ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៥ លេខ ៣ កក្កដា - កញ្ញា ឆ្នាំ២០១១ តម្លៃ ១.៥០០រ

# ការដោះស្រាយបញ្ហាចំណាកស្រុកមិនស្របច្បាប់នៅកម្ពុជា[១]



ការងារនៅលើទូកនេសាទសមុទ្រ មានគ្រោះថ្នាក់ និងមានការរំលោភបំពានខ្លាំងបំផុត សម្រាប់ជនចំណាកស្រុកជាបុរស។

## សេចក្ដីផ្ដើម

នៅប្រទេសកម្ពុជា ចំណាកស្រុកភាគច្រើនមានលក្ខណៈមិនស្របច្បាប់ ហើយតាមធម្មតា ការធ្វើដំណើរ តែងមានអ្នកធ្លាប់ធ្វើចំណាកស្រុកពីមុន ឬមេខ្យល់ជួយសម្របសម្រួល។ បញ្ហានេះ បានប្រែជាស្មុគស្មាញ និងពិបាកគ្រប់គ្រងខ្លាំងណាស់ ហើយប៉ះពាល់ដល់ អភិបាលកិច្ចចំណាកស្រុកនៃកម្លាំងពលកម្ម។ វាចោទបញ្ហាខាងការគ្រប់គ្រង ពីព្រោះការធ្វើដំណើរតែងកើត ឡើងនៅក្រៅក្របខ័ណ្ឌច្បាប់នៃប្រទេសបញ្ជូន និងប្រទេសទទួលពលករ ដែលនាំឲ្យលំបាកដល់ការកត់ត្រា និងតាមដាន ហើយក៏បង្កជាបញ្ហាដល់ការការពារផងដែរ។ ស្ថានភាពមិនស្របច្បាប់នេះ ធ្វើឲ្យជនចំណាកស្រុកងាយរងគ្រោះបំផុត ដោយការរំលោភ និងការកេងប្រវ័ញ្ចពីសំណាក់និយោជក ហើយជារឿយៗ មិនបានទទួលការការពារផ្នែកច្បាប់ទេ។ ក្នុងករណីធ្ងន់ធ្ងរបំផុត ពួកគេត្រូវរងគ្រោះដោយការជួញដូរមនុស្ស។ គម្លាតធ្ងន់ធ្ងររវាងគោលនយោបាយ និងការអនុវត្តជាក់ស្ដែងទាក់ទងនឹងចំណាកស្រុកមិនស្របច្បាប់ បង្ហាញពីតម្រូវការកាន់តែខ្លាំងនូវការវិភាគស៊ីជម្រៅ និងអន្តរាគមន៍គោលនយោបាយ ដែលជាកម្មវត្ថុដ៏ចម្បងនៃការសិក្សាស្រាវជ្រាវនេះ។

## ការពិនិត្យត្រួសៗពីចំណាកស្រុកមិនស្របច្បាប់នៅកម្ពុជា

### *និយមន័យ និងស្ថានភាព*

ចំណាកស្រុកមិនស្របច្បាប់ គេតែងកំណត់ជាទូទៅថាជាការធ្វើដំណើរមិនស្របច្បាប់ទៅធ្វើការនៅក្នុងប្រទេសណាមួយ ឬការធ្វើដំណើរដោយមិនមានការអនុញ្ញាតឲ្យធ្វើការ និងមានរួមបញ្ចូលផងដែរនូវ ករណីអ្នកធ្វើចំណាកស្រុកស្របច្បាប់ ប៉ុន្តែក្រោយមកបានបាត់បង់ស្ថានភាពស្របច្បាប់របស់ខ្លួន (ឧទាហរណ៍ ដោយសារការស្នាក់នៅហួសពេលកំណត់) (UN General Assembly; Brennan 1984; Global Commission on International Migration 2005; LeVoy & Geddie2010; Lee 2005)។ ពាក្យ "មិនស្របច្បាប់" អាចជំនួសបានដោយពាក្យ "គ្មានឯកសារត្រឹមត្រូវ" "គ្មានការអនុញ្ញាត" "មិនផ្លូវការ" ឬ "លួចលាក់"។

ចំណាកស្រុកមិនស្របច្បាប់ ជាទម្រង់ពេញនិយមបំផុតសម្រាប់ការធ្វើដំណើរឆ្លងកាត់ព្រំដែន ក្នុងចំណោមពលករកម្ពុជា ដែលស្វែងរកការងារធ្វើនៅក្រៅប្រទេស។ ចំណាកស្រុកមិនស្របច្បាប់មានពីរប្រភេទ។ **ប្រភេទទី១** គឺចំណាកស្រុកចម្ងាយជិតនៅតាមព្រំដែនកម្ពុជា-ថៃ។ នៅទីនោះ ការងារភាគច្រើនជាប្រភេទកសិកម្ម ដែលជនចំណាកស្រុកដឹងពី សាច់ញាតិ មិត្តភក្តិ ឬអ្នកភូមិ ដែលបានធ្វើចំណាកស្រុកពីមុន។ អ្នកធ្លាប់ត្រួសត្រាយផ្លូវទាំងនេះ អាចជួយសម្រួលដល់ការរកកន្លែងធ្វើការ

## មាតិកា

ការដោះស្រាយចំណាកស្រុកមិនស្របច្បាប់នៅកម្ពុជា............ ១
ការពិចារណាពីផលប៉ះពាល់នៃចំណាកស្រុកលើឪពុកម្ដាយវ័យជរា៖ ភស្តុតាងពីឃុំពីរ ក្នុងខេត្តបាត់ដំបង .................. ៧
ការពង្រឹងផលចំណេញ ការត្រៀមរៀបចំសម្រាប់ការផ្លាស់ប្ដូរ៖ កម្លាំងពលកម្ម និងពិពិធកម្មនៅកម្ពុជា ......................... ១២
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ...................... ១៥
— ស្ថានភាពក្នុងប្រទេស........................ ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........................................ ២៤

[១] លោក ហ៊ីង-វុត្ថា និង លោក លន់-ពិដេ ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

**តារាង ១៖ ជនចំណាកស្រុកមិនស្របច្បាប់នៅថៃ បែងចែកតាមវិស័យសេដ្ឋកិច្ចឆ្នាំ២០០៩**

| វិស័យសេដ្ឋកិច្ច | ចំនួនកម្មករ | | | |
|---|---|---|---|---|
| | កម្ពុជា | ឡាវ | ភូមា | សរុប |
| នេសាទ | 14969 | 1800 | 39809 | 56578 |
| ទាក់ទិននឹងនេសាទ | 6020 | 1180 | 129773 | 136973 |
| កសិកម្ម និងចិញ្ចឹមសត្វ | 24085 | 18035 | 179583 | 221703 |
| ពាក់ព័ន្ធនឹងកសិកម្ម និងចិញ្ចឹមសត្វ | 7077 | 4469 | 62611 | 74157 |
| សំណង់ | 32465 | 12635 | 175136 | 220236 |
| យករ៉ែ/ថ្ម | 61 | 35 | 1747 | 1843 |
| លក់ដុំ &លក់រាយ | 4778 | 7565 | 30471 | 42814 |
| អាហារ និងភេសជ្ជៈ (អ្នកលក់) | 4483 | 13074 | 36668 | 54225 |
| បម្រើការតាមផ្ទះ | 6578 | 21267 | 101945 | 129790 |
| ផ្សេងៗ | 24245 | 30794 | 321024 | 376063 |
| សរុប | 124761 | 110854 | 1078767 | 1314382 |

*ប្រភព៖ Paitoonpong & Sukaruji (ជិតចេញផ្សាយ)*

និងបង្កើតជាបណ្តាញតភ្ជាប់រវាងក្រុមគ្រួសារនៅជនបទ និងតំបន់គោលដៅនៅថៃ។ របៀបរបបអនុវត្តនេះ ជនចំណាកស្រុកបានចាត់ទុកជាទូទៅថា មានសុវត្ថិភាព ងាយស្រួល និងអស់ចំណាយតិចសមរម្យ និងមិនចាំបាច់ត្រូវចំណាយពេលរង់ចាំ មិនត្រូវការឯកសារ និងនីតិវិធីជ្រើសរើសស្មុគស្មាញទេ។ សម្រាប់អ្នកដែលទិញលិខិតឆ្លងកាត់ព្រំដែន សម្រាប់រយៈពេលមួយសប្តាហ៍ ហៅថា *បាត* ជាដំបូងត្រូវចំណាយប្រាក់សម្រាប់ចំណាកស្រុកនេះពី ៣,០ ទៅ ៥,៥ដុល្លារ ដោយក្នុងនេះ មានចំណាយលើរថយន្តឈ្នួល ពី ២,៥ ទៅ ៥,០ដុល្លារ និងលើលិខិតឆ្លងកាត់ព្រំដែន ០,៥ដុល្លារ។ ជនចំណាកស្រុក ត្រូវធ្វើលិខិតឆ្លងកាត់ព្រំដែនជាថ្មីរៀងរាល់សប្តាហ៍នៅច្រកព្រំដែន។ ពួកគាត់ក៏អាចទិញលិខិតឆ្លងកាត់ព្រំដែនរយៈពេល១ឆ្នាំ បានដែរ ដែលមានតម្លៃ ១៩ដុល្លារ។

**ចំណាកស្រុកប្រភេទទី២** គឺការធ្វើដំណើរចម្ងាយឆ្ងាយទៅថៃ ឬម៉ាឡេស៊ី ដើម្បីធ្វើការលើទូកនេសាទ ឬធ្វើជាកម្មករសំណង់ ឬកម្មកររោងចក្រ។ ក្នុងករណីភាគច្រើន ជនចំណាកស្រុកធ្វើដំណើរជាក្រុមតូចៗជាមួយមេខ្យល់ ទៅកន្លែងធ្វើការនៅថៃ។ សេវាជាមូលដ្ឋានដែលមេខ្យល់ផ្តល់ឲ្យ រួមមាន ការធ្វើដំណើរទៅព្រំដែន និងការសុំលិខិតអនុញ្ញាតឲ្យធ្វើការ និងការរកការងារនៅក្នុងប្រទេសគោលដៅ។ ជនចំណាកស្រុកត្រូវបង់ជាមុននូវប្រាក់កម្រៃសម្រួលការនេះ ដែលមានចំនួនពី ១០០ ទៅ ២០០ដុល្លារ។

ថៃ ជាទិសដៅចំបងនៃចំណាកស្រុកមិនស្របច្បាប់ពីកម្ពុជា។ អង្គការចំណាកស្រុកអន្តរជាតិ (International Organisation for Migration) បានបញ្ជាក់ថា អាចមានប្រជាជនកម្ពុជាដល់ ១៨០.០០០នាក់ ដែលធ្វើការក្រៅផ្លូវការនៅថៃ។ ក្រសួងការងារប្រទេសថៃ (Paitoonpong & Sukaruji ជិតចេញផ្សាយ) បានប៉ាន់ស្មានថា មានជនចំណាកស្រុកកម្ពុជាមិនស្របច្បាប់ប្រមាណ ១២០.០០០នាក់។ យោងតាមប្រភពដដែល (តារាង១) ជនចំណាកស្រុកកម្ពុជាមិនស្របច្បាប់ភាគច្រើននៅប្រទេសថៃ ធ្វើការក្នុងវិស័យកសិកម្ម (៤២%) និងសំណង់ (២៦%)។ ម៉ាឡេស៊ី ជាគោលដៅចម្បងទី២ នៃជនចំណាកស្រុកមិនស្របច្បាប់ ហើយក្រុមនេះភាគច្រើនជាជនជាតិភាគតិចចាម។ ផ្លូវធ្វើដំណើរតាមធម្មតា គឺជិះយន្តហោះទៅម៉ាឡេស៊ីជាទេសចរ បន្ទាប់មកស្វែងរកការងារដោយមិនមានលិខិតអនុញ្ញាតការងារ។ ជនចំណាកស្រុកមិនស្របច្បាប់ទៅម៉ាឡេស៊ីភាគច្រើន គឺដើម្បីស្វែងរកការងារធ្វើនៅក្នុងវិស័យសំណង់ និងកម្មន្តសាល។

## *លក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ចនៃជនចំណាកស្រុកកម្ពុជាមិនស្របច្បាប់*

គ្រួសារជាងពាក់កណ្តាលក្នុងគំរូតាង[២] មានសមាជិកគ្រួសារធ្វើចំណាកស្រុក ដែលភាគច្រើនមិនស្របច្បាប់។ នារីមានប្រមាណ ១/៣នៃជនចំណាកស្រុក (តារាង ២)។ ទាំងជនចំណាកស្រុកស្របច្បាប់ និងមិនស្របច្បាប់ ភាគច្រើនមានអាយុជិត៣០ឆ្នាំ។ ទំហំគ្រួសារជាមធ្យម គឺប្រមាណ ៥នាក់ ដែលប្រហាក់ប្រហែលគ្នានឹងគ្រួសារមិនធ្វើចំណាកស្រុក។ ប៉ុន្តែជនចំណាកស្រុកស្របច្បាប់ និងមិនស្របច្បាប់ មានកម្រិតអប់រំខុសគ្នាច្រើន (តារាង ៣)។

គ្រួសារដែលមានជនចំណាកស្រុកមិនស្របច្បាប់ មានស្ថានភាពសេដ្ឋកិច្ច ទាបជាងគ្រួសារដែលមានជនចំណាកស្រុកស្របច្បាប់ ឬមិនធ្វើចំណាកស្រុក។ តារាង ៤ បង្ហាញថា ជនចំណាកស្រុកមិនស្របច្បាប់ ចំណាយលើអាហារប្រមាណ ១៩% តិចជាងជនមិនធ្វើចំណាកស្រុក ប៉ុន្តែតិចជាងជនចំណាកស្រុកស្របច្បាប់បន្តិចបន្តួចប៉ុណ្ណោះ។ ភាពខុសគ្នានៃចំណាយរវាងជនចំណាកស្រុកមិនស្របច្បាប់ និងស្របច្បាប់ មិនមានសារៈសំខាន់ខាងស្ថិតិទេ។ ចំណាយប្រើប្រាស់មិនមែនអាហាររបស់ជនចំណាកស្រុកមិនស្របច្បាប់ មានចំនួន ៤០%

២ អង្កេតនេះ វិទ្យាស្ថាន CDRI បានធ្វើឡើងនៅចុងឆ្នាំ២០០៧ សម្រាប់គម្រោងស្រាវជ្រាវ "ចំណាយ និងផលចំណេញនៃចំណាកស្រុកពលកម្មឆ្លងកាត់ព្រំដែនក្នុង GMS៖ ករណីសិក្សាពីកម្ពុជា" ។ អង្កេតនេះបានសម្ភាសន៍ ៥២៦ គ្រួសារមកពី ៦ភូមិ ដែលមានសកម្មភាពចំណាកស្រុកច្រើន។

**តារាង ២៖ គ្រួសារ និងសមាជិកធ្វើចំណាកស្រុក**

| | ស្របច្បាប់ | % | មិនស្របច្បាប់ | % | មិនធ្វើចំណាកស្រុក | % | សរុប |
|---|---|---|---|---|---|---|---|
| គ្រួសារ | 16 | 3 | 293 | 56 | 217 | 41 | 526 |
| ជនចំណាកស្រុក | 19 | 4 | 494 | 96 | - | - | 513 |
| ស្ត្រី | 6 | 3 | 171 | 97 | - | - | 177 |

*ប្រភព៖ Chan (2009)*

**តារាង៣៖ លក្ខណៈសង្គមរបស់ជនចំណាកស្រុក និងមិនមែនចំណាកស្រុក**

| ប្រភេទចំណាកស្រុក | ស្របច្បាប់ | មិនស្របច្បាប់ | មិនធ្វើចំណាកស្រុក |
|---|---|---|---|
| ទំហំគ្រួសារជាមធ្យម | 5.0 | 5.6 | 4.8 |
| ចំនួនសមាជិកក្នុងបន្ទុក* | 1.6 | 2.2 | 2.1 |
| អាយុជាមធ្យមរបស់ជនចំណាកស្រុក | 28.6 | 27.8 | - |
| ចំនួនឆ្នាំជាមធ្យមនៃការសិក្សារបស់ជនចំណាកស្រុក | 6.8 | 4.3 | - |

**សមាជិកគ្រួសារអាយុតិចជាង ១៥ឆ្នាំ ឬច្រើនជាង ៥៤ឆ្នាំ។*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យអង្កេតឆ្នាំ២០០៧។*

តិចជាងជនចំណាកស្រុកស្របច្បាប់ និង ១៣% តិចជាងជនមិនធ្វើចំណាកស្រុក។ ចំណាយជាមធ្យមរបស់ជនចំណាកស្រុកមិនស្របច្បាប់ មានចំនួន ១៧% តិចជាងចំណាយរបស់ជនមិនធ្វើចំណាកស្រុក។ តម្លៃទ្រព្យសម្បត្តិរបស់គ្រួសារជនចំណាកស្រុកមិនស្របច្បាប់ មានប្រហែលពាក់កណ្តាលនៃគ្រួសារជនចំណាកស្រុកស្របច្បាប់ (ទាំងក្នុងឆ្នាំ២០០២ និង ២០០៧)។

## មូលហេតុនាំឲ្យមានចំណាកស្រុកមិនស្របច្បាប់

ចំណាកស្រុកមិនស្របច្បាប់ មានមូលហេតុចម្រុះ។ ការសិក្សានេះបានរកឃើញថា គោលនយោបាយពលកម្ម និងលក្ខខណ្ឌទីផ្សារពលកម្មក្នុងប្រទេសម្ចាស់ផ្ទះជាមូលហេតុមួយនាំឲ្យមាន លំហូរជនចំណាកស្រុកកម្ពុជាមិនស្របច្បាប់ដ៏ច្រើនសន្ធឹកនេះ។ ម្យ៉ាងទៀតក៏មានភាពមិនស៊ីគ្នារវាងតម្រូវការពលកម្ម និងការផ្គត់ផ្គង់ពលកម្មក្នុងប្រទេសម្ចាស់ផ្ទះដែរ ព្រមទាំងទីផ្សារងងឹតដែលមានបណ្តាញរឹងមាំ សម្រាប់ផ្គត់ផ្គង់ពលករ។ ការអនុវត្តច្បាប់ធូររលុងប្រឆាំងនឹងនិយោជក ដែលជួលពលករមិនស្របច្បាប់ បានលើកទឹកចិត្តពួកគេឲ្យជ្រើសរើសពលករពីទីផ្សារងងឹត។ ក្នុងករណីប្រទេសថៃ អតុល្យភាពអាចមើលឃើញច្បាស់ តាមការចុះឈ្មោះពលករមិនស្របច្បាប់ចាប់ពីឆ្នាំ១៩៩២ មក (Paitoonpong & Sukaruji ជិតចេញផ្សាយ)។

**តារាង ៤៖ មធ្យម (mean) ចំណាយប្រើប្រាស់ប្រចាំថ្ងៃ និងតម្លៃទ្រព្យសម្បត្តិ (គិតក្នុងមនុស្សម្នាក់) នៃគ្រួសារគំរូតាងមួយចំនួន**

| | | មធ្យម (Mean) | | | T-Value† | | |
|---|---|---|---|---|---|---|---|
| | | ស្របច្បាប់(a) | មិនស្របច្បាប់ (b) | មិនចំណាកស្រុក (c) | (b)–(a) | (b)–(c) | (a)–(c) |
| ចំណាយប្រើប្រាស់ (រៀល/នាក់) | អាហារ | 1142.0 | 1168.6 | 1391.8 | 0.2 | -5.3*** | -2.0** |
| | | (478.5) | (450.1) | (469.4) | | | |
| | មិនមែនអាហារ | 1223.0 | 877.2 | 990.4 | -2.2** | -1.9* | 1.2 |
| | | (752.46) | (578.8) | (668.2) | | | |
| | សរុប | 2515 | 2249 | 2641 | -0.8 | -3.3*** | -0.3 |
| | | (1155) | (1241) | (1367) | | | |
| ទ្រព្យសម្បត្តិ (ពាន់រៀល/នាក់)‡ | 2002 | 818.9 | 371.2 | 433.9 | -3.3*** | -1.2 | 2.5** |
| | | (727.2) | (517.3) | (562.5) | | | |
| | 2007 | 1265.9 | 665.5 | 721.1 | -3.1*** | -0.8 | 2.8*** |
| | | (670.6) | (765.9) | (737.7) | | | |

*សម្គាល់៖ Standard deviation in parentheses. † Two-sample t-test of different means with equal variance.*

*‡ Excluding land and house. * significant at 10% level. ** significant at 5% level. *** significant at 1% level.*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យអង្កេតឆ្នាំ២០០៧។*

គិតមកដល់ឆ្នាំ២០០៩ អាជ្ញាធរថៃបានចុះឈ្មោះជនចំណាកស្រុកមិនស្របច្បាប់កម្ពុជាបាន ១២៤.៧៦១នាក់ (*ibid*)។

បញ្ហានៅស្រុកកំណើត ក៏ជម្រុញឲ្យប្រជាជនចាកចេញដែរ។ ជម្លោះផ្ទៃក្នុង និងអស្ថិរភាពនយោបាយ លែងជាបញ្ហាបារម្ភចម្បងរបស់ប្រជាជនកម្ពុជាទៀតហើយ។ ឥឡូវនេះបញ្ហាសេដ្ឋកិច្ច ជាពិសេសភាពក្រីក្រ ទើបជាបញ្ហាចម្បង។ តួលេខចំណាយប្រើប្រាស់ក្នុងតារាង ៤ បង្ហាញថា ជនចំណាកស្រុកកំពុងរស់នៅក្រោមបន្ទាត់ក្រីក្របន្តិច ហើយមានច្រើននាក់ណាស់ប្រាថ្នាត្រឹមតែរំដោះខ្លួនពីភាពក្រីក្រប៉ុណ្ណោះ។ ចំណាកស្រុកក្នុងប្រទេសទៅកាន់ទីប្រជុំជន ក៏ជាជម្រើសមួយដែរ ប៉ុន្តែការងារមានតែក្នុងផ្នែកអតិពលកម្មប្រើជំនាញទាប ដូចជា ខាងសំណង់ និងកាត់ដេរជាដើម។

ហេតុអ្វីបានជាប្រជាជន មិនជ្រើសយកចំណាកស្រុកស្របច្បាប់? លក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ចរបស់ជនចំណាកស្រុកមិនបានបង្ហាញថា ភាពខុសគ្នាក្នុងស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចបានជះឥទ្ធិពល ដល់ការសម្រេចចិត្តរបស់ពួកគេនោះទេ។ ម្យ៉ាងវិញទៀត អ្នកទាំងនោះក៏មិនមែនកើតមកសម្រាប់តែធ្វើជាពលករមិនស្របច្បាប់នោះដែរ។ ពួកគេអាចជ្រើសយកវិធីណាដែលខ្លួនអាចរកបាន និងរ៉ាប់រងចំណាយបាន។ លោក Chan (2009) បានអះអាងថា ចំណាយពីដំបូងដ៏ច្រើននៃចំណាកស្រុកស្របច្បាប់ ជាហេតុផលចម្បងមួយ នាំឲ្យពួកគេចូលចិត្តធ្វើចំណាកស្រុកមិនស្របច្បាប់ ទោះបីជាចំណាកស្រុកស្របច្បាប់វាផ្ដល់ប្រាក់ចំណេញសុទ្ធបានច្រើនជាងក្ដី។ លោក Chan វែកញែកថា ដើម្បីបានការងារស្របច្បាប់នៅប្រទេសថៃ ពលករត្រូវការប្រាក់ដល់ប្រមាណ ៧០០ដុល្លារ ដែលពលករនៅជនបទកម្ពុជាភាគច្រើន មិនអាចរកបានទេ។ បើសិនធ្វើចំណាកស្រុកមិនស្របច្បាប់វិញ ម្នាក់ៗចំណាយអស់តិចជាងនេះឆ្ងាយណាស់។ ទិន្នន័យបែបគុណវិស័យ ក៏បានបញ្ជាក់គាំទ្រដល់ការអះអាងរបស់លោក Chan ដែលថា ជនចំណាកស្រុកមិនស្របច្បាប់ដែលក្រីក្រខ្លាំង មិនឃើញមានចំណាប់អារម្មណ៍ខិតខំស្វែងរកការងារ តាមរយៈភ្នាក់ងារជ្រើសរើសពលករស្របច្បាប់នោះទេ។ ចំណាកស្រុកស្របច្បាប់ទៅប្រទេសថៃ អាចចំណាយពេលអស់ពី ៣ ទៅ ៦ខែ រីឯចំណាកស្រុកមិនស្របច្បាប់វិញ ចំណាយពេលអស់ត្រឹមតែ ២-៣ថ្ងៃ និងត្រូវការឯកសារតិចតួចជាង ឬគ្មានសោះ។

ទីតាំងភូមិសាស្ត្រនៅជិត ក៏ជាកត្តាបង្កើនលំហូរចំណាកស្រុកក្រៅផ្លូវការដែរ (Battistella 2002)។ ប្រទេសកម្ពុជាមានព្រំដែនគោកជាប់ប្រទេសថៃ ប្រវែង ៨០៣គីឡូម៉ែត្រ ដែលមានច្រកមិនផ្លូវការជាច្រើន។ ព្រំដែនដ៏វែងបែបនេះ ពិបាកគ្រប់គ្រងខ្លាំងណាស់។ ម្យ៉ាងទៀត បណ្ដាញមានស្រាប់ ក៏បានជួយសម្រួលដល់ដំណើររបស់ជនចំណាកស្រុកមិនស្របច្បាប់ ដែលតែងពឹងផ្អែកលើមិត្តភក្តិ ឬសាច់ញាតិដែលកំពុងធ្វើការនៅក្នុងប្រទេសម្ចាស់ផ្ទះដែរ។ បណ្ដាញប្រភេទនេះ បានជួយកាត់បន្ថយបន្ទុកចំណាយលើការស្វែងរកការងារ និងបង្កើនលទ្ធភាពរកបានការងារធ្វើ (Chiuri *et al.* 2005)។

## បញ្ហា និងការប្រឈមនៃចំណាកស្រុកមិនស្របច្បាប់

ពលករចំណាកស្រុកមិនស្របច្បាប់ ប្រឈមនឹងហានិភ័យកាន់តែខ្ពស់នៃការកេងប្រវ័ញ្ច និងការមិនទទួលបានសិទ្ធិជាមូលដ្ឋាន ដូចជា ការថែទាំសុខភាព និងការអប់រំជាដើម (IOM 2003)។ កន្លងមកមានភស្តុតាងជាច្រើននៃការរំលោភដោយនិយោជក ដូចជា ការបង្ខំឲ្យធ្វើការលើសម៉ោង ការកាត់ប្រាក់ខែ និងការបៀតបៀនផ្លូវភេទ បៀវត្សរ៍ទាបជាងកម្រិតមធ្យម និងលក្ខខណ្ឌការងារមិនល្អ។

Naro (2009) បានចងក្រងករណីសិក្សាអំពីជនចំណាកស្រុកកម្ពុជា ដែលបានទទួលរងការរំលោភបំពានពីនិយោជក ដូចជា ខ្លះត្រូវធ្វើការច្រើនម៉ោងតែបានប្រាក់កម្រៃទាប ហើយខ្លះទៀតបានទទួលទារុណកម្មលើរូបរាងកាយ នៅពេលពួកគេមិនព្រមធ្វើតាមបញ្ជា។ Marshall (2001) បានបង្ហាញភស្តុតាងពីកុមារកម្ពុជា ដែលគេជួញដូរឲ្យធ្វើជាអ្នកសុំទាន និងអ្នកលក់ផ្កាតាមផ្លូវ ខណៈដែលជនចំណាកស្រុកជាស្ត្រី ត្រូវគេបង្ខំឲ្យធ្វើជាអ្នកបម្រើផ្លូវភេទ។ យោងតាមរបាយការណ៍ពី UNIAP (2010) ជារៀងរាល់ឆ្នាំមានប្រជាជនកម្ពុជារាប់ពាន់នាក់ ត្រូវបានគេជួញដូរទៅប្រទេសថៃ។ បុរសៗត្រូវគេជួញដូរឲ្យទៅធ្វើការលើទូកនេសាទ ឬធ្វើជាកម្មករសំណង់។ នារីៗ ត្រូវគេជួញដូរឲ្យធ្វើការក្នុងឧស្សាហកម្មកំសាន្ត ដែលមានទាំងបនពេស្យាចារផង។

ការងារនៅលើទូកនេសាទសមុទ្រ មានគ្រោះថ្នាក់ និងមានការរំលោភបំពានខ្លាំងបំផុត សម្រាប់ជនចំណាកស្រុកជាបុរស។ ក្រៅពីការមិនបើកប្រាក់ខែឲ្យ ជនចំណាកស្រុកត្រូវទទួលរងលក្ខខណ្ឌការងារធ្ងន់ធ្ងរ ហើយត្រូវទទួលរងទារុណកម្មលើរាងកាយ ប្រសិនបើមេការរកឃើញថាមានកំហុសអ្វីមួយ។ ពួកគេត្រូវធ្វើការរហូតដល់១៥ម៉ោងក្នុងមួយថ្ងៃ និងមានករណីរាយការណ៍អំពីការបង្ខំឲ្យប្រើប្រាស់គ្រឿងញៀន ដើម្បីអាចទ្រាំទ្រនឹងការងារធ្ងន់ធ្ងរបាន (ICSW 2007)។ ជនចំណាកស្រុកមួយចំនួន ត្រូវគេជួញដូរ និងយកទៅលក់ដោយមិនដឹងខ្លួន ដូច្នេះត្រូវធ្វើការជាច្រើនឆ្នាំដើម្បីដោះបំណុល (*ibid*)។ ក្រៅពីការកេងប្រវ័ញ្ច ជនចំណាកស្រុកកម្ពុជាមិនស្របច្បាប់ជាច្រើនមិនអាចទទួលបានសេវាសង្គម ដូចជា ការថែទាំសុខភាព និងការអប់រំសម្រាប់កូនៗរបស់ពួកគេ ពីព្រោះត្រូវរត់គេចពីអាជ្ញាធរដែលជាមធ្យោបាយតែមួយគត់ ដើម្បីដោះស្រាយស្ថានភាពលួចលាក់របស់ខ្លួន។

## វិធីផ្នែកច្បាប់ដើម្បីដោះស្រាយបញ្ហាចំណាកស្រុកមិនស្របច្បាប់

មានការមូលមតិក្នុងអន្តរជាតិថា ចំណាកស្រុកមិនស្របច្បាប់គួរតែដោះស្រាយក្នុងលក្ខណៈរួម និងគ្រប់ជ្រុងជ្រោយ តាមរយៈការពិនិត្យពីមូលហេតុនានា ការដោះស្រាយផលប៉ះពាល់របស់វា និងការបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ។

### *ដោះស្រាយមូលហេតុនៃចំណាកស្រុកមិនស្របច្បាប់*

ភាពក្រីក្ររ៉ាំរ៉ៃ បន្ទុកចំណាយខ្ពស់លើចំណាកស្រុកស្របច្បាប់ និងការអនុវត្តខុសឆ្គងដោយទីភ្នាក់ងារឯកជនមួយចំនួនដែលរកការងារឲ្យធ្វើ បានជំរុញពលករកម្ពុជាឲ្យធ្វើចំណាកស្រុកតាមរយៈបណ្ដាញក្រៅផ្លូវការ។ អន្តរាគមន៍ផ្សេងៗដើម្បីដោះស្រាយកត្តាជំរុញទាំងនេះ នឹងជួយកាត់បន្ថយចំណាកស្រុកមិនស្របច្បាប់។

*ពង្រឹងការអភិវឌ្ឍសហគមន៍ដើមៈ* ការវិភាគខាងលើបង្ហាញថា គ្រួសារនានាជ្រើសយកចំណាកស្រុកដើម្បីគេចផុតពី

ភាពក្រីក្រធ្ងន់ធ្ងរ និងការលំបាកខាងសេដ្ឋកិច្ចនៅមូលដ្ឋាន។ ទោះជាមិនទាន់មានភស្តុតាងជាក់ស្តែងច្បាស់លាស់ អំពីទំនាក់ទំនងរវាងការអភិវឌ្ឍ និងចំណាកស្រុកក្តី ក៏ការអភិវឌ្ឍសហគមន៍អាចកាត់បន្ថយចំណាកស្រុកបាន ដោយជួយជំនះលើហេតុផលដែលធ្វើឲ្យជនចំណាកស្រុក ជ្រើសយកវិធីមិនស្របច្បាប់។ វិធានការអាទិភាពដែលអាចយកមកអភិវឌ្ឍសហគមន៍ រួមមានការបង្កើនជំនួយឧបត្ថម្ភផ្នែកកសិកម្ម ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ការបង្កើនលទ្ធភាពបានប្រើប្រាស់ធនធានធម្មជាតិ និងការពង្រឹងការផ្គត់ផ្គង់សេវាសាធារណៈ ជាពិសេសការអប់រំ និងការថែទាំសុខភាព។ ជំនួយអភិវឌ្ឍន៍ ត្រូវផ្តោតឲ្យចំសហគមន៍នានាដែលមានអត្រាចំណាកស្រុកខ្ពស់។

*បើកឱកាសឲ្យមានចំណាកស្រុកស្របច្បាប់៖* ដោយមានជម្រើសតិចតួចសម្រាប់ចំណាកស្រុកស្របច្បាប់ ចំណាកស្រុកមិនស្របច្បាប់ ក៏បានក្លាយជាវិធីតែមួយគត់ដែលពលករចំណាកស្រុកកម្ពុជាភាគច្រើន អាចមានលទ្ធភាពធ្វើបាន។ មានការមូលមតិជាអន្តរជាតិ ដូចមានបញ្ជាក់ក្នុងកិច្ចប្រជុំត្រីភាគីនៃ ILO តំបន់អាស៊ី ឆ្នាំ២០០៣ នៅក្រុងបាងកកនោះថា ឱកាសធ្វើចំណាកស្រុកស្របច្បាប់ដោយងាយស្រួល និងមានតម្លាភាព អាចជាចំណែកមួយនៃដំណោះស្រាយដ៏សក្តិសិទ្ធិ ចំពោះបញ្ហាចំណាកស្រុកមិនស្របច្បាប់។ អាទិភាពដ៏សំខាន់បំផុតនៃប្រព័ន្ធស្វែងរកការងារស្របច្បាប់របស់កម្ពុជា គឺត្រូវធ្វើឲ្យសាមញ្ញនូវនីតិវិធីរដ្ឋបាល ពន្លឿនការសម្របសម្រួលសេវា និងកាត់បន្ថយចំណាយលើការរកការងារឲ្យធ្វើ។

*រៀបចំច្បាប់គ្រប់គ្រងទីភ្នាក់ងារឯកជនស្វែងរកការងារឲ្យធ្វើ៖* ការកើតមានព្រឹត្តិការណ៍ធ្ងន់ធ្ងរម្តងហើយម្តងទៀត នៃការមិនអនុវត្តតាម និងអនុវត្តខុសឆ្គង បានបង្ហាញពីតម្រូវការជាបន្ទាន់នូវបទបញ្ញត្តិតឹងរ៉ឹងលើទីភ្នាក់ងារជ្រើសរើសពលករ។ ការជ្រើសរើស និងការដាក់ឲ្យធ្វើការ ត្រូវមានបទបញ្ញត្តិគ្រប់គ្រងតឹងរ៉ឹងតាមរយៈប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ដែលក្នុងនោះមានកំណត់ច្បាស់នូវការទទួលខុសត្រូវរបស់ទីភ្នាក់ងារ លក្ខខណ្ឌជ្រើសរើស និងទោសទណ្ឌ។ បទបញ្ញត្តិល្អ ក៏ត្រូវមានការតាមដានយ៉ាងសកម្មដែរ ដើម្បីធានានូវការអនុវត្តតាមជាអតិបរមា។ ការតាមដានគួរមានទាំងការទទួលបានរបាយការណ៍ពីទីភ្នាក់ងារ ស្តីពីការជ្រើសកន្លែងដាក់ឲ្យធ្វើការ និងស្ថានភាពការងាររបស់ពលករ ការចុះពិនិត្យជាទៀងទាត់ដោយភ្នាក់ងាររដ្ឋាភិបាល ឬអ្នកតំណាង ព្រមទាំងការងារជាច្រើនទៀត។

## ការការពារ និងសុខុមាលភាពរបស់ពលករចំណាកស្រុក

*ពង្រឹងការអប់រំ និងបំផុសចំណាប់អារម្មណ៍៖* ព័ត៌មានកាន់តែប្រសើរ នាំឲ្យមានការការពារកាន់តែប្រសើរ ដូច្នេះគួរជួយពង្រឹងការអប់រំ និងបំផុសចំណាប់អារម្មណ៍របស់ពលករមុនពេលត្រូវចេញដំណើរ។ ព័ត៌មានអាចផ្សព្វផ្សាយបានតាមរយៈការបង្កើតមជ្ឈមណ្ឌលធនធានចំណាកស្រុកថ្នាក់ជាតិ និងថ្នាក់ខេត្ត។ មុខងារសំខាន់ៗរបស់មជ្ឈមណ្ឌល មានជាអាទិ៍ ការចុះបញ្ជីពលករចំណាកស្រុកជាសក្តានុពល និងការផ្តល់ព័ត៌មានតាមរយៈសៀវភៅតូចៗ ផ្ទាំងផ្សព្វផ្សាយ ការពិគ្រោះយោបល់ ទស្សនកិច្ចប្រព័ន្ធផ្សព្វផ្សាយ កិច្ចប្រជុំ និងសិក្ខាសាលា។

*ពង្រីកការផ្តល់សេវាគាំទ្រ៖* ការតែងតាំងអនុព័ន្ធពលកម្មនៅថៃ និងម៉ាឡេស៊ី ដែលមានពលករចំណាកស្រុកកម្ពុជាភាគច្រើនទៅធ្វើការ ជាមធ្យោបាយល្អមួយដើម្បីពង្រឹងសេវាកម្មគាំទ្រ។ ក្នុងមុខងាររបស់អនុព័ន្ធ គួរមានទាំង ការកសាងទំនាក់ទំនងការងាររឹងមាំជាមួយប្រទេសម្ចាស់ផ្ទះ ស្តីពីបញ្ហាពលករ ការតាមដានការអនុវត្តចំពោះពលករចំណាកស្រុក ការផ្តល់ជំនួយផ្នែកច្បាប់ទប់ទល់នឹងការរំលោភកិច្ចសន្យា ការរំលោភបំពាន ការកេងប្រវ័ញ្ច ការជួយមតិអំពីបញ្ហាពាក់ព័ន្ធនឹងកិច្ចសន្យា ឬការងារ និងការធានាឲ្យជនចំណាកស្រុកមិនស្របច្បាប់ ទទួលបានការការពារ និងការជួយសម្រួលនៅពេលធ្វើមាតុភូមិនិវត្តន៍។

## ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ

ចំណាកស្រុក ជាបញ្ហាពហុភាគី ដូច្នេះត្រូវមានការចរចា និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីញ៉ាំងឲ្យចំណាកស្រុកពលករមានរបៀបរៀបរយ និងមានច្បាប់គ្រប់គ្រងត្រឹមត្រូវ (ILO 2010)។ ចំណាកស្រុកមិនស្របច្បាប់ អាចដោះស្រាយបានប្រសើរបំផុតក្នុងក្របខ័ណ្ឌទ្វេភាគី និងតំបន់ ដើម្បីបំពេញបន្ថែមលើគោលនយោបាយជាតិ។

*ការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី៖* កិច្ចសហប្រតិបត្តិការរវាងប្រទេសបញ្ជូន និងប្រទេសទទួល ឃើញមានប្រសិទ្ធភាពល្អក្នុងការដោះស្រាយបញ្ហាចំណាកស្រុកមិនស្របច្បាប់។ អនុស្សរណៈយោគយល់ (MoU) ចុះហត្ថលេខាដោយកម្ពុជា និងថៃក្នុងឆ្នាំ២០០៣ ជាករណីជាក់ស្តែងមួយនៃកិច្ចសហប្រតិបត្តិការដ៏សក្តិសិទ្ធិដើម្បីដោះស្រាយបញ្ហាចំណាកស្រុក។ ឯកសារនេះមានគោលដៅចម្បង ផ្តល់ជាក្របខ័ណ្ឌមួយសម្រាប់ការជ្រើសរើសពលរដ្ឋកម្ពុជាឲ្យទៅធ្វើការនៅថៃ ហើយក៏ព្យាយាមប្រែក្លាយពលករកម្ពុជាមិនស្របច្បាប់ ឲ្យទៅជាពលករស្របច្បាប់ដែរ។ រដ្ឋាភិបាលប្រទេសទាំងពីរបានរួមដៃគ្នាធ្វើការងារនេះ ដោយផ្តល់អត្តសញ្ញាណប័ណ្ណដល់ពលករមិនស្របច្បាប់ ហើយប័ណ្ណនេះអនុញ្ញាតឲ្យពលករ អាចដាក់ពាក្យសុំប័ណ្ណការងាររយៈពេល ២ឆ្នាំបាន។ កម្ពុជាក៏គួរស្នើដល់រដ្ឋាភិបាលម៉ាឡេស៊ី ឲ្យពិចារណាលើការផ្តល់សិទ្ធិស្របច្បាប់ ដល់ពលករកម្ពុជាមិនស្របច្បាប់ទាំងឡាយដែរ។

*ដំណើរបង្កើត ទីផ្សារពលកម្មមហាអនុតំបន់មេគង្គរួមគ្នា៖* ចលនាពលករ ឆ្លងកាត់ព្រំដែនពាសពេញមហាអនុតំបន់មេគង្គ (GMS) មានសន្ទុះខ្លាំង ដោយមានថៃជាគោលដៅទីផ្សារពលកម្មចម្បងមួយ ហើយកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ជាប្រភពនៃពលករគ្មានជំនាញ។ ទោះជាលំហូរពលកម្មក្នុងតំបន់មានទំហំធំ និងសារៈសំខាន់ខាងសេដ្ឋកិច្ចក្តី ប៉ុន្តែបច្ចុប្បន្នមិនទាន់មានបទបញ្ញត្តិសម្រាប់អនុតំបន់ ឬក្របខ័ណ្ឌស្ថាប័ន ដើម្បីសម្របសម្រួលចលនាពលកម្មនៅឡើយទេ។ GMS គួរធ្វើការងារសំដៅបង្កើតទីផ្សារពលកម្មរួមគ្នាមួយ។ គំនិតនេះអាចមានប្រយោជន៍ដល់គ្រប់ប្រទេសចូលរួម។ សម្រាប់ប្រទេសខ្វះពលកម្ម ដូចជា ថៃ ការមានទីផ្សារពលកម្មតំបន់រួមគ្នាមួយ អាចធានានូវការផ្គត់ផ្គង់ពលករយ៉ាងជាប់លាប់ និងអាចទុកចិត្តបាន ហើយកត្តានេះសំខាន់ខ្លាំងណាស់ សម្រាប់ការប្រកួតប្រជែងប្រកបដោយនិរន្តរភាព ក្នុងវិស័យអតិពលកម្មជាច្រើន។ សម្រាប់ប្រទេសសម្បូរពលកម្ម ដូចជា កម្ពុជា ចលនាពលករកាន់តែងាយស្រួល អាចបន្ថយនូវសម្ពាធនៃការអត់ការងារធ្វើ។ ជំហានដំបូង ដើម្បី

សម្រេចគោលដៅនេះ គឺត្រូវដាក់បញ្ចូលចំណាកស្រុកពលករទៅក្នុងរបៀបវារៈអភិវឌ្ឍន៍នៃ មហាអនុតំបន់មេគង្គ (GMS) ហើយបន្ទាប់មកបង្កើតវេទិកាអ្នកជំនាញ ដើម្បីសិក្សាពីភាពអាចធ្វើបាន និងផ្ដល់អនុសាសន៍ ដល់អ្នកដឹកនាំ។

*សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងចលនាពលកម្មដោយសេរី៖* ចំណាកស្រុកក្នុងអាស៊ាន បានកើនឡើងយ៉ាងគំហុក ប៉ុន្តែមិនទាន់មានក្របខ័ណ្ឌច្បាប់ ឬក្របខ័ណ្ឌស្ថាប័នថ្នាក់តំបន់នៅឡើយទេ។ រហូតដល់ឆ្នាំ២០០៧ ទើបមេដឹកនាំអាស៊ានចុះហត្ថលេខាលើសេចក្ដីប្រកាស ស្ដីពីការការពារ និងលើកកម្ពស់សិទ្ធិរបស់ពលករចំណាកស្រុក។ មានមនុស្សជាច្រើនគិតថា សេចក្ដីប្រកាសនេះ ជាជំហានទីមួយដ៏សំខាន់ដើម្បីឈានទៅដល់ការការពារ និងគោរពសិទ្ធិរបស់ពលករចំណាកស្រុកបានកាន់តែប្រសើរ ប៉ុន្តែការយឺតយ៉ាវក្នុងការតាក់តែងលិខិតុបករណ៍ក្របខ័ណ្ឌ បង្ហាញឲ្យឃើញថា អាស៊ានត្រូវតែបង្កើនល្បឿនអនុវត្តការប្ដេជ្ញាចិត្តរបស់ខ្លួនក្រោមសេចក្ដីប្រកាសនេះ។ អាស៊ានត្រូវអនុម័តគោលការណ៍ណែនាំ និងបទបញ្ញត្តិចាំបាច់នានា ព្រមទាំងបង្កើតយន្តការស្ថាប័ន ដើម្បីធានាបានការអនុវត្តដោយរលូន និងការតាមដានប្រកបដោយប្រសិទ្ធភាព។ លិខិតុបករណ៍ទាំងនេះ នឹងត្រូវដាក់បញ្ចូលក្នុងលិខិតុបករណ៍ក្របខ័ណ្ឌអាស៊ានដែលមានលក្ខណៈចងភ្ជាប់តាមផ្លូវច្បាប់។

## សេចក្ដីសន្និដ្ឋាន

ការវិភាគខាងលើបង្ហាញច្បាស់ថា ចំណាកស្រុកមិនស្របច្បាប់បានផុសឡើងជាបញ្ហាចំបងមួយ ក្នុងការគ្រប់គ្រងចំណាកស្រុកនៅកម្ពុជា។ ការដោះស្រាយចំណាកស្រុកនេះ ជាបញ្ហាអាទិភាពមួយផ្នែកគោលនយោបាយ ដោយត្រូវមានដំណោះស្រាយជារួម និងគ្រប់ជ្រុងជ្រោយ ទាក់ទិននឹងគោលនយោបាយ និងអន្តរាគមន៍ជាក់ស្ដែងនៅគ្រប់កម្រិតនៃចំណាកស្រុក ដែលអនុវត្តឡើងដោយអ្នកពាក់ព័ន្ធជាច្រើន។ ជោគជ័យនៃការគ្រប់គ្រងចំណាកស្រុកមិនស្របច្បាប់នៅកម្ពុជា ត្រូវពឹងផ្អែកមិនត្រឹមតែលើសមត្ថភាពរបស់ប្រទេសក្នុងការប្រែក្លាយ "ចំណាកស្រុកដើម្បីរស់រាន" ទៅជា "ចំណាកស្រុកជាជម្រើសមួយ" ប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាស្រ័យទៅលើដំណោះស្រាយរបស់អង្គការកម្រិតតំបន់ ដូចជា GMS និង អាស៊ាន និងរបស់សហគមន៍អន្តរជាតិទៀតផង។

## ឯកសារយោង


Battistella, Graziano (2002), "Unauthorized Migrants as Global Workers in the ASEAN Region", *Southeast Asian Studies* 40(3), pp. 350–371

Brennan, M. Ellen (1984), "Irregular Migration: Policy Responses in Africa and Asia", *International Migration Review* 18(3), pp. 409–425

Chan Sophal (2009), *Costs and Benefits of Cross-Country Labour Migration in the GMS: Cambodia Country Study*, Working Paper No.47 (Phnom Penh: CDRI)

Chiuri, M. Concetta, Giuseppe de Arcangelis & Giovanni Ferri (2005), *Crisis in Countries of Origin and Illegal Immigration into Europe via Italy* (Geneva: Global Commission on International Migration)

Global Commission on International Migration (2005), *Migration in an Interconnected World: New Directions for Action* (Geneva: Global Commission on International Migration)

Hing Vutha, Lun Pide & Phan Dalis (2011), "Labour Migration Situation and Policy Framework in Cambodia", *Annual Development Review 2010–2011*, pp. 83–102

International Council on Social Welfare (2007), *Trafficking and Related Labour Exploitation in the ASEAN Region* (Utrecht: ICSW)

International Labour Organisation (2010), *International Labour Migration: A Rights-based Approach* (Geneva: ILO)

International Organisation for Migration (2003), *Labour Migration in Asia: Trends, Challenges and Policy Responses in Countries of Origin* (Geneva: IOM)

Lee, L. Tang (2005), *Statelessness, Human Rights and Gender: Irregular Migrant Workers from Burma in Thailand* (Leiden: Koninklijke Brill NV)

LeVoy, Michele & Eve Geddie (2010), "Irregular Migration: Challenges, Limits and Remedies", *Refugee Survey Quarterly* 28(4), pp. 87–113

Marshall, Phil (2001), *Globalization, Migration and Trafficking: Some Thoughts from the South-East Asian Region,* (Kuala Lumpur: UN Inter-Agency Project on Trafficking in Women and Children in the Mekong Subregion)

MLVT (2010), *Policy on Labour Migration for Cambodia* (Phnom Penh: Ministry of Labour and Vocational Training)

Naro, Neth (2009), *Human Trafficking in Cambodia: Reintegration of the Cambodian Illegal Migrants from Vietnam and Thailand,* Working Paper No 181 (Singapore: S. Rajaratnam School of International Studies)

Paitoonpong, Srawooth and Chothiga Sakuruji (forthcoming), *Managing International Labour Migration in ASEAN* (Bangkok: Thailand Development Research Institute)

Shah, Nasra (2009), *The Management of Irregular Migration and Its Consequences for Development: Gulf Cooperation Council,* Working Paper No.19 (Bangkok: International Labour Organisation)

Stoyanova, Mariya (2008), *Challenges of Irregular Migration* (Geneva: Friedrich Ebert Stiftung)

UN General Assembly, "Resolution 3449: Measure to Ensure the Human Rights and Dignity of All Migrant Workers", http://www.un.org/documents/ga/res/30/ares30.htm (accessed 27 August 2010)

UNIAP (2010), *Human Trafficking Sentinel Surveillance: Poipet, Cambodia 2009-2010* (Bangkok: United Nations Inter-Agency Project on Human Trafficking)

# ការពិចារណាពីផលប៉ះពាល់នៃចំណាកស្រុក លើឪពុកម្ដាយវ័យជរា៖ ភស្តុតាងពីឃុំពីរ ក្នុងខេត្តបាត់ដំបង[១]

## សេចក្ដីផ្ដើម

លំហូរប្រជាជន ពីតំបន់ជនបទក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ទៅតំបន់ទីក្រុង និងឆ្លងកាត់ព្រំដែន ដើម្បីស្វែងរកការងារធ្វើជាសំខាន់ ជាផលវិបាកជៀសមិនផុតមួយនៃការអភិវឌ្ឍ និងដំណើរការសាកលភាវូបនីយកម្ម។ ចំណាកស្រុកកម្លាំងពលកម្មប្រភេទនេះ កើតមានឥតអាក់ និងកំពុងកើនសន្ទុះនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន រាប់បញ្ចូលទាំងកម្ពុជាផងដែរ (Chan 2008)។ ប៉ុន្តែបញ្ហាថា តើចំណាកស្រុកនេះមានផលប៉ះពាល់យ៉ាងណាទៅលើសមាជិកគ្រួសារ ព្រមទាំងចំណងសាមគ្គីភាពរវាងសមាជិកមួយជំនាន់ទៅមួយជំនាន់ទៀតនោះ កំពុងស្ថិតក្នុងការជជែកវែកញែកយ៉ាងខ្លាំងក្លា។ វេទិកាអន្តរជាតិនានាដែលធ្វើការតស៊ូមតិ និងរបាយការណ៍ក្នុងប្រព័ន្ធផ្សព្វផ្សាយ តែងមើលឃើញថា ចំណាកស្រុកធ្វើឲ្យខូចខាតដល់ក្រុមគ្រួសារ និងនាំឲ្យបាត់បង់ជំនួយទ្រទ្រង់ផ្នែកផ្លូវចិត្ត សង្គម និងសេដ្ឋកិច្ច និងបាត់បង់ការថែទាំឪពុកម្ដាយចាស់ជរា (Knodel *et al*. 2010)។ ចំណាកស្រុករបស់កូនប្រុសស្រីពេញវ័យក្មេងៗនៅតំបន់ជនបទ ធ្វើឲ្យឪពុកម្ដាយវ័យជរា ត្រូវមើលថែទាំខ្លួនដោយខ្លួនឯង ដូចមានចុះក្នុងឯកសារជាច្រើន ដែលសិក្សាពីចំណាកស្រុកនៅកម្ពុជា (FitzGerald *et al*. 2007; Murshid 2007)។

ក្នុងពេលជាមួយគ្នា ក៏មានទស្សនៈខ្លះទៀតដែលមើលឃើញមិនសូវអវិជ្ជមានទេនូវ ផលប៉ះពាល់នៃចំណាកស្រុកទៅលើក្រុមគ្រួសារក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ការសិក្សាជាច្រើនដែលគាំទ្រទស្សនៈនេះលើកថា ចំណាកស្រុកជាផ្នែកមួយនៃយុទ្ធសាស្ត្រគ្រួសារដើម្បីបំបែកបណ្ដុំហានិភ័យរបស់គ្រួសារ និងផ្ដល់ប្រយោជន៍ដល់ទាំងជនចំណាកស្រុក និងសមាជិកគ្រួសារមិនធ្វើចំណាកស្រុករបស់សាមីជន ក្នុងនេះមានទាំងឪពុកម្ដាយវ័យជរាដែលនៅឯក្រោយក្នុងស្រុកកំណើតផង។ ការសិក្សាទាំងនេះផ្ដោតលើការដោះដូរផ្នែកសេដ្ឋកិច្ច ជាជាងលើសកម្មភាពជួយឧបត្ថម្ភនានាដែលកូនៗតែងផ្ដល់ជូនឪពុកម្ដាយ ដូចជា ទំនាក់ទំនងក្នុងសង្គម ជំនួយឧបត្ថម្ភក្នុងការរស់នៅប្រចាំថ្ងៃ និងសេវាថែទាំសុខភាពជាដើម។ ទស្សនៈមួយដែលបានគិតគូរពីផលប៉ះពាល់ចម្រុះ និងផ្ដោតទូលំទូលាយលើការប្រែប្រួលរចនាសម្ព័ន្ធ និងទំនាក់ទំនងគ្រួសារ ក្នុងពេលដែលសង្គមផ្លាស់ប្ដូរពីទម្រង់កសិកម្ម ទៅជាឧស្សាហកម្ម ហើយបន្ទាប់មកទៅកាន់ទម្រង់ក្រោយឧស្សាហកម្ម ពោលគឺ "គ្រួសារធំទូលាយបែបថ្មី (modified extended family)" ។ ការវិវត្តមិនបានធ្វើឲ្យបាត់បង់ទំនាក់ទំនងគ្រួសារធំទូលាយនោះទេ ប៉ុន្តែបានធ្វើឲ្យផុសឡើងនូវទម្រង់បែបថ្មីមួយទៀត ដែលសមស្របទៅតាមកាលៈទេសៈផ្លាស់ប្ដូរថ្មី។ ផ្អែកលើទស្សនៈនេះ ភាពជឿនលឿននៃបច្ចេកវិទ្យា ជាពិសេសផ្នែកដឹកជញ្ជូន និងទូរគមនាគមន៍ ជួយឲ្យសមាជិកគ្រួសារអាចរក្សាទំនាក់ទំនងជិតស្និទ្ធ និងបំពេញកាតព្វកិច្ចចំពោះគ្នាបានខ្លះ ឬទាំងអស់ ក្នុងនេះមានទាំងកាតព្វកិច្ចមើលថែទាំឪពុកម្ដាយវ័យជរា ដែលកាលពីមុនត្រូវតែរស់នៅកន្លែងជិតៗគ្នាទើបអាចអនុវត្តបាន (Knodel *et al*. 2010)។

## សំណួរស្រាវជ្រាវ

ការស្រាវជ្រាវនេះ សំដៅដោះស្រាយសំនួរធំៗដូចតទៅ៖ តើចំណាកស្រុកពួកកូនពេញវ័យក្មេងៗ វាប៉ះពាល់ដូចម្ដេចខ្លះទៅលើសុខុមាលភាពរបស់ឪពុកម្ដាយវ័យជរានៅទីជនបទ? និង តើចំណាកស្រុកនេះប៉ះពាល់ដូចម្ដេច ទៅលើសាមគ្គីភាពសមាជិកគ្រួសារពីជំនាន់មួយទៅជំនាន់មួយ? ពិសេសទៅទៀត ការសិក្សានេះព្យាយាមពិនិត្យថា តើចំណាកស្រុកពួកកូនពេញវ័យក្មេងៗ វាបង្កជាការចាកចោល និងការមិនគិតគូរ ឪពុកម្ដាយវ័យជរា ឬយ៉ាងណា? តើមានការបំពេញកាតព្វកិច្ចចំពោះគ្នាប្រភេទអ្វីខ្លះ រវាងសមាជិកគ្រួសារជំនាន់ផ្សេងគ្នា ដែលត្រូវប្រែប្រួលខុសៗគ្នាទៅតាមទីតាំងរស់នៅរបស់កូនៗ? តើជនចំណាកស្រុក ហើយនិងឪពុកម្ដាយ នៅរក្សាទំនាក់ទំនងខាងសង្គមដែរឬទេ? និង តើការដោះដូរផ្នែកសម្ភារៈក្នុងអំឡុងពេលនៃការរស់នៅបែកគ្នានេះ បើកាត់កងគ្នាទៅវាអំណោយផលទៅខាងឪពុកម្ដាយ ឬខាងកូនៗ?

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ ធ្វើឡើងនៅខែមិថុនា ២០១០ ក្នុង ២ឃុំនៅខេត្តបាត់ដំបង។ ឃុំត្រែង ក្នុងស្រុករតនៈមណ្ឌល ស្ថិតនៅប៉ែកខាងលិចនៃខេត្ត នៅក្បែរប៉ុន្តែមិនជាប់ព្រំដែនថៃទេ។ ផ្លូវជាតិលេខ៦៧ ឆ្លងកាត់ឃុំនេះ ដោយតភ្ជាប់ទីរួមខេត្តបាត់ដំបង និងទីរួមខេត្តប៉ៃលិន។ ឃុំតាលាស់ ក្នុងស្រុកមោងឫស្សី ស្ថិតនៅប៉ែកអាគ្នេយ៍នៃខេត្តបាត់ដំបង ក្បែរផ្លូវជាតិលេខ៥ ដែលឆ្លងកាត់ខេត្តនេះពីភាគខាងជើងទៅភាគខាងត្បូង និងតភ្ជាប់ទីរួមខេត្តបាត់ដំបង ទៅរាជធានីភ្នំពេញ។ អង្កេតមួយបានធ្វើឡើងនៅ ៥ភូមិ ក្នុងឃុំត្រែង និងឃុំតាលាស់ លើអ្នកភូមិ ២៦៥នាក់ អាយុពី ៦០ ដល់ ៧០ឆ្នាំ ដែលមានកូនយ៉ាងហោចណាស់មួយនាក់

---

១ អត្ថបទនេះ រៀបចំដោយ ហាក់-សុចន្ទី អឿ-អ៊ីល សូ-ដាន ឃួន-ចាន់ដួរ ចិន-សុជឿន ហួន-កល្យាណ និង John McAndrew ដែលសុទ្ធតែជាសមាជិកនៃគម្រោងវិភាគបញ្ហាអភិវឌ្ឍន៍ (ADI) របស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា នៅពេលដែលការសិក្សាកំពុងដំណើរការ។ ក្រុមអ្នកស្រាវជ្រាវសូមថ្លែងអំណរគុណចំពោះការចូលរួមសហការរបស់ សាស្ត្រាចារ្យ Zachary Zimmer នៃ University of California ក្នុងក្រុង San Francisco និង សាស្ត្រាចារ្យ John Knodel នៃមជ្ឈមណ្ឌលសិក្សាពីប្រជាជន នៃ University of Michigan។ ការសិក្សានេះ ក៏ទទួលបានជំនួយទ្រទ្រង់ផងដែរពី Doha International Institute of Family Studies and Development។

**រូបភាព ១៖ គ្រួសារមនុស្សវ័យជរាមានកូនធ្វើចំណាកស្រុក និងកូនរស់នៅក្បែរ**




នៅរស់។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់ មានកូនសរុបចំនួន ១២៦៨នាក់។

## របៀបរបបរស់នៅរបស់ឪពុកម្ដាយ និងកូនៗ

ការសិក្សា បានកំណត់ជនចំណាកស្រុកជា កូនៗដែលបានចាកឆ្ងាយពីផ្ទះ និងទៅក្រៅស្រុកដែលឪពុកម្ដាយខ្លួនកំពុងរស់នៅ។ កូនៗដែលបន្តរស់នៅក្នុងស្រុកដើមរបស់ឪពុកម្ដាយខ្លួន បន្ទាប់ពីឪពុកម្ដាយបានផ្លាស់ទីមករស់នៅក្នុងភូមិសិក្សា គឺមិនត្រូវបានចាត់ទុកជាជនចំណាកស្រុកទេ។ ការសិក្សាបង្ហាញថា សមាជិកគ្រួសារដែលមានឪពុកម្ដាយវ័យជរា ជាទូទៅបានធ្វើចំណាកស្រុក មិនមែនរត់ចោលស្រុកនោះទេ។ គ្រួសារវ័យជរាដែលរាយការណ៍ថា មានកូនម្នាក់ធ្វើចំណាកស្រុក គឺមានភាគរយខ្ពស់ ហើយគ្រួសារវ័យជរាដែលប្រាប់ថាមានកូនម្នាក់នៅផ្ទះ មានចំនួនភាគរយកាន់តែខ្ពស់ជាងនោះទៀត។ មានអ្នកឆ្លើយសម្ភាសន៍ ជិតដល់ ៧០% មានកូនម្នាក់ធ្វើចំណាកស្រុក ហើយ ៨០% មានកូនម្នាក់រស់នៅជាមួយ។ ចំណុចនេះបង្ហាញថា កូនៗមិនបានទុកចោលឪពុកម្ដាយវ័យជរាឲ្យនៅឯកោទេ ទោះបីពួកខ្លួន មានអត្រាធ្វើចំណាកស្រុកកម្រិតខ្ពស់ក្ដី។ ឪពុកម្ដាយជំនាន់នេះ មានកូនច្រើនរហូតដល់ ៤,៨នាក់ជាមធ្យម ដែលអាចឲ្យកូនៗខ្លះធ្វើចំណាកស្រុក ហើយខ្លះទៀតនៅផ្ទះ ឬនៅភូមិ ជាមួយឪពុកម្ដាយបាន (រូបភាព ១)។

ការសិក្សា ក៏បានប្រៀបធៀបរបៀបរបបរស់នៅ របស់អ្នកឆ្លើយសម្ភាសន៍ ដែលមានកូនកំពុងធ្វើចំណាកស្រុកនាបច្ចុប្បន្ន និងអ្នកឆ្លើយសម្ភាសន៍ ដែលមិនមានកូនកំពុងធ្វើចំណាកស្រុក។ ប្រសិនបើឪពុកម្ដាយវ័យជរា ដែលមានកូនធ្វើចំណាកស្រុក ត្រូវទុកចោលឲ្យរស់នៅដោយឯកោនោះ យើងរំពឹងរកឃើញភាគរយខ្ពស់ នៃពួកអ្នកដែលត្រូវរស់នៅជាគ្រួសារ ដែលមិនមានកូនណាម្នាក់នៅជាមួយ ប៉ុន្តែជាក់ស្ដែងយើងមិនបានរកឃើញដូច្នេះទេ។ ជាង ៧៥% នៃអ្នកឆ្លើយសម្ភាសន៍ ដែលមានកូនកំពុងធ្វើចំណាកស្រុក គឺកំពុងរស់នៅជាមួយកូនមួយទៀត។ ចំណុចគួរឲ្យចាប់អារម្មណ៍គឺ អ្នកឆ្លើយសម្ភាសន៍ ដែលមានកូនកំពុងធ្វើចំណាកស្រុក មានអត្រារស់នៅឯកោទាបជាងអ្នកឆ្លើយសម្ភាសន៍ ដែលមិនមានកូនកំពុងធ្វើចំណាកស្រុក។ ប៉ុន្តែអត្រារស់នៅតែជាមួយប្ដី ឬប្រពន្ធ ឬចៅ នៃអ្នកឆ្លើយសម្ភាសន៍ដែលមានកូនកំពុងធ្វើចំណាកស្រុក ហាក់មានកម្រិតខ្ពស់ជាង អ្នកឆ្លើយសម្ភាសន៍ដែលមិនមានកូនធ្វើចំណាកស្រុក។ ទោះយ៉ាងនេះក្ដី តួលេខខុសគ្នាក្នុងករណីទាំងអស់នេះ មានកម្រិតទាបទេ (រូបភាព ២)។

## ផលប៉ះពាល់នៃចំណាកស្រុកទៅលើសុខុមាលភាពឪពុកម្ដាយ

គេតែងនិយាយថា ចំណាកស្រុករបស់កូនពេញវ័យក្មេងៗ នៅតំបន់ជនបទ ធ្វើឲ្យថយចុះសុខុមាលភាពរបស់ឪពុកម្ដាយវ័យជរា។ លទ្ធផលការសិក្សានេះ មិនបានគាំទ្រដល់ការយល់ឃើញដូចខាងលើទេ។ ជាទូទៅ ឪពុកម្ដាយវ័យជរាដែលមាន ឬមិនមាន កូនៗធ្វើចំណាកស្រុក មានស្ថានភាពប្រហាក់ប្រហែលគ្នា។ តួលេខមធ្យម (mean) នៃពិន្ទុទ្រព្យសម្បត្តិ ពិន្ទុលទ្ធភាពផ្នែករាងកាយ ពិន្ទុភាពពេញចិត្តក្នុងគ្រួសារ ពិន្ទុសុខុមាលភាពផ្លូវចិត្ត និងភាគរយអ្នកមានកំហិតក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ គឺសឹងតែដូចគ្នា។ ទន្ទឹមគ្នានេះ អត្រាគ្មានជំងឺនៃអ្នកឆ្លើយសម្ភាសន៍មានកូនកំពុងធ្វើចំណាកស្រុក ឃើញថាមានកម្រិតខ្ពស់ជាងអ្នកពុំមានកូនកំពុងធ្វើចំណាកស្រុក (តារាង ១)។

**រូបភាព ២៖ របៀបរបបរស់នៅរបស់អ្នកឆ្លើយសម្ភាសន៍មានវ័យជរា**



**តារាង ១៖ សូចនាករមួយចំនួននៃសុខុមាលភាពរបស់អ្នកឆ្លើយសម្ភាសន៍** (បែងចែកតាមស្ថានភាពចំណាកស្រុករបស់កូន។)

| | ស្ថានភាពចំណាកស្រុក | | |
|---|---|---|---|
| | មានកូនកំពុងធ្វើចំណាកស្រុក | មិនមានកូនកំពុងធ្វើចំណាកស្រុក | សរុប |
| ចំនួនករណី | 171 | 94 | 265 |
| ពិន្ទុទ្រព្យសម្បត្តិ[១] (មធ្យម=mean) | 4.8 | 4.6 | 4.8 |
| ភាគរយអ្នកគ្មានដីធ្លី | 36 | 21* | 31 |
| ពិន្ទុលទ្ធភាពផ្នែករាងកាយ[២] (មធ្យម) | 4.5 | 4.6 | 4.5 |
| ភាគរយអ្នកមានកំហិតក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ[៣] | 10 | 7 | 9 |
| ពិន្ទុភាពពេញចិត្តក្នុងគ្រួសារ[៤] (មធ្យម) | 7.4 | 7.5 | 7.4 |
| ពិន្ទុសុខុមាលភាពផ្លូវចិត្ត[៥] (មធ្យម) | 11.1 | 11.4 | 11.2 |

*កម្រិតសារៈសំខាន់៖ * = កម្រិត 0.0៥ ផ្អែកលើ chi-square test និង T-test*

*១. វាស់វែងតាមពិន្ទុសរុបនៃទ្រព្យក្នុងផ្ទះ ១៣មុខ បូកនឹង លក្ខណៈផ្ទះ ២យ៉ាង។*

*២. ពិន្ទុលទ្ធភាពផ្នែករាងកាយ ផ្អែកលើការយល់ឃើញរបស់អ្នកឆ្លើយសម្ភាសន៍លើរង្វាស់ ៣ គឺ៖ លទ្ធភាពដើរបាន ២០០ម៉ែត្រ លទ្ធភាពលើកបាវស្រូវទម្ងន់ ៥គីឡូក្រាម និង លទ្ធភាពថែទាំផ្ទះដោយមិនមានជំនួយពីអ្នកដទៃ។ ពិន្ទុខ្ពស់បំផុតគឺ ៦ និងទាបបំផុត គឺ ០។*

*៣. កំហិតក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ មានន័យថាអ្នកឆ្លើយសម្ភាសន៍ ឬ ប្តី/ប្រពន្ធគាត់ ត្រូវមានគេជួយមើលថែទាំ ដូចជាក្នុងការងូតទឹក និងស្លៀកពាក់ ជាដើម។*

*៤. ពិន្ទុភាពពេញចិត្តក្នុងគ្រួសារ ផ្អែកលើការយល់ឃើញរបស់អ្នកឆ្លើយសម្ភាសន៍អំពី ភាពចុះសម្រុងគ្នាក្នុងគ្រួសារ និងការពឹងពាក់គ្នាទៅវិញទៅមក ព្រមទាំងស្ថានភាពរស់នៅរបស់កូនៗគាត់។ ពិន្ទុខ្ពស់បំផុតគឺ ៩ និង ទាបបំផុតគឺ ៣។*

*៥. ពិន្ទុសុខុមាលភាពផ្លូវចិត្ត ផ្អែកលើការយល់ឃើញរបស់អ្នកឆ្លើយសម្ភាសន៍ លើរង្វាស់ចំនួន៦។ ពិន្ទុខ្ពស់បំផុតគឺ ១៨ និង ទាបបំផុតគឺ ៦។*

ចំណុចនេះគ្មានអ្វីគួរភ្ញាក់ផ្អើលទេ ព្រោះគ្រួសារគ្មានដីធ្លី តែងរងសម្ពាធខ្លាំងជាង ទើបអនុញ្ញាតឲ្យកូនៗធ្វើចំណាកស្រុកទៅរកការងារធ្វើ។

សមាមាត្រអ្នកឆ្លើយសម្ភាសន៍ ដែលមានកូនៗទាំងអស់ទៅរស់នៅក្រៅភូមិ (ដូច្នេះអាចចាត់ទុកថា រស់នៅឯកោ) មានតិចជាង ១០% ហើយភាគច្រើនក្រីក្រ និងគ្មានដីធ្លីទេ។ អត្រាគ្មានដីធ្លីរបស់ពួកគាត់ខ្ពស់ជាខ្លាំង ហើយពិន្ទុទ្រព្យសម្បត្តិ វាទាបជាខ្លាំង បើធៀបនឹងអ្នកឆ្លើយសម្ភាសន៍ដែលមានកូននៅជាមួយ (តារាង ២)។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ ២៣នាក់ ដែលប្រាប់ថា កូនៗទាំងអស់រស់នៅក្រៅភូមិ មាន ១៨នាក់ ជាស្ត្រី ហើយក្នុងនោះ ១៣នាក់ ជាស្ត្រីមេម៉ាយ។

## ការផ្គត់ផ្គង់សម្ភារៈ និងប្រាក់កាស

គេនិយាយថា ចំណាកស្រុកនៃកូនពេញវ័យក្មេងៗពីតំបន់ជនបទ បានទុកចោលឪពុកម្តាយវ័យជរាឲ្យនៅធ្វើការងារស្រែចំការដោយគ្មានអ្នកណាជួយ (Murshid 2007)។ ប៉ុន្តែភស្តុតាង

**តារាង ២៖ សូចនាករមួយចំនួននៃសុខុមាលភាពរបស់អ្នកឆ្លើយសម្ភាសន៍** (បែងចែកតាមចម្ងាយទីកន្លែងកូនរស់នៅជិតបំផុត)

| | ទីកន្លែងកូនរស់នៅជិតបំផុត | | |
|---|---|---|---|
| | ក្នុងផ្ទះរួមគ្នា | ក្នុងភូមិ | ក្រៅភូមិ |
| ចំនួនករណី | 212 | 30 | 23 |
| ពិន្ទុខាងទ្រព្យសម្បត្តិ (មធ្យម=mean) | 5.1 | 3.3 | 3.3*** |
| ភាគរយអ្នកឆ្លើយសម្ភាសន៍គ្មានដីធ្លី | 25 | 40 | 74*** |
| ពិន្ទុលទ្ធភាពផ្នែករាងកាយ (មធ្យម) | 4.5 | 4.7 | 4.6 |
| ភាគរយអ្នកមានកំហិតក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ | 9 | 13 | 4 |
| ពិន្ទុភាពពេញចិត្តក្នុងគ្រួសារ (មធ្យម) | 7.6 | 6.6 | 7.1*** |
| ពិន្ទុសុខុមាលភាពផ្លូវចិត្ត (មធ្យម) | 11.4 | 10.1 | 10.8** |

*កម្រិតសារៈសំខាន់៖ ** = កម្រិត 0,0១; *** = កម្រិត 0,0៥ ផ្អែកលើ chi-square test និង ANOVA test ។ សម្រាប់និយមន័យ សូមមើលតារាង១។*

**រូបភាព ៣៖ ការរួមចំណែករបស់កូនៗជួយដល់ឪពុកម្តាយ (បែងចែកតាមទីកន្លែងរស់នៅរបស់កូនៗ)**




*កំណត់សម្គាល់៖ កូនៗនៅរាជធានីភ្នំពេញ និងនៅប្រទេសក្រៅ ដែលបានជួយការងារអាជីវកម្ម ឬស្រែចំការជាទៀងទាត់ នៅឆ្នាំមុន មានភាគរយខ្ពស់ ដោយសារពួកគេទើបធ្វើចំណាកស្រុកថ្មីៗ មិនទាន់បានមួយឆ្នាំទេ។*

ជាក់ស្តែងដែលយើងរកឃើញ មិនបានគាំទ្រគំនិតនេះទេ។ ពិតហើយកូនៗដែលរស់នៅជាមួយ ឬនៅក្បែរឪពុកម្តាយ តែងជួយក្នុងការងារអាជីវកម្ម ឬស្រែចំការបានទៀងទាត់ជាង ប៉ុន្តែកូនៗដែលរស់នៅឆ្ងាយពីឪពុកម្តាយ តែងជួយជាប្រាក់កាសបានច្រើនឡើង។ ចំណុចនេះបង្ហាញថា កូនៗតែងរួមចំណែកជួយដល់ឪពុកម្តាយរបស់ខ្លួន តាមរូបភាពខុសៗគ្នា និងបំពេញឲ្យគ្នា ផ្អែកទៅតាមទីកន្លែងដែលពួកគេរស់នៅ។ កូនៗដែលរស់នៅជាមួយឪពុកម្តាយ ចូលរួមចំណែកជាការផ្តល់ជំនួយទៀងទាត់ក្នុងការងារស្រែចំការ និងអាជីវកម្ម។ ជំនួយប្រភេទនេះមានតម្លៃខ្លាំងណាស់ មិនគួរមើលស្រាលទេ។ កូនៗដែលធ្វើការនៅក្រៅស្រុក មិនថានៅក្នុង ឬក្រៅប្រទេសកម្ពុជានោះទេ តែងចូលរួមជួយឪពុកម្តាយតាមរយៈការផ្ញើប្រាក់ទៅផ្ទះ (រូបភាព ៣)។

## ទំនាក់ទំនងសង្គមរវាងឪពុកម្តាយ និងកូនៗ

ទំនាក់ទំនងសង្គមរវាងឪពុកម្តាយ និងកូនពេញវ័យក្មេងៗ មានតម្លៃណាស់នៅកម្ពុជា។ ចំណាកស្រុករបស់កូនៗ ទៅឆ្ងាយពីឪពុកម្តាយ បានកាត់បន្ថយឱកាសរក្សាទំនាក់ទំនងប្រចាំថ្ងៃ និងអាចធ្វើឲ្យខូចខាតដល់ តម្លៃសីលធម៌ខាងលើ។ ចំណាកស្រុកអាចរួមចំណែកជាវិជ្ជមានដល់ សុខុមាលភាពផ្នែកសេដ្ឋកិច្ចនៃ គ្រួសាររបស់ជនចំណាកស្រុកក៏ពិតមែន ប៉ុន្តែក៏អាចធ្វើឲ្យទំនាក់ទំនង រវាងឪពុកម្តាយ និងកូនៗ ចុះខ្សោយដែរ។ កាលពីមុន ឪពុកម្តាយ និងកូនៗដែលរស់នៅឆ្ងាយពីគ្នា តែងពិបាកទៅជួបសួរសុខទុក្ខគ្នាឲ្យបានទៀងទាត់ ឯការតភ្ជាប់នឹងបណ្តាញទូរស័ព្ទ ក៏គ្មានដែរ។ ប៉ុន្តែបច្ចុប្បន្នវត្តមាន និងការប្រើប្រាស់ជាទូទៅនូវ ទូរស័ព្ទចល័ត បានជួយសម្រួលយ៉ាងច្រើន ដល់ទំនាក់ទំនងរវាងឪពុកម្តាយ និងកូនៗ ដែលរស់នៅឆ្ងាយពីគ្នា។ ការសិក្សារកឃើញថា ភាគច្រើននៃកូនៗដែលរស់នៅស្រុកផ្សេងពី ឪពុកម្តាយខ្លួន ទាំងនៅក្នុង និងនៅក្រៅប្រទេសកម្ពុជា តែងទំនាក់ទំនងទូរស័ព្ទ ឬមកជួយឪពុកម្តាយខ្លួនយ៉ាងហោចណាស់ក៏មួយលើកក្នុងមួយខែដែរ។ ក្រុមទាំងពីរនេះ ពឹងផ្អែកលើការទាក់ទងគ្នាតាមទូរស័ព្ទខ្លាំងជាង លើការធ្វើដំណើរមកសួរសុខទុក្ខផ្ទាល់។ ទំនាក់ទំនងទាំងនេះ មានកម្រិតទាបបន្តិច ប៉ុន្តែក៏ប្រហាក់ប្រហែលគ្នានឹងកូនៗ ដែលរស់នៅក្នុងភូមិផ្សេងគ្នា ប៉ុន្តែនៅក្នុងស្រុកជាមួយគ្នានឹងឪពុកម្តាយ ពោលគឺ កូនៗដែលនៅក្នុងការសិក្សានេះ គេមិនបានចាត់ទុកថាជា ជនចំណាកស្រុក (រូបភាព ៤)។

## ការដោះដូរផ្នែកសម្ភារៈ និងប្រាក់កាស

ការដោះដូរ ផ្នែកជំនួយទ្រទ្រង់ និងសេវាផ្សេងៗ រវាងឪពុកម្តាយ និងកូនៗដែលធ្វើចំណាកស្រុក អាចកើតមានក្នុងទិសណាមួយ ឬមិនដែលកើតមានសោះ។ ឪពុកម្តាយតែងផ្តល់ជំនួយទ្រទ្រង់ដល់កូនៗដែលធ្វើចំណាកស្រុក ជាពិសេសជួយចេញចំណាយផ្សេងៗ ក្នុងដំណាក់កាលដំបូងៗនៃចំណាកស្រុក។ ក្នុងចំណោមកូនៗ ៣៨៤នាក់ ដែលធ្វើចំណាកស្រុកបានចាប់ពីមួយឆ្នាំឡើងទៅមាន ៤៨% បានទទួលជំនួយពីឪពុកម្តាយសម្រាប់ការចំណាយក្នុងពេលធ្វើចំណាកស្រុក ហើយ ៥៦% បានផ្តល់ជំនួយហិរញ្ញវត្ថុដល់ឪពុកម្តាយជាទៀងទាត់។ ម៉្យាងទៀត

**រូបភាព ៤៖ កូនៗនៅក្រៅភូមិបន្តរក្សាទំនាក់ទំនងជាមួយឪពុកម្តាយយ៉ាងហោចណាស់ម្តងក្នុងមួយខែ**



**រូបភាព ៥៖ ទិសនៃជំនួយឧបត្ថម្ភរវាងកូនៗចំណាកស្រុក និងឪពុកម្តាយ**




៥៥% នៃកូនៗ ២៥៦នាក់ ដែលធ្វើចំណាកស្រុករយៈពេល ១ឆ្នាំ បានចូលរួមចេញថ្លៃថ្នាំសង្កូវឲ្យឪពុកម្តាយខ្លួន។

មានកូនៗដែលធ្វើចំណាកស្រុក ៤២% បានប្រាប់ថាខ្លួនបានជួយឧបត្ថម្ភដល់ឪពុកម្តាយជាស្បៀងអាហារ ប្រាក់កាស និងទ្រព្យសម្បត្តិផ្សេងៗ ច្រើនជាងជំនួយឧបត្ថម្ភដែលខ្លួនបានទទួលពីឪពុកម្តាយ និងមាន ៣៣% បានប្រាប់ពីស្ថានភាពផ្ទុយពីនេះ។ ចំពោះបញ្ហាថា តើអ្នកណាទទួលបានអត្ថប្រយោជន៍ច្រើនជាងនោះ ការសិក្សានេះបង្ហាញថា មានការប្រែប្រួលខុសគ្នាខ្លាំងទៅតាមស្ថានភាពជាក់ស្តែង ប៉ុន្តែជារួម គឺមានលំហូរជំនួយជាវិជ្ជមានទៅខាងឪពុកម្តាយច្រើនជាង។ គួរកត់សម្គាល់ថា កូនស្រីចំណាកស្រុកដែលបានរួមចំណែកក្នុងលំហូរជាវិជ្ជមាននេះ មានអត្រាខ្ពស់ខ្លាំងជាងកូនប្រុសចំណាកស្រុក (រូបភាព ៥)។

## សេចក្តីសន្និដ្ឋាន

ការសិក្សានេះបង្ហាញថា ជាទូទៅចំណាកស្រុកនៃកូនៗពេញវ័យក្មេងៗនៅកម្ពុជា មានឥទ្ធិពលវិជ្ជមានលើសុខុមាលភាពរបស់ឪពុកម្តាយវ័យជរា គឺផ្ទុយពីទស្សនៈថា វាមានផលប៉ះពាល់អវិជ្ជមានទាំងខាងសង្គម និងខាងសេដ្ឋកិច្ចទៅលើឪពុកម្តាយវ័យជរា។ ចំនួនមធ្យមកម្រិតខ្ពស់នៃកូនៗនៅរស់ របស់អ្នកឆ្លើយសម្ភាសន៍ ជួយឲ្យពួកគាត់ទទួលបានជំនួយឧបត្ថម្ភបំពេញគ្នាពីកូនៗដែលស្នាក់នៅជាមួយគាត់ កូនៗដែលស្នាក់នៅក្បែរៗនោះ និងកូនៗចំណាកស្រុក។ ស្រដៀងគ្នានេះដែរ ចំណាកស្រុកនៃកូនៗពេញវ័យ មិនមានជះឥទ្ធិពលអវិជ្ជមានលើសាមគ្គីភាពរវាងសមាជិកគ្រួសារមានអាយុជំនាន់ខុសគ្នានោះទេ។ ទូរស័ព្ទចល័តអាចឲ្យឪពុកម្តាយ និងកូនៗចំណាកស្រុក រក្សាទំនាក់ទំនងសង្គមរវាងគ្នាបាន។ ចំណុចនេះជួយគាំទ្រដល់គំនិតថា ចំណងទាក់ទង "គ្រួសារធំទូលាយបែបថ្មី" កំពុងផុសឡើងរវាងឪពុកម្តាយវ័យជរា និងកូនៗចំណាកស្រុក នៅកម្ពុជា។

ជាទូទៅ ការសិក្សានេះបានរកឃើញផលប៉ះពាល់ជាវិជ្ជមាននៃចំណាកស្រុកចំពោះឪពុកម្តាយវ័យជរា ប៉ុន្តែក៏នៅមានក្តីបារម្ភមួយដែរ។ អ្នកឆ្លើយសម្ភាសន៍ដែលមានកូនៗទាំងអស់នៅក្រៅភូមិ មានមិនដល់ ១០% ទេ ប៉ុន្តែពួកគាត់ភាគច្រើនជាជនក្រីក្រគ្មានដីធ្លី។ ពួកគាត់មានអត្រាគ្មានដីធ្លីខ្ពស់ជាខ្លាំង និងអត្រាទ្រព្យសម្បត្តិជាមធ្យម ទាបជាខ្លាំង បើធៀបនឹង អ្នកដែលមានកូនរស់នៅជាមួយ។ គោលនយោបាយ និងកម្មវិធីនានារបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកាត់បន្ថយ ឥទ្ធិពលអវិជ្ជមាននៃចំណាកស្រុក គួរផ្តោតលើជនក្រីក្រទាំងនេះ។

ការសិក្សា បង្ហាញពីសាមគ្គីភាពពីជំនាន់មួយទៅជំនាន់មួយ រវាងឪពុកម្តាយ និងកូនៗចំណាកស្រុក និងមិនធ្វើចំណាកស្រុក ប៉ុន្តែរឿងនេះ បានកើតមានឡើងក្នុងបរិបទរួមនៃភាពក្រីក្រ។ ឪពុកម្តាយវ័យជរា មិនមានទ្រព្យសម្បត្តិច្រើនទេ ហើយប្រសិនបើមិនមានការចូលរួមជួយពីកូនៗនោះ ទ្រព្យរបស់ពួកគាត់ ប្រហែលមាន កាន់តែតិចជាងនេះទៀត។ ដូច្នេះកូនៗ អាចមានតួនាទីសំខាន់ក្នុងការកាត់បន្ថយផលប៉ះពាល់ នៃភាពក្រីក្រនៅជនបទ ប៉ុន្តែភាពក្រីក្រនៅតែឃើញមាន។ ឱកាសចំណាកស្រុកអាចជួយដល់ឪពុកម្តាយវ័យជរាជាច្រើននៅតំបន់ជនបទ តាមរយៈជំនួយឧបត្ថម្ភពីកូនៗចំណាកស្រុក ប៉ុន្តែមានបញ្ហាមួយដែលត្រូវយកចិត្តទុកដាក់។ គ្រួសារដែលមានកូនតិច និងនិន្នាការថយចុះទំហំគ្រួសារទៅថ្ងៃអនាគត អាចមានផលប៉ះពាល់លើការផ្តល់ជំនួយឧបត្ថម្ភពីសមាជិកគ្រួសារមួយជំនាន់ទៅមួយជំនាន់ទៀត។

## ឯកសារយោង


Chan S. (2008), "The Political Economy of Managing Labour Migration", *Cambodia Development Review*, Volume 12, Issue 1, pp. 1-4

FitzGerald, I., So S., Chan S., Kem S. & Tuot S. (2007), *Moving Out of Poverty: Trends in Community Well-being and Household Mobility in Nine Cambodian Villages* (Phnom Penh: Cambodia Development Research Institute)

Knodel, J., J. Kespichayawattana, C. Saengtienchai & S. Wiwatwanich, (2010), "How Left Behind are Rural Parents of Migrant Children: Evidence from Thailand", *Ageing and Society*, Volume 30, Issue 5, pp. 811-841

Murshid, K.A.S. (2007), "Chapter 7: Domestic and Cross-border Migration from the Tonle Sap", in Brett M. Ballard (ed.), *We Are Living with Worry All the Time: A Participatory Poverty Assessment of the Tonle Sap* (Phnom Penh: Cambodia Development Research Institute)

# ការពង្រីកផលចំណេញ ការត្រៀមរៀបចំសម្រាប់ការផ្លាស់ប្ដូរកម្លាំងពលកម្ម និងពិពិធកម្មនៅកម្ពុជា

*"ការអប់រំ ធ្វើឲ្យប្រជាជនមានភាពប្រសប់ និងអាចស្វែងរកចម្លើយដើម្បីដោះស្រាយបញ្ហាផ្ទាល់ខ្លួន... វាជាគ្រឹះនៃសន្តិភាព និងការអភិវឌ្ឍ។"*

*ឯកឧត្ដម ប៉ក់ ថាវិន*
*អគ្គនាយក នៃអគ្គនាយកដ្ឋានឧត្ដមសិក្សា*
*នៃក្រសួងអប់រំ យុវជន និងកីឡា*

## ការបង្កើនផលិតភាពក្នុងទីផ្សារពលកម្មនៅកម្ពុជា

កម្ពុជាមានប្រជាជនវ័យក្មេងយ៉ាងច្រើន ដែលសកម្ម និងធ្វើការផ្លាស់ទីចុះឡើង។ បើសិនមានគោលនយោបាយសមស្របទ្រព្យសំណាងជាប្រជាជននេះ អាចក្លាយជាសម្បត្តិដ៏ស្ដុកស្ដម្ភសម្រាប់ជំរុញ និងធ្វើពិពិធកម្មកំណើនសេដ្ឋកិច្ច។

កម្លាំងពលកម្មរបស់កម្ពុជា ជាធាតុផ្សំយ៉ាងសំខាន់ក្នុងដំណើរផ្លាស់ប្ដូរនៅក្នុងសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន។ តាំងពីដើមរៀងមក ថ្លៃពលកម្មទាប ជាកត្តាដ៏សំខាន់សម្រាប់ទាក់ទាញវិនិយោគទុនបរទេស ជាពិសេស ក្នុងវិស័យកម្មន្តសាល។ វិនិយោគនេះ បានផ្ដល់ការងាររាប់ពាន់ ព្រមទាំងជាឈ្នាន់មួយសម្រាប់ការឈានឡើងផ្នែកឧស្សាហកម្ម។

ពិតហើយ ពលកម្មតម្លៃទាបមានផលប្រយោជន៍ខ្លាំងណាស់សម្រាប់កម្ពុជា ប៉ុន្ដែការពង្រឹងផលចំណេញទាំងនេះ និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ត្រូវមានការជំរុញជាគោលនយោបាយរួមមួយពីសំណាក់រដ្ឋាភិបាល។ គន្លឹះសំខាន់ គឺសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការ ផ្ដល់កម្លាំងពលកម្មមានជំនាញដ៏ចំបាច់សម្រាប់ជំរុញពិពិធកម្ម ព្រមទាំងពង្រឹងវិស័យជាប្រពៃណី ដូចជា ទេសចរណ៍ និងផ្នែកកាត់ដេរ ជាដើម។

មានវិស័យស្នូល និងឧបសគ្គជាច្រើន ដែលគោលនយោបាយរដ្ឋាភិបាលត្រូវផ្ដោតលើជាអាទិភាព។ ទិដ្ឋភាពចំបងមួយនៃពិពិធកម្មកំណើន គឺការបង្កើនផលិតភាពពលកម្មក្នុងវិស័យកសិកម្ម ដែលនឹងជះឥទ្ធិពលជំរុញផលិតកម្មកសិកម្ម ព្រមទាំងជួយរំដោះកម្លាំងពលកម្មលើសតម្រូវការ ចេញពីវិស័យកសិកម្មឲ្យចូលបម្រើក្នុងឧស្សាហកម្ម និងសេវាកម្ម ដែលមានផលិតភាពខ្ពស់ជាង។

ដើម្បីប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព នូវផលិតភាពជាសក្ដានុពលនៃ កម្លាំងពលកម្មច្រើនលើសតម្រូវការក្នុងវិស័យកសិកម្ម ព្រមទាំងទ្រព្យសំណាងជាប្រជាជននេះ រដ្ឋាភិបាលត្រូវបង្កើនសមត្ថភាពវិស័យអប់រំ និងប្រព័ន្ធបណ្ដុះបណ្ដាលវិជ្ជាជីវៈនាពេលបច្ចុប្បន្នរបស់កម្ពុជា ។ ក្របខណ្ឌទាំងនេះ ត្រូវផ្ដល់ការអប់រំមានគុណភាពល្អដល់សិស្ស-និស្សិតជាច្រើនប្រភេទ និងកសាងសមត្ថភាពជំនាញដ៏ចាំបាច់ សម្រាប់ជំរុញសេដ្ឋកិច្ចកម្ពុជាទៅមុខ។

## ផលិតភាពពលកម្មក្នុងវិស័យកសិកម្ម

ការពិនិត្យជារួមបង្ហាញច្បាស់ថា របាយកម្លាំងពលកម្មនៅកម្ពុជាមិនទាន់មានប្រសិទ្ធភាពល្អគ្រប់គ្រាន់ទេ ហើយបញ្ហាចោទសំខាន់ គឺផលិតភាពពលកម្មនៅជនបទ។

ដោយសារកម្លាំងពលកម្មភាគច្រើន បម្រើការងារក្នុងវិស័យកសិកម្ម ដូច្នេះការរួមចំណែករបស់ពួកគេនៅក្នុង ផសស មិនបានគួរឲ្យពេញចិត្តទេ។ នៅឆ្នាំ២០០៨ វិស័យកសិកម្មប្រើប្រាស់ដល់ ៧២% នៃកម្លាំងពលកម្មសរុបនៅកម្ពុជា ប៉ុន្ដែរួមចំណែកបានត្រឹម ៣៣% នៃ ផផស ប៉ុណ្ណោះ។ ផ្ទុយទៅវិញ ប្រជាជន ៨,៦% ធ្វើការនៅក្នុងវិស័យឧស្សាហកម្ម ដែលរួមចំណែកបាន ២២,៤% នៃ ផសស រីឯវិស័យសេវាកម្មផ្ដល់ការងារដល់មនុស្ស ១៩,៣% ហើយរួមចំណែកបាន ៣៨,៨% នៃ ផសស ។

ការរួមចំណែកក្នុងមនុស្សម្នាក់ គិតក្នុងមួយឯកតាកំណើន ផសស មានលក្ខណៈមិនស្មើគ្នាទេរវាងវិស័យនានា

**រូបភាព ១៖ ការរួមចំណែកក្នុងមនុស្សម្នាក់ គិតក្នុងមួយឯកតាកំណើន ផសស**




*ប្រភព៖ ទិន្នន័យស្រង់ចេញពីបទបង្ហាញរបស់ ឯកឧត្ដមបណ្ឌិត ហេង សួ ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា នៅថ្ងៃទី ១៦ មីនា ២០១១*

១ អត្ថបទនេះ គឺជាការបោះពុម្ពសាជាថ្មីនៃសង្ខេបចក្ខុវិស័យប្រទេសកម្ពុជា ដែលរៀបរៀងដោយ Benjamin C. R. Flower ផ្អែកលើបទបង្ហាញក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១១ បកស្រាយដោយឯកឧត្ដមបណ្ឌិត ហេង សួ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លោកស្រី Sandra D'Amico នាយកគ្រប់គ្រងនៃក្រុមហ៊ុន HR Inc. កម្ពុជា និងជានាយករងនៃសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) ឯកឧត្ដម ប៉ក់ ថាវិន អគ្គនាយក នៃអគ្គនាយកដ្ឋានឧត្ដមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា។

(រូបភាព ១)។ គេឃើញច្បាស់ថា ពលករក្នុងវិស័យកសិកម្មមានផលិតភាពតិចជាងពលករក្នុងវិស័យឧស្សាហកម្ម (វិស័យមានផលិតភាពខ្ពស់បំផុត) និងពលករក្នុងវិស័យសេវាកម្ម។

ជាការឆ្លើយតប រាជរដ្ឋាភិបាលបានផ្តោតកម្លាំងលើការបង្កើនផលិតភាពពលកម្មក្នុងកសិកម្ម ដោយធ្វើការផ្សព្វផ្សាយពីជំនាញបច្ចេកទេសថ្មីៗ និងផ្តល់ការបណ្តុះបណ្តាលដល់កម្លាំងពលកម្មនៅជនបទ។ ចរិកាជាតិ បានជួយទ្រទ្រង់យ៉ាងច្រើនដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលកសិកម្មខេត្ត ដើម្បីផ្តល់កម្មវិធីបណ្តុះបណ្តាលអំពីវិធីសាស្ត្រដាំដុះ ផលិតកម្មជី ការរក្សាទុកផលក្រោយពេលប្រមូលវាបាន ការដាំដំណាំចម្រុះ និងជំនាញមូលដ្ឋាននៃសហគ្រិន។

គម្រោងជាក់លាក់ជាច្រើន បានអនុវត្តរបៀបវារៈនៃការកសាងសមត្ថភាពនេះ។ គម្រោងទាំងនេះ រួមមាន មូលនិធិបណ្តុះបណ្តាលថ្នាក់ជាតិដើម្បីកាត់បន្ថយភាពក្រីក្រ ផ្តល់ដោយមន្ទីរជំនាញខេត្តនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) ការបណ្តុះបណ្តាលពិសេសសម្រាប់ជនជាតិដើមភាគតិច និងមូលនិធិបណ្តុះបណ្តាលពិសេសរបស់សម្តេចតេជោ។

ធនធានរបស់ដៃគូអភិវឌ្ឍន៍នានា ក៏ត្រូវបានប្រមែប្រមូលដើម្បីដោះស្រាយ បញ្ហាកម្លាំងពលកម្មជនបទគ្មានជំនាញគ្រប់គ្រាន់នេះដែរ។ ក្នុងបញ្ហានេះ ADB លេចធ្លោជាពិសេសតាមរយៈការងារក្នុងគំនិតផ្តួចផ្តើម GMS របស់ខ្លួន។ គម្រោងនានា រួមមាន កម្មវិធីបណ្តុះបណ្តាល VSTP (Voucher Skill Training Programme) កម្មវិធីបច្ចេកវិទ្យាក្រោយប្រមូលផល និង ស្ពានចម្លងបន្តជំនាញ និងគម្រោងពង្រឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទៅដល់កម្លាំងពលកម្មជនបទ។

ការបង្កើនផលិតភាពពលកម្មកសិកម្ម គួរមានបំពេញបន្ថែមដោយគោលនយោបាយប្រើប្រាស់ផលិតភាពជាសក្តានុពល នៃកម្លាំងពលកម្មច្រើនលើសតម្រូវការនៅទីជនបទ។ សកម្មភាពរបស់រដ្ឋាភិបាល ក្នុងការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងសមត្ថភាពនៃវិស័យអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការត្រៀមរៀបចំពលករ គឺមានសារៈសំខាន់បំផុត។ មានតែវិធីសាស្ត្រពីរនេះប៉ុណ្ណោះ ដែលអាចដោះស្រាយបញ្ហារបាយកម្លាំងពលកម្មគ្មានប្រសិទ្ធភាពនេះ ដោយការបង្កើនផលិតភាពក្នុងមនុស្សម្នាក់ក្នុងវិស័យកសិកម្ម និងការបណ្តុះបណ្តាលកម្លាំងពលកម្មច្រើនលើសតម្រូវការ ដើម្បីត្រៀមខ្លួនពលករឲ្យចូលបម្រើការក្នុងវិស័យសេវាកម្ម ឬឧស្សាហកម្ម។

## ការពង្រីកលទ្ធភាពទទួលបានការអប់រំ និងការកសាងសមត្ថភាពក្នុងវិស័យអប់រំ

កង្វះខាតជំនាញនៅក្នុងទីផ្សារពលកម្មរបស់កម្ពុជា ត្រូវតែដោះស្រាយជាចាំបាច់ ដើម្បីកសាងកម្លាំងពលកម្មដែលអាចសម្របខ្លួន អាចបត់បែនបាន និងមានផលិតភាពខ្ពស់ ហើយអាចឆ្លើយតបទៅនឹងតម្រូវការពិពិធកម្មសេដ្ឋកិច្ច។ ចំណុចសំខាន់ គឺត្រូវលើកកម្ពស់ស្តង់ដារនៃការអប់រំ និងពង្រីកលទ្ធភាពទទួលបានការអប់រំ ជាពិសេសក្នុងចំណោមក្រុមជនដែលមានអ្នកតំណាងតិច។

ទាក់ទិននឹងចំណុចខ្វះខាតក្នុងប្រព័ន្ធអប់រំ អង្កេតពីបរិយាកាសវិនិយោគឆ្នាំ២០០៧ របស់ធនាគារពិភពលោក រកឃើញថា និយោជក ១៥,៥% បានចាត់ទុកជំនាញ និងការអប់រំ ជាឧបសគ្គធ្ងន់ធ្ងរ ឬធ្ងន់ធ្ងរខ្លាំង ចំពោះប្រតិបត្តិការ និងកំណើនអាជីវកម្មរបស់ពួកគេ។ ក្រុមហ៊ុនខ្នាតធំ ១៨,៨% ខ្នាតមធ្យម ២១,៨% និងខ្នាតតូច ១២,៨% ប្រាប់ថា កង្វះខាតពលករមានជំនាញច្បាស់លាស់ ជាបញ្ហាធំចំពោះពួកគេ ហើយក្រុមហ៊ុនបរទេស ២២% និងក្រុមហ៊ុនក្នុងស្រុក ១៣,៥% ក៏យល់ឃើញដូច្នេះដែរ។ ការវាយតម្លៃរហ័សមួយនាពេលថ្មីៗនេះ ដោយក្រុមហ៊ុន HR Inc. បានផ្តល់ទិន្នន័យបឋមគាំទ្រដល់ការសិក្សាឆ្នាំ២០០៧ ខាងលើ។ កង្វះខាតជំនាញក្នុងចំណោមថ្នាក់គ្រប់គ្រងជាន់ខ្ពស់ (៦៤%) ថ្នាក់គ្រប់គ្រងកណ្តាល (៤៨%) និងបុគ្គលិកជំនាញ (៥០%) ជាឧបសគ្គចំបងចំពោះកំណើនរបស់ក្រុមហ៊ុន។

រដ្ឋាភិបាល បានកំណត់កំណែទម្រង់វិស័យអប់រំ ជាអាទិភាពមួយសម្រាប់ដោះស្រាយបញ្ហានេះ។ យុទ្ធសាស្ត្រចតុកោណ ជំហានទី១ និងទី២ និង ផែនការយុទ្ធសាស្ត្រនៃការអប់រំ (ESP) មានទិសដៅជំរុញ កំណើនសេដ្ឋកិច្ច កំណើនការងារ ការកែលម្អគុណភាព និងការអភិវឌ្ឍធនធានមនុស្ស ព្រមទាំងបង្កើតកិច្ចសហការជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ក្នុងវិស័យអប់រំកម្រិតខ្ពស់។

កន្លងមកវិស័យឯកជន ជាកម្លាំងជំរុញចំបងនៅក្នុងកំណើនដ៏ឆាប់រហ័សនៃចំនួនស្ថាប័នអប់រំកម្រិតខ្ពស់ (HEIs) នៅកម្ពុជា។ ចំនួន HEIs កើនឡើងយ៉ាងកំហុគពីប្រមាណ ១០ស្ថាប័ន ក្នុងទសវត្សរ៍១៩៩០ ដល់ ៩០ស្ថាប័ន ក្នុងឆ្នាំ២០១១ ដោយបានបណ្តុះបណ្តាលនិស្សិតជាង ១៩៥.០០០នាក់ ក្នុងនោះមាន ៣៧% ជានិស្សិតនារី។ ស្ថាប័នទាំងនេះសំខាន់ខ្លាំងណាស់សម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច វប្បធម៌ និងសិល្បៈនៅកម្ពុជា។

ចំនួន HEIs បាននិងកំពុងកើនឡើងយ៉ាងខ្លាំង ប៉ុន្តែនៅមានបញ្ហាជាច្រើនដែលត្រូវដោះស្រាយ ដើម្បីធានាឲ្យវិស័យនេះមានកំណើនប្រកបដោយនិរន្តរភាព ហើយអាចជួយអភិវឌ្ឍកម្លាំងពលកម្មបានលទ្ធផលប្រសើរបំផុត។ បញ្ហាចំបង គឺបទបញ្ញត្តិ និងគុណភាពអប់រំដែលស្ថាប័នទាំងនេះផ្តល់ឲ្យ។ HEIs ភាគច្រើននៅទាបជាងស្តង់ដារអន្តរជាតិនៅក្នុងវិស័យសំខាន់ៗ ដូចជាការស្រាវជ្រាវ អភិបាលកិច្ច និងការបង្រៀន។ ជាបន្ថែមលើកំហិតខាងសមត្ថភាពស្ថាប័ន នៅមានកង្វះសម្ភារៈសម្រាប់បង្រៀន និងស្រាវជ្រាវ ដូចជា សៀវភៅបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) ទំនើប និងមន្ទីរពិសោធន៍ ។ល។

មានបញ្ហាជាច្រើន ទាក់ទិននឹងលទ្ធភាពទទួលបានការអប់រំនៅ HEIs។ អត្រាចុះឈ្មោះចូលរៀនមានភាពខុសគ្នាជាខ្លាំងរវាងប្រជាជននៅជនបទ នឹងនៅទីក្រុង។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៩-២០១៣ ព្យាយាមដោះស្រាយបញ្ហាទាំងនេះ ដោយផ្តោតទៅលើទាំងសមត្ថភាព និងដែនគ្រប់ដណ្តប់នៃ HEIs ។ កំណើនលទ្ធភាពទទួលបានការអប់រំជាន់ខ្ពស់ នឹងត្រូវជំរុញឡើងតាមការផ្តល់អាហារូបករណ៍ដល់ក្រុមដែលមានអ្នកតំណាងតិច (ឧ. ជនក្រីក្រ នារី ជនជាតិដើមភាគតិច) និងសិស្សឆ្នើម។ គុណភាពនៃការបង្រៀន ការរៀនសូត្រ និងការស្រាវជ្រាវក្នុងការអប់រំកម្រិតខ្ពស់ នឹងបានប្រសើរឡើង តាមរយៈការធ្វើបច្ចុប្បន្នភាពវិធីសាស្ត្របង្រៀន (ឧទាហរណ៍ ការប្រើប្រាស់ ICT) ការអភិវឌ្ឍកម្មវិធីអប់រំ និងការបំពាក់គ្រឿងសម្រួលការនៅតាម HEIs ដែលអាចឆ្លើយតបនឹងតម្រូវការនៃការបង្រៀន ការសិក្សា និងការស្រាវជ្រាវ។ រដ្ឋាភិបាលនឹងផ្តោតលើ ភាសាអង់គ្លេស គណិតវិទ្យា និងវិទ្យាសាស្ត្រ ដែលនឹងផ្តល់ផលចំណេញខ្ពស់ ទាំងសម្រាប់ការរកការងារធ្វើរបស់បុគ្គល និងការអភិវឌ្ឍសេដ្ឋកិច្ចជាទូទៅ។

ក្រៅពីការកសាងសមត្ថភាពស្ថាប័ននៃ HEIs រដ្ឋាភិបាលគួរផ្តោតផងដែរ លើការរៀបចំបទបញ្ញត្តិឲ្យបានសមស្រប។

ក្រមសីលធម៌ ស្តង់ដារ និងប្រព័ន្ធទទួលស្គាល់គុណភាពសមស្រប និងផ្តល់ការលើកទឹកចិត្តឲ្យ HEIs ធ្វើការកែលម្អ និងផ្តល់ព័ត៌មានច្រើនជាងមុនដល់និយោជក និងសិស្ស-និស្សិត អំពីខ្លឹមសារ និងគុណភាពនៃសញ្ញាប័ត្ររបស់ស្ថាប័នខ្លួន។

ការពង្រឹងសមត្ថភាពផ្តល់ការអប់រំនៅក្រៅ HEIs ក៏សំខាន់ដែរ ព្រោះការចេះអាន ចេះសរសេរ ចេះគិតលេខ ការដោះស្រាយបញ្ហា ការសម្រេចចិត្ត និងជំនាញសម្រាប់ការងារទូទៅ គឺជាចំណុចខ្សោយដែលនៅលេចធ្លោនៅឡើយ។ គោលនយោបាយកម្លាំងពលកម្ម គួរមានរួមបញ្ចូលការអប់រំកម្រិតបឋម និងមធ្យម ដែលសំខាន់បំផុតសម្រាប់ផ្តល់ឲ្យកម្លាំងពលកម្មនូវសមត្ថភាពជំនាញ និងចំណេះដឹងជាមូលដ្ឋាន ដែលបង្កើនឱកាសឱ្យពួកគេរកបានការងារតាំងពីវ័យក្មេង។

ប្រព័ន្ធអប់រំកម្រិតបឋម និងមធ្យម នៅមានទិដ្ឋភាពជាច្រើនដែលរារាំងដល់ការអភិវឌ្ឍកម្លាំងពលកម្មទោះបីបានរីកលូតលាស់ច្រើនណាស់ហើយក្តី។ ពេលនេះចាំបាច់ត្រូវមានធ្វើវិនិយោគច្រើនលើការកសាងសមត្ថភាពគ្រូបង្រៀន ដូចជា ការផ្តល់ការបណ្តុះបណ្តាល សម្ភារៈ និងលក្ខខណ្ឌពលកម្មឲ្យបានគ្រប់គ្រាន់។

អាហាររូបត្ថម្ភគ្រប់គ្រាន់ ក៏ជាគន្លឹះជួយឲ្យសិស្ស-និស្សិតក្រីក្រដកខ្លួនឲ្យផុតពីអន្ទាក់វិលវង់នៃភាពក្រីក្រ ហើយប្រើប្រាស់សក្តានុពលរបស់ខ្លួនឲ្យអស់លទ្ធភាព និងទទួលបានអត្ថប្រយោជន៍កាន់តែច្រើន ពីវិនិយោគក្នុងទិដ្ឋភាពផ្សេងៗទៀតនៃប្រព័ន្ធអប់រំ។ ក្រសួងសុខាភិបាល ក៏បានបង្ហាញពីបញ្ហាខ្វះវីតាមីន (ដូចជា វីតាមីនD) ក្នុងចំណោមប្រជាជនទូទៅ ដែលបានប៉ះពាល់យ៉ាងខ្លាំងដល់សមត្ថភាពសិក្សារបស់សិស្ស-និស្សិត។

ការផ្តោតកម្លាំងផ្តល់ការអប់រំកម្រិតបឋម និងមធ្យម ដល់ប្រជាជនក្រីក្របំផុតក្នុងសង្គម អាចជួយកាត់បន្ថយភាពក្រីក្រ និងរួមចំណែកជំរុញកំណើនប្រកបដោយនិរន្តរភាព។ ធនាគារពិភពលោក បានចាប់អនុវត្តហើយ នូវគម្រោងផ្តល់ប្រាក់មានលក្ខខណ្ឌ (Conditional Cash-Transfer) ដើម្បីជួយបង្កើនលទ្ធភាពទទួលបានការអប់រំ។ ក្របខ័ណ្ឌគោលនយោបាយបែបនេះ គួរតែពង្រីកបន្ថែម។

## ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបំពេញតម្រូវការនៃពិពិធកម្មសេដ្ឋកិច្ច

ឧបសគ្គចំបងរារាំងដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅកម្ពុជា គឺភាពមិនស៊ីគ្នា រវាងជំនាញដែលវិស័យឯកជនត្រូវការ និងជំនាញដែលប្រព័ន្ធអប់រំ ជាពិសេសស្ថាប័នអប់រំកម្រិតខ្ពស់ (HEIs) ផ្តល់ឲ្យ។ បញ្ហានេះកើតមានជាក់ស្តែងទាក់ទិននឹងសមត្ថភាពជំនាញវិជ្ជាជីវៈ និងអាជីពជាក់លាក់ ដែលប្រភេទឧស្សាហកម្មមួយចំនួនត្រូវការ។

អង្កេតទីផ្សាររបស់ មជ្ឈមណ្ឌលសម្រាប់ការបណ្តុះបណ្តាលពីប្រព័ន្ធព័ត៌មាន (CSIT) មួយ ស្តីពីវិស័យបច្ចេកវិទ្យាព័ត៌មាន (IT) បានបង្ហាញពីភាពមិនស៊ីគ្នា រវាងជំនាញដែលមានក្នុងទីផ្សារពលកម្ម និងតម្រូវការរបស់និយោជក។ វិស័យ IT នៅកម្ពុជាមានលក្ខណៈសម្គាល់មួយ គឺការងារភាគច្រើនមានតម្លៃបន្ថែមទាប ដែលត្រូវការតែសមត្ថភាពជំនាញមូលដ្ឋានប៉ុណ្ណោះ។ ទោះយ៉ាងនេះក្តី អ្នកបម្រើការងារនេះជាង ៥៥% មានដល់សញ្ញាប័ត្រជាន់ខ្ពស់ផ្នែកវិស្វកម្ម ឬសញ្ញាប័ត្រថ្នាក់អនុបណ្ឌិត (រូបភាព ២)។ ជំនាញកំពុងមានតម្រូវការនេះ គឺអាចផ្តល់ឲ្យបានយ៉ាងងាយតាមរយៈវគ្គបណ្តុះបណ្តាលបច្ចេកទេស និងជំនាញ។ ចំណុចនេះបានចោទបញ្ហាដល់ការរក្សាទុកបុគ្គលិក ដោយសារអ្នកមានជំនាញខ្ពស់ទទួលបានត្រឹមតែការងារមានជំនាញទាប។

ការបណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ និងការអប់រំ (TVET) ជាគោលនយោបាយកម្លាំងពលកម្មដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាល ដើម្បីកែតម្រូវបញ្ហានេះ ដោយកសាងទីផ្សារពលកម្មរបស់កម្ពុជា តាមរយៈការអភិវឌ្ឍសមត្ថភាពជំនាញដែលនិយោជកត្រូវការ។ គំនិតផ្តួចផ្តើមចំបងៗ រួមមាន របៀបវារៈកំណែទម្រង់នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) ការបង្កើតទីភ្នាក់ងារជាតិ មុខរបរ និងការងារ (NEA) និងកម្មវិធីពង្រឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (STVET) ផ្តល់មូលនិធិដោយ ADB ។

កម្មវិធី STVET ផ្តោតលើការអប់រំផ្នែកយន្តសាស្ត្រ សំណង់ ICT និងទេសចរណ៍។ កម្មវិធីនេះ ក៏បានអភិវឌ្ឍសមត្ថភាពកម្លាំងពលកម្មនៅក្រៅតំបន់ទីប្រជុំជនដែរ។ កម្មវិធី STVET មានផែនការលើកកម្ពស់គុណភាពមជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត ចំនួន ៥ ឲ្យក្លាយជាមជ្ឈមណ្ឌលបណ្តុះបណ្តាលភូមិភាគ ដោយមជ្ឈមណ្ឌលនីមួយៗមានជំនាញជាក់លាក់រៀងខ្លួន ដែលផ្តល់អត្ថប្រយោជន៍ដល់ភូមិភាគនោះ។

ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ជួយដល់ STVET តាមរយៈការជួយសម្របសម្រួល ឲ្យមានការប្រាស្រ័យទាក់ទងកាន់តែប្រសើររវាង និយោជក ពលករ និងអ្នកផ្តល់ការបណ្តុះបណ្តាល។ ជាពិសេសទីភ្នាក់ងារនេះ ជួយផ្តល់ការណែនាំ និងពិគ្រោះយោបល់អំពី អាជីព និងបើកដំណើរការមជ្ឈមណ្ឌលការងារ សម្រាប់ជួយគាំទ្រកម្លាំងពលកម្មនៅជនបទ។ វត្តមាន STVET និង NEA ទាំងពីរនេះ ធានាឲ្យមានការបណ្តុះបណ្តាលស្របតាមតម្រូវការរបស់និយោជក និងមានការផ្សព្វផ្សាយជំនាញសមស្របទៅក្នុងទីផ្សារពលកម្ម។

ចំពោះ TVET គេឃើញមានបញ្ហាប្រឈមជាច្រើន ហើយធំបំផុត គឺចំណាប់អារម្មណ៍ក្នុងសង្គមដែលថា វគ្គអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ TVET គឺសម្រាប់បុគ្គលិកសាមញ្ញ មិនមែនសម្រាប់អ្នកវិជ្ជាជីវៈទេ។ ពួកសិស្ស-និស្សិត ក៏ទទួល

**រូបភាព២៖ សមត្ថភាពនយោជិតមានតម្លៃបន្ថែមទាបផ្នែក** IT




*ប្រភព៖ បទបង្ហាញរបស់លោកស្រី D'Amico ក្នុងសន្នសីទចក្ខុវិស័យ ប្រទេសកម្ពុជា ថ្ងៃទី១៦ មីនា ២០១១*

*តទៅទំព័រ ១៨*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះ ពិពណ៌នាពីសូចនាករសេដ្ឋកិច្ចពិភពលោក និង សេដ្ឋកិច្ចនៅអាស៊ីខាងកើត។

## កំណើនសេដ្ឋកិច្ចពិភពលោក

បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី អាស៊ីអាគ្នេយ៍ និង អាស៊ីខាងកើត បន្តនាំមុខក្នុងការងើបឡើងវិញ ស្របពេលដែល ប្រទេសឧស្សាហកម្មធំៗ កំពុងប្រឹងងើបឡើងវិញនៅឡើយពី វិបត្តិសេដ្ឋកិច្ចនេះ ដែលធ្ងន់ធ្ងរបំផុតចាប់តាំងពីមហាវិបត្តិក្នុង ទសវត្សរ៍១៩៣០ នោះមក។ ចំណាយប្រើប្រាស់ផ្នែកឯកជន កំពុងទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច ខណៈដែលអន្តរាគមន៍ផ្នែក សារពើពន្ធ និងរូបិយវត្ថុ បាននិងកំពុងមានភាពប្រក្រតីឡើងវិញ។ ទោះយ៉ាងនេះក្ដី កំណើនសេដ្ឋកិច្ចពិភពលោកជារួមមានល្បឿន យឺតជាងកាលពីមួយឆ្នាំមុន។

ក្នុងត្រីមាសទី១ ឆ្នាំ២០១១ ផសស ពិតរបស់ឥណ្ឌូនេស៊ី កើន ៦,៥% ធៀបនឹងឆ្នាំមុន ស្របពេលដែលវៀតណាម កើន ៥,៤% ប៉ុន្តែ ផសស ពិតរបស់ម៉ាឡេស៊ី សិង្ហបុរី និងថៃ បានធ្លាក់ចុះ។ ផសស របស់ម៉ាឡេស៊ី មានកំណើន ៤,៦% រីឯសិង្ហបុរី មាន ៨,៣%។ កំណើន ផសស នៅថៃ បន្តធ្លាក់ចុះ ដល់ ៣% ដោយសារជាសំខាន់មកពីវិបត្តិនយោបាយក្នុងស្រុក ដែលកំពុងបន្តកើតមាន និងជម្លោះព្រំដែនជាមួយកម្ពុជា។ ទោះជាមានកំណើនយឺតជាងកាលពីមួយឆ្នាំមុនក្ដី ចិន នៅតែ ទទួលបានលទ្ធផលល្អ ដោយមានកំណើន ផសស ៩,៧%។ កំណើន ផសស នៅហុងកុង មានកម្រិត ៧,២% ចំណែកឯ កូរ៉េខាងត្បូង មាន ៤,២%។

សេដ្ឋកិច្ចរបស់ប្រទេសឧស្សាហកម្មធំៗ ចាប់ផ្ដើមងើប ឡើងវិញក៏ពិតមែន ប៉ុន្តែពួកគេកំពុងប្រឹងប្រែងនៅឡើយដើម្បី ឡើងឲ្យដល់កម្រិតដូចនៅមុនពេលមានវិបត្តិ។ នៅត្រីមាសទី១ ឆ្នាំ២០១១ អត្រាកំណើន ផសស ក្នុងប្រទេសប្រើប្រាស់អឺរ៉ូទាំង ១២ កើនដល់ ២,៥% ធៀបនឹងឆ្នាំមុន ស្របពេលដែល ផសស នៅសហរដ្ឋអាមេរិក មានកំណើន ២,៣%។ ក្នុងត្រីមាសនេះដែរ ការធ្លាក់ចុះសេដ្ឋកិច្ចកំពុងគំរាមកំហែងប្រទេសជប៉ុន ដោយសារ ការរញ្ជួយដីដ៏ធំដែលបានបំផ្លិចបំផ្លាញប្រទេសនេះកាលពីខែមីនា ធ្វើឲ្យស្លាប់មនុស្សរាប់ពាន់នាក់ និងខូចខាតរោងចក្រនុយក្លេអ៊ែរ មួយកន្លែងទៀត។ កង្វល់អំពីការលេចធ្លាយជាតិវិទ្យុសកម្ម បានប៉ះពាល់ធ្ងន់ធ្ងរដល់ចំណាយប្រើប្រាស់ក្នុងស្រុក និងជញ្ជីង ពាណិជ្ជកម្មរបស់ជប៉ុន។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

ទោះមានការងើបឡើងវិញក្ដី ក៏សេដ្ឋកិច្ចពិភពលោកនៅតែ ប្រឈមនឹងបញ្ហាបន្ទាន់មួយ គឺអតិផរណាបន្តនៅខ្ពស់ដដែល។ នៅត្រីមាសទី១ ឆ្នាំនេះ នៅបណ្ដាប្រទេសមានសេដ្ឋកិច្ចធំៗក្នុង ពិភពលោក អតិផរណាបានកើនឡើង បើធៀបនឹងកាលពី មួយឆ្នាំមុន។ ពួកអ្នករៀបចំគោលនយោបាយក្នុងប្រទេសកំពុង អភិវឌ្ឍន៍នៅអាស៊ី ក៏ត្រូវប្រយ័ត្នប្រយែងចាត់វិធានការដើម្បីទប់ ស្កាត់អតិផរណាផងដែរ។

នៅត្រីមាសទី១ ឆ្នាំនេះ អតិផរណា នៅឥណ្ឌូនេស៊ី កើន ៦,៨% ធៀបនឹងឆ្នាំមុន ហើយនៅសិង្ហបុរី កើន ៥,២%។ ដោយសារគោលនយោបាយពង្រីកហិរញ្ញវត្ថុ ប្រទេសវៀតណាម កំពុងបន្តប្រយុទ្ធនឹងអតិផរណាកម្រិតខ្ពស់ដល់ ១២,៨%។ ចំណែកឯប្រទេសកម្ពុជា និងថៃ គឺអាចរក្សាបាននូវអត្រា អតិផរណាសមរម្យ ត្រឹម ៣,៦% និង ៣,០%។ អត្រាអតិផរណា នៅបណ្ដាប្រទេសអាស៊ីខាងកើត បន្តកើនឡើងនៅត្រីមាសទី១ ឆ្នាំ២០១១ បើធៀបនឹងកាលពីមួយឆ្នាំមុន។ អត្រាអតិផរណា នៅចិន កើនដល់ ៥,១% ហុងកុង ដល់ ៤,០% និង កូរ៉េខាង ត្បូង ៤,៤%។ ក្នុងពេលជាមួយគ្នា ប្រទេសប្រើប្រាស់អឺរ៉ូទាំង១២ មានកំណើនអតិផរណាដល់ ២,៥% ស្របពេលដែលអតិផរណា នៅសហរដ្ឋអាមេរិក ធ្លាក់ចុះបន្តិចមកត្រឹម ២,១% និងនៅជប៉ុន មានអត្រាស្មើសូន្យ។

នៅត្រីមាសទី១ ឆ្នាំ២០១១ អត្រាប្ដូរប្រាក់របស់ប្រទេស នៅអាស៊ីអាគ្នេយ៍ភាគច្រើន ក្រៅពីវៀតណាម បានកើនឡើង ធៀបនឹងដុល្លារអាមេរិក។ ប្រាក់រៀល ឡើងថ្លៃ ៣,៣% ដល់ ៤០៤១,៩រៀល/ដុល្លារUS ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ី ឡើង ៤% ដល់ ៨៩០២,០២រូពីយ៉ា/ដុល្លារUS ប្រាក់រីងហ្គីតម៉ាឡេស៊ី ឡើងថ្លៃ ៩,៥% ដល់ ៣,០៥រីងហ្គីត/ដុល្លារUS ប្រាក់ដុល្លារ សិង្ហបុរី ឡើងថ្លៃ ៨,៦% ដល់ ១,២៨ដុល្លារសិង្ហបុរី/ដុល្លារUS និងប្រាក់បាតថៃ ឡើងថ្លៃ ៧,១% ដល់ ៣០,៥៦បាត/ដុល្លារUS។ ប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ៧,៦% រហូតដល់ ២០.២៧៣ដុង/ ដុល្លារUS។ ក្នុងរយៈដូចគ្នានេះ អត្រាប្ដូរប្រាក់អឺរ៉ូ នៅថេរធៀប នឹងដុល្លារអាមេរិក ខណៈពេលដែលប្រាក់យេនជប៉ុន ឡើងថ្លៃ ៩,២% ដល់ ៨២,៣យេន/ដុល្លារUS។

## ថ្លៃទំនិញក្នុងទីផ្សារពិភពលោក

ថ្លៃទំនិញសំខាន់ៗក្នុងទីផ្សារពិភពលោក បន្តកើនឡើងនៅ ត្រីមាសទី១ ឆ្នាំនេះ បើធៀបនឹងកាលពីមួយឆ្នាំមុន។ ភាពតានតឹង នៅមជ្ឈិមបូព៌ា និងវិបត្តិនុយក្លេអ៊ែរនៅជប៉ុន បានរួមចំណែកដល់ ការរំពឹងទុកអំពីការឡើងថ្លៃប្រេងកាន់តែខ្ពស់។ ពោត (USNo.2) ឡើងថ្លៃ ៧២% ដល់ ២៨០,៣២ដុល្លារ/តោន ប្រេងដូង (north-west) ឡើងថ្លៃ ៥៥% ដល់ ១២៥១ដុល្លារ/តោន និងជ័រកៅស៊ូ (SMR 5) ឡើងថ្លៃ ៧០% ដល់ ៥២៧៨,០៣ដុល្លារ/តោន។ ក្នុងរយៈពេលដូចគ្នា ប្រេងឆៅ (OPEC spot) ឡើងថ្លៃ ៣៣% ដល់ ១០០,៧ដុល្លារ/ធុង សាំង (US Gulf Coast) ឡើងថ្លៃ ២៦% ដល់ ០,៦៨ដុល្លារ/លីត្រ និងប្រេងម៉ាស៊ូត (low sulphur No.2) ឡើងថ្លៃ ៣៥% ដល់ ០,៧៣ដុល្លារ/លីត្រ។ អង្ករ (Thai 100% B) ធ្លាក់ថ្លៃ ៦,៦% មកត្រឹម ៥២៨,២៥ដុល្លារ ក្នុងមួយតោន។

---

១ អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវនៅ វិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១១ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2006 | 2007 | 2008 | 2009 | | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.6 | 10.2 | 6.8 | - | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.4 | 6.3 | 6.1 | 4.4 | 3.9 | 4.2 | 5.4 | 5.7 | 6.2 | 5.8 | 6.9 | 6.5 |
| ម៉ាឡេស៊ី | 5.9 | 6.3 | 4.6 | -6.2 | -3.9 | -1.2 | 4.5 | 16.9 | 8.9 | 5.3 | 4.8 | 4.6 |
| សិង្ហបុរី | 7.7 | 7.7 | 1.1 | -10.1 | -3.5 | 0.8 | 4.0 | 17.4 | 18.7 | 10.5 | 12.0 | 8.3 |
| ថៃ | 4.8 | 4.9 | 2.6 | -7.1 | -4.9 | -2.8 | 5.8 | 12.0 | 9.2 | 6.7 | 3.8 | 3.0 |
| វៀតណាម | 8.1 | 8.5 | 6.2 | - | - | - | - | 5.8 | 6.4 | 7.2 | 7.3 | 5.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 10.5 | 11.9 | 9.0 | 6.1 | 7.9 | 9.1 | 10.7 | 11.9 | 10.3 | 9.7 | 9.8 | 9.7 |
| ហុងកុង | 6.6 | 6.4 | 2.4 | -7.8 | -3.8 | -2.2 | 2.6 | 8.0 | 6.5 | 6.8 | 6.2 | 7.2 |
| កូរ៉េខាងត្បូង | 5.0 | 4.9 | 2.2 | -4.4 | -2.2 | 0.4 | 6.1 | 8.1 | 7.1 | 4.5 | 4.8 | 4.2 |
| តៃវ៉ាន់ | 4.6 | 5.2 | 0.1 | -10.2 | -7.5 | -1.3 | 8.4 | 14.6 | 12.9 | 9.8 | 6.9 | 6.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.7 | 2.9 | 0.9 | -2.5 | -4.8 | -4.7 | 0.1 | 0.6 | 1.7 | 1.9 | 2.0 | 2.5 |
| ជប៉ុន | 2.1 | 2.0 | -0.7 | -9.1 | 0.6 | -4.7 | -1.4 | 5.5 | 3.5 | 5.0 | 2.2 | -1.0 |
| សហរដ្ឋអាមេរិក | 3.3 | 2.2 | 1.1 | -2.6 | -3.9 | -2.5 | 2.6 | 2.8 | 2.9 | 2.3 | 2.8 | 2.3 |

*Sources: International Monetary Fund, Economist and countries' statistic offices.*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១១ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.7 | 10.5 | 19.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 | 4.1 | 1.8 | 3.3 | 3.6 |
| ឥណ្ឌូនេស៊ី | 13.4 | 6.4 | 10.1 | 8.5 | 5.6 | 2.78 | 2.6 | 3.6 | 4.4 | 6.2 | 6.3 | 6.8 |
| ម៉ាឡេស៊ី | 3.7 | 2.0 | 5.3 | 3.7 | 1.3 | -2.23 | -0.2 | 1.3 | 1.6 | 1.9 | 2.1 | 2.8 |
| សិង្ហបុរី | 1.0 | 2.1 | 6.5 | 2.1 | -0.5 | -0.4 | -0.3 | 0.9 | 3.1 | 3.4 | 4.0 | 5.2 |
| ថៃ | 4.7 | 2.2 | 5.5 | -0.2 | -2.8 | -2.1 | 1.9 | 3.7 | 3.3 | 3.3 | 2.0 | 3.0 |
| វៀតណាម | 7.7 | 8.3 | 23.3 | 15.1 | 6.2 | 2.6 | 4.6 | 7.5 | 9.0 | 8.4 | 10.9 | 12.8 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 1.5 | 4.8 | 5.9 | -0.6 | 1.5 | -1.26 | 0.7 | 2.1 | 2.7 | 3.3 | 4.7 | 5.1 |
| ហុងកុង | 2.2 | 2.0 | 4.3 | 1.7 | -0.1 | -0.9 | 1.3 | 1.9 | 2.6 | 2.3 | 2.9 | 4.0 |
| កូរ៉េខាងត្បូង | 2.4 | 2.5 | 4.6 | 3.9 | 2.8 | 2.0 | 2.4 | 2.7 | 2.6 | 2.9 | 3.6 | 4.4 |
| តៃវ៉ាន់ | 0.6 | 1.8 | 3.2 | 0.0 | -0.8 | -1.3 | -1.3 | 1.3 | 1.1 | 0.4 | 1.1 | 1.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.1 | 3.3 | 1.0 | 0.9 | -0.34 | 0.4 | 1.1 | 1.5 | 1.7 | 2.0 | 2.5 |
| ជប៉ុន | 0.5 | 0.1 | 1.4 | -0.1 | -1.0 | -2.2 | -2.0 | -1.2 | -0.9 | -0.9 | 0.1 | 0.0 |
| សហរដ្ឋអាមេរិក | 3.2 | 2.9 | 3.8 | -0.2 | -0.9 | -1.6 | 1.4 | 2.3 | 1.8 | 1.2 | 1.3 | 2.1 |

*Sources: International Monetary Fund, Economist and National Institute of Statistics.*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4103.20 | 4062.70 | 4054.20 | 4128.60 | 4164.40 | 4163.10 | 4180.11 | 4209.02 | 4236.69 | 4122.58 | 4041.90 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9134.00 | 9419.00 | 9699.00 | 10,225.00 | 9887.00 | 9472.44 | 9266.93 | 9,132.00 | 8995.11 | 8965.70 | 8902.02 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.70 | 3.30 | 3.30 | 3.50 | 3.50 | 3.40 | 3.37 | 3.24 | 3.15 | 3.11 | 3.05 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.59 | 1.51 | 4.58 | 1.45 | 1.44 | 1.39 | 1.40 | 1.36 | 1.36 | 1.30 | 1.28 |
| ថៃ (បាត) | 37.90 | 32.22 | 33.36 | 33.98 | 33.96 | 33.30 | 32.90 | 32.33 | 31.63 | 29.99 | 30.56 |
| វៀតណាម (ដុង) | 15,994.00 | 16,030.00 | 16,382.00 | 17,801.00 | 17,841.00 | 18,472.00 | 18,825.67 | 18,993.00 | 19,485.00 | 19499.48 | 20273.83 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ន់) | 7.97 | 8.03 | 6.94 | 6.83 | 6.83 | 6.83 | 6.83 | 6.77 | 6.77 | 6.66 | 6.58 |
| ហុងកុង (ដុល្លារហុងកុង) | 7.77 | 7.80 | 7.78 | 7.75 | 7.75 | 7.75 | 7.76 | 7.78 | 7.77 | 7.76 | 7.79 |
| កូរ៉េខាងត្បូង (វ៉ុន) | 955.00 | 929.04 | 1137.23 | 1273.90 | 1239.04 | 1167.77 | 1143.97 | 1166.04 | 1182.41 | 1132.85 | 1120.19 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.50 | 32.85 | 31.54 | 33.10 | 32.77 | 32.29 | 31.93 | 31.90 | 31.90 | 30.36 | 29.30 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.70 | 0.84 | 0.71 | 0.70 | 0.68 | 0.72 | 0.79 | 0.77 | 0.74 | 0.73 |
| ជប៉ុន (យ៉េន) | 116.40 | 117.80 | 102.46 | 95.95 | 93.58 | 89.78 | 90.73 | 92.20 | 85.74 | 82.53 | 82.33 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៦-២០១១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - USA (USD/តោន) | 111.04 | 149.08 | 218.15 | 171.16 | 146.85 | 168.13 | 162.88 | 157.41 | 176.13 | 238.81 | 280.32 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 433.85 | 707.68 | 912.23 | 719.35 | 659.16 | 732.33 | 807.67 | 813.00 | 874.67 | 1108.00 | 1251.00 |
| កៅស៊ូ SMR 5 | 1996.30 | 2202.30 | 2586.30 | 1638.77 | 1924.80 | 2536.03 | 3105.90 | 3083.73 | 3175.97 | 4257.27 | 5278.03 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 282.00 | 305.36 | 615.32 | 499.45 | 307.31 | 569.00 | 565.67 | 461.33 | 468.33 | 531.00 | 528.25 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 213.88 | 294.59 | 460.41 | 420.10 | 411.18 | 390.43 | 372.68 | 370.95 | 406.88 | 480.24 | 537.24 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 61.58 | 69.25 | 95.44 | 57.46 | 68.32 | 73.86 | 75.73 | 77.00 | 74.91 | 84.17 | 100.70 |
| សាំង - US Gulf Coast (សេន/លីត្រ) | 47.70 | 53.58 | 62.22 | 43.11 | 46.92 | 49.64 | 53.87 | 54.43 | 51.54 | 57.23 | 67.92 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 51.35 | 55.51 | 76.20 | 40.51 | 46.46 | 51.03 | 53.87 | 55.13 | 53.64 | 61.68 | 72.47 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

វិស័យសេវាកម្ម បន្តរួមចំណែកយ៉ាងសំខាន់ក្នុងដំណើររើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា។ នៅត្រីមាសទី១ ឆ្នាំ២០១១ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ខាងសេវាកម្ម អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង ១៣៤% ធៀបនឹងឆ្នាំមុន ដល់ ២០៩,៥លានដុល្លារ។ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ខាងសណ្ឋាគារ និងទេសចរណ៍ កើន ២៧៥៥% ដល់ ១០៧,៩លានដុល្លារ។ ភ្ញៀវទេសចរបរទេសមកដល់កម្ពុជា កើនឡើងទាំងតាមផ្លូវអាកាស (១៥%) ផ្លូវគោក និងផ្លូវទឹក (១២%)។ វិនិយោគខាងវិស័យកសិកម្ម ធ្លាក់ចុះ ៩៨% មកត្រឹម ៤,១លានដុល្លារ ខណៈដែលវិនិយោគខាងវិស័យឧស្សាហកម្ម ធ្លាក់ចុះ ៧៣% មកត្រឹម ៦៧,១លានដុល្លារ។ ទោះយ៉ាងនេះក្ដី វិនិយោគក្នុងវិស័យកាត់ដេរបង្ហាញសញ្ញាងើបឡើងវិញ ដោយកើន ១៣៤% ដល់ ៥៧,១លានដុល្លារ។ វិស័យសាងសង់ កំពុងងើបឡើងវិញដែរ ដោយតម្លៃនៃការសាងសង់ផ្ទះល្វែង កើនឡើង ៤៥% ដល់ ១៦,១លានដុល្លារ ប៉ុន្តែតម្លៃនៃការសាងសង់ផ្ទះវីឡា និងផ្ទះធម្មតា ធ្លាក់ចុះ ២០% មកត្រឹម ៤,១លានដុល្លារ ស្របពេលដែលសំណង់ផ្សេងៗទៀតធ្លាក់ចុះ ៣៣% មកត្រឹម ៤៣,៨លានដុល្លារ។

នៅត្រីមាសទី១ ឆ្នាំ២០១១ ការនាំចេញសរុប កើនឡើង ៤១% ធៀបនឹងត្រីមាសទី១ឆ្នាំមុន ដល់១០១៧,៧លានដុល្លារ ដោយក្នុងនេះ ការនាំចេញសំលៀកបំពាក់ មាន ៨៧%។ សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក នៅតែជាទិសដៅនាំចេញដ៏ចម្បងដដែល ប៉ុន្តែកំណើនការនាំចេញទៅសហរដ្ឋអាមេរិក (២២%) វាទាបជាងទៅសហភាពអឺរ៉ុប (៦៩%) អាស៊ាន (៧៣%) ជប៉ុន (៧៣%) និងកន្លែងដទៃទៀតក្នុងពិភពលោក (៧០%)។ ការនាំចេញផលិតផលកសិកម្ម កើនឡើង ២៤៩% ដល់ ៧៤លានដុល្លារ ស្របពេលដែលការនាំចេញត្រី ធ្លាក់ចុះ ២៥% មកត្រឹម ០,៦លានដុល្លារ។

នៅត្រីមាសទី១នេះដែរ ការនាំចូលសរុបកើនឡើង ៤៤% ដល់ ៧២៨,៦លានដុល្លារ ក្នុងនេះប្រេងសាំង មានចំណែកប្រមាណ ៨,៥% និងម៉ាស៊ូត ១៣% ហើយការនាំចូលសាំង កើន ១១៥% និងម៉ាស៊ូត កើន ៨៦%។ ការនាំចូលសម្ភារៈសំណង់ ធ្លាក់ចុះ ១៤% មកត្រឹម ១១,៨លានដុល្លារ ដោយសារកំណើនដ៏យឺតក្នុងវិស័យអចលនវត្ថុ។ អតិរេកជញ្ជីងពាណិជ្ជកម្មកម្ពុជា សម្រាប់ត្រីមាសនេះ កើន ៥៣% ធៀបនឹងឆ្នាំមុន ដល់ ២៨៩លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាល អនុវត្តបានល្អក្នុងការបង្កើតប្រាក់ចំណូលកាលពីឆ្នាំទៅ បើធៀបនឹង ១ឆ្នាំមុននោះទៀត។ នៅត្រីមាសទី៤ ឆ្នាំ២០១០ ប្រាក់ចំណូលសរុបពីមួយឆ្នាំទៅមួយឆ្នាំ កើន ២៤% ដល់ ១៦៧៥ពាន់លានរៀល ក្នុងនេះចំណូលចរន្តមានប្រមាណ ៩៤% ចំណូលពន្ធ មាន ៧៣% និងចំណូលមូលធន ៦,២%។ ប៉ុន្តែកំណើនជាភាគរយនៃចំណូលពន្ធ (០,៥%) នៅមានកម្រិតទាបបើធៀបនឹងចំណូលចរន្ត (១៧%) និងចំណូលមូលធន (១១១៤%)។ ក្នុងរយៈពេលដដែល ចំណាយសរុប កើន ៣,៦% ដល់ ១៩៤៥,៤ពាន់លានរៀល ក្នុងនេះចំណាយមូលធនកើន ៦,៤% ដល់ ៦៧៥,៦ពាន់លាលរៀល ប៉ុន្តែចំណាយចរន្ត ធ្លាក់ចុះ ៤,៦% មកត្រឹម ១២៦៩,៨ពាន់លានរៀល។ នៅត្រីមាសទី៤ ឆ្នាំ២០១០ ប្រាក់បៀវត្សរ៍ មានចំណែក ៤៥% ក្នុងចំណាយចរន្ត ហើយចំណែកនៃឧបត្ថម្ភធន និងប្រាក់ឧបត្ថម្ភខាងសង្គមកិច្ចមាន ១៨%។ គួបគ្នាមក ចំណូល និងចំណាយសរុប នៅត្រីមាសទី៤ បង្កឲ្យមានឱនភាពថវិកា ២០៧,៣ពាន់លានរៀល ធៀបនឹងអតិរេក ៩០,២ពាន់លានរៀលកាលពីមួយឆ្នាំមុន។

## អតិផរណា និងអត្រាប្ដូរប្រាក់បរទេស

នៅត្រីមាសទី១ ឆ្នាំ២០១១ ថ្លៃទំនិញទាំងអស់ កើនឡើង ៣,៦% ធៀបនឹងកាលពីមួយឆ្នាំមុន ក្នុងនេះ ថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ៣,៩% ហើយថ្លៃដឹកជញ្ជូន កើន ៥,០%។ ក្នុងត្រីមាសដដែល ប្រាក់រៀលឡើងថ្លៃ ៣,៣% ដល់ ៤០៤១,៩រៀល/ដុល្លារសហរដ្ឋអាមេរិក និងឡើងថ្លៃ ១១% ធៀបនឹងប្រាក់ដុងវៀតណាម។ មាសឡើងថ្លៃ ២៦% ដល់ ១៦៨,៣ដុល្លារក្នុងមួយជី ហើយប្រេងម៉ាស៊ូត ឡើងថ្លៃ ២៣% ដល់ ៤៤២៧,២រៀលក្នុងមួយលីត្រ និងប្រេងសាំងឡើងថ្លៃ ១៤% ដល់ ៤៧៥០,១រៀលក្នុងមួយលីត្រ។

## ការវិវត្តរូបិយវត្ថុ

នៅឆ្នាំ២០១០ សាច់ប្រាក់ងាយស្រួលសរុប (M2) កើនឡើង ១៨% ដល់ ១៨.៤៦៦ពាន់លានរៀល ធៀបនឹង ១៤.៣៧២ពាន់លានរៀល កាលពីមួយឆ្នាំមុន។ នៅត្រីមាសទី៤ ឆ្នាំ២០១០ ទ្រព្យសកម្មបរទេសសុទ្ធ ធ្លាក់ចុះ ១,២% មកត្រឹម ១៦,៦៩៨ពាន់លានរៀល ស្របពេលដែលទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើនឡើង ៤០% ដល់ ២៧៧៩ពាន់លានរៀល។ ក្នុងរយៈពេលដដែល ប្រាក់រៀលចរាចរ កើនឡើង ៥,២% ដល់ ៣២២១ពាន់លានរៀល ហើយរូបិយវត្ថុផ្សេងៗ កើនឡើង ២,៧% ដល់ ១៦.២៥៦ពាន់លានរៀល។

## ស្ថានភាពក្រីក្រ

អង្កេតពលករងាយរងគ្រោះរបស់វិទ្យាស្ថាន CDRI ក្នុងខែឧសភា ២០១១ បង្ហាញថា ក្នុងចំណោមក្រុមពលករមិនមែនខាងកាត់ដេរទាំង ៩ក្រុម មានតែ ២ក្រុមប៉ុណ្ណោះ ដែលបានថយចុះប្រាក់ចំណូល។ អ្នកធាក់ស៊ីក្លូ រងគ្រោះខ្លាំងជាងគេ ដោយសារប្រាក់ចំណូលពិតរបស់ខ្លួន ធ្លាក់ចុះ ១៣% បន្ទាប់មក គឺអ្នកស៊ីឈ្នួលធ្វើស្រែ (ធ្លាក់ចុះ ៤,០%)។ ចំណែកឯកម្មករសំណង់មានជំនាញ អ្នកលក់បន្លែ កម្មករលីសែង អ្នករត់ម៉ូតូឌុប អ្នកបម្រើតុភោជនីយដ្ឋាន អ្នករើសអេតចាយ និងកម្មករសំណង់គ្មានជំនាញ បានកើនប្រាក់ចំណូលពិត។

ដូចមានចុះក្នុងតារាង ៨ ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ កើនឡើង ១៨% ធៀបនឹងខែឧសភាឆ្នាំមុន ដល់ ៨៦៦១រៀលក្នុងមួយថ្ងៃ ចំណែកឯចំណាយប្រចាំថ្ងៃជាមធ្យម

---

១ អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ កញ្ញា អ៊ួន វិមល និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅ វិទ្យាស្ថាន CDRI។

របស់ពួកគាត់ ធ្លាក់ចុះ ៥,0% មកត្រឹម ៤០១៥រៀល/ថ្ងៃ។ ក្នុងចំណោមអ្នករើសអេតចាយឆ្លើយសម្ភាសន៍មាន ៨៣% និយាយថា ប្រភពរបស់អេតចាយបានធ្លាក់ចុះ បើធៀបនឹងក្នុងបីខែមុន។ ទោះជាយ៉ាងនេះក្ដី មាន ៦0% រាយការណ៍ថា របស់អេតចាយបានឡើងថ្លៃ។ អ្នករើសអេតចាយ ៩0% បានធ្វើចំណាកស្រុកពីខេត្តនានា ពិសេសខេត្តព្រៃវែង តាកែវ កណ្ដាល ស្វាយរៀង និងសៀមរាប។

ប្រាក់ចំណូលរបស់អ្នកបម្រើភោជនីយដ្ឋាន បានកើនឡើង ១៣% ធៀបនឹងខែឧសភា ២០១០ ដល់ ៦០៦៦រៀលក្នុងមួយថ្ងៃ។ រយៈពេលធ្វើការជាមធ្យមប្រចាំថ្ងៃរបស់ពួកគេគឺ ១២ម៉ោង ដែលវែងជាងគេក្នុងចំណោមពលករងាយរងគ្រោះទាំង ១០ក្រុម។ អ្នកឆ្លើយសម្ភាសន៍ទាំង ៤០នាក់ ក្នុងក្រុមនេះ ប្រាប់ថា ពួកគេមកធ្វើការតែម្នាក់ឯងនៅភ្នំពេញ។ អ្នកបម្រើភោជនីយដ្ឋានឆ្លើយសម្ភាសន៍ ៤៥% បានចូលរៀននៅមធ្យមសិក្សា។

ប្រាក់ចំណូលរបស់អ្នកលក់បន្លែតូចតាច កើន ៦,៧% ដល់ ៨៥៩៩រៀលក្នុងមួយថ្ងៃ នៅខែឧសភា ២០១១។ អ្នកលក់បន្លែតូចតាចឆ្លើយសម្ភាសន៍ទាំង ៤០នាក់ និយាយថា ប្រាក់ចំណូលរបស់ខ្លួន បានត្រឹមតែមួយគ្រប់ សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារប៉ុណ្ណោះ។ មូលធនជាមធ្យមរបស់ពួកគាត់ គឺ ៥០.000រៀល ដែលទាបជាងខែកុម្ភៈ ១៣% ហើយអ្នកលក់បន្លែ ៧0% និយាយថា ចំនួននេះមិនគ្រប់គ្រាន់សម្រាប់ធ្វើអាជីវកម្មទេ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែង កើនឡើង ៥,៦% ធៀបនឹងខែឧសភា ២០១០ ដល់ ៩៨៦១រៀលក្នុងមួយថ្ងៃ ហើយចំណាយរបស់ពួកគាត់ ធ្លាក់ចុះ ៤,៩% ពី ៥៦៨៩រៀលក្នុងមួយថ្ងៃ មកត្រឹម ៥៤១២រៀលក្នុងមួយថ្ងៃ។ ៧0% នៃអ្នកឆ្លើយសម្ភាសន៍ និយាយថា ពួកគេជួលផ្ទះនៅរួមគ្នា ដោយផ្ទះមួយនៅ ៧នាក់ជាមធ្យម ហើយ ៣0% ទៀត រស់នៅតាមចិញ្ចើមថ្នល់ ឬនៅតាមវត្ត។ អ្នកឆ្លើយសម្ភាសន៍ ៧0% និយាយថា ស្ថានភាពគ្រួសារខ្លួន ល្អប្រសើរឡើង ចាប់ពីបានមកប្រកបរបរនេះ ហើយ ២៣% និយាយថា នៅដដែល និង ៧% និយាយថា កាន់តែលំបាកឡើង។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរ កើនឡើង ៦,១% ធៀបនឹងខែឧសភា ២០១០ ដល់ ៧៩៥0រៀលក្នុងមួយថ្ងៃ រីឯចំណាយប្រចាំថ្ងៃ ធ្លាក់ចុះ ៥,៧% ពី ៤៨៥៣រៀលក្នុងមួយថ្ងៃ មកត្រឹម ៤៥៧៧រៀលក្នុងមួយថ្ងៃ។ ពួកគេបានមកធ្វើការក្នុងរោងចក្រអស់រយៈពេលប្រមាណ ៣ឆ្នាំហើយ ហើយមាន ៤៤% បានផ្លាស់ប្ដូររោងចក្រ។ កម្មករឆ្លើយសម្ភាសន៍ ៤0% និយាយថា ពួកគេប្ដូររោងចក្រដោយសារ មានជម្ងឺ ២% ដោយសារមានបញ្ហាជាមួយអ្នកត្រួតការ ៣៤% ដោយសាររោងចក្របិទទ្វារ និង ២៥% ដោយសារបញ្ហាផ្សេងៗទៀត។ បើសិនជារោងចក្រដែលខ្លួនកំពុងបម្រើការត្រូវបិទទ្វារ ៥៣% នៃអ្នកឆ្លើយសម្ភាសន៍គិតថា នឹងស្វែងរកការងារផ្សេងទៀតធ្វើនៅរាជធានីភ្នំពេញ ឯ ៤២% នឹងត្រឡប់ទៅស្រុកវិញ ហើយ ៥% មិនទាន់ដឹងទេ។

នៅខែកុម្ភៈ ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែធ្លាក់ចុះស្របពេលដែល ៩ក្រុមទៀត កើនចំណូលឡើង។ ការធ្លាក់ចុះនេះបន្ដរហូតដល់ខែឧសភា ដែលនៅពេលនោះប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពួកគេ ធ្លាក់ចុះ ៤,៤% មកត្រឹម ៥៩៨៤រៀលក្នុងមួយថ្ងៃ។ ពលករឆ្លើយសម្ភាសន៍ ៥៧% មានដីដាំដុះតិចជាងមួយហិកតា ៣៨% គ្មានដីទេ ៣% មានដី ១ហិកតា និង ៣% ទៀត មានដីលើសពីមួយហិកតា។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកធាក់ស៊ីក្លូ មិនដែលបានលើសពី ១០,000រៀលក្នុងមួយថ្ងៃទេ តាំងពីឆ្នាំ២00៨ មក ប៉ុន្ដែបានឡើងដល់ ១០.៦៣៣រៀលក្នុងមួយថ្ងៃ នៅខែកុម្ភៈ ២០១១។ បន្ទាប់ពីមានកំណើនខ្លាំង ប្រាក់ចំណូលពិតជាមធ្យមរបស់អ្នកធាក់ស៊ីក្លូ បានធ្លាក់ចុះ ២២% នៅខែឧសភា បើប្រៀបធៀបនឹងរយៈពេល ៣ខែមុន និងធ្លាក់ចុះ ១៣% ធៀបនឹងខែឧសភាឆ្នាំមុន។ មានអ្នកធាក់ស៊ីក្លូឆ្លើយសម្ភាសន៍តែ ២0% ប៉ុណ្ណោះ ដែលមានស៊ីក្លូផ្ទាល់ខ្លួន ឯក្រៅពីនោះត្រូវជួលស៊ីក្លូពីគេ។ សមាមាត្រអ្នកធាក់ស៊ីក្លូ ដែលរស់នៅតាមចិញ្ចើមថ្នល់ នឹងរស់នៅតាមវត្ត កើនឡើងពី ៦៣% នៅខែកុម្ភៈ ទៅដល់ ៦៨% នៅខែឧសភា ឆ្នាំ២០១១។ រយៈពេលមធ្យមដែលពួកគេប្រកបរបរនេះគឺ ៩ឆ្នាំ។

---

តពីទំព័រ ១៤ "**ការពង្រឹងផលចំណេញ**....."

សម្ពាធពីសង្គម និងក្រុមគ្រួសារ ឲ្យចូលរៀនក្នុង HEIs និងចូលបម្រើការងារការិយាល័យ ដែលគេគិតថាបានប្រាក់ខែខ្ពស់ជាង។ គំនិតនេះខុសពីការពិតខ្លាំងណាស់ ដែលនាំឲ្យអ្នកមានសញ្ញាប័ត្រឧត្ដមសិក្សាភាគច្រើន ទទួលបានតំណែងទាបជាងសមត្ថភាពរបស់ខ្លួន។ ដើម្បីដោះស្រាយបញ្ហា គេត្រូវប្ដូរឈ្មោះថ្មីឲ្យការអប់រំ និងការបណ្ដុះបណ្ដាលបច្ចេកទេស វិជ្ជាជីវៈ (TVET) នេះ ដើម្បីឆ្លុះបញ្ចាំងពីការពិត ដែលកម្មវិធីនេះផ្ដល់ឲ្យបុគ្គលម្នាក់ៗនូវជំនាញដែលបង្កើនលទ្ធភាពរកបានការងាររបស់ពួកគេ។ ការបញ្ជ្រាប និងសម្របសម្រួលកម្មវិធី TVET ព្រមទាំងប្រព័ន្ធទទួលស្គាល់គុណភាពសមស្រប ក៏រួមចំណែកជួយកែប្រែគំនិតនេះបានច្រើនដែរ។

បច្ចុប្បន្នមានតម្រូវការកាន់តែច្រើនឡើង ដើម្បីបង្កើនទំនាក់ទំនងរវាងវិស័យឯកជន អ្នករៀបចំគោលនយោបាយ និងកម្លាំងពលកម្ម។ ចំណុចនេះសំខាន់ណាស់ ជាពិសេសនៅពេលកម្ពុជាកំពុងប្រឹងប្រែងធ្វើពិពិធកម្ម និងឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃបន្ថែម ហើយតម្រូវការរបស់និយោជកក៏អាចប្រែប្រួលយ៉ាងឆាប់រហ័ស។ គោលនយោបាយ ត្រូវតែយកចិត្តទុកដាក់ និងឆ្លើយតបយ៉ាងសកម្មនឹងការប្រែប្រួលទាំងនេះ ដើម្បីឲ្យកម្មវិធីបណ្ដុះបណ្ដាលផ្សេងៗ អាចសម្របខ្លួនបានលឿនតាមស្ថានភាពសេដ្ឋកិច្ចជាក់ស្ដែង ហើយកម្លាំងពលកម្ម ក៏អាចទាញយកប្រយោជន៍បានលឿនពីឱកាសល្អនានា ដែលទើបផុសឡើង។ ឧទាហរណ៍ថ្មីស្រឡាងមួយ គឺតម្រូវការបណ្ដុះបណ្ដាលជាបន្ទាន់ ដើម្បីទាញយកប្រយោជន៍ឲ្យបានច្រើនជាអតិបរមា ពីឱកាសល្អនានាដែលកំពុងផុសឡើងក្នុងតំបន់សេដ្ឋកិច្ចពិសេស (SEZs)។ ដើម្បីកំណត់បានពីតម្រូវការទីផ្សារពលកម្ម ដែលកំពុងផុសឡើងនេះ ត្រូវមានការសិក្សាស្រាវជ្រាវជាក់ស្ដែងស៊ីជម្រៅដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្ដល់ព័ត៌មានអំពីទីផ្សារពលកម្មឲ្យបានទាន់ពេលដល់អ្នករៀបចំគោលនយោបាយ។

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | ទ្រព្យសកម្មជាប់លាប់ ( លានដុល្លារ ) | | | | | | | | | | | |
| កសិកម្ម | 26.8 | 498.0 | 135.6 | 92 | 175.3 | 176.1 | 94.4 | 165.7 | 41.4 | 278.0 | 36.7 | 4.1 |
| ឧស្សាហកម្ម | 914.6 | 365.3 | 709.1 | 724.9 | 257.7 | 60.6 | 685.5 | 247.7 | 54.5 | 44.3 | 87.7 | 67.1 |
| *កាត់ដេរ* | *174.4* | *89.4* | *170.7* | *142.8* | *16.4* | *21.9* | *14.2* | *13.1* | *21.3* | *29.3* | *50.0* | *57.1* |
| សេវាកម្ម | 155.5 | 2939.1 | 1742.5 | 10,003.2 | 495.6 | 150.2 | 3475.8 | 89.5 | 121.6 | 0 | 1096.2 | 209.5 |
| *សណ្ឋាគារ និងទេសចរណ៍* | *102.6* | *345.0* | *1048.3* | *8758.1* | *254.1* | *150.2* | *0.0* | *3.78* | *14.0* | *0* | *1087.4* | *107.9* |
| សរុប | 1096.9 | 3802.4 | 2587.2 | 10570.9 | 928.6 | 386.3 | 4255.7 | 502.9 | 217.5 | 322.3 | 1220.6 | 280.72 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | -41.2 | 882.0 | 1001.7 | -91.2 | -56.8 | 48.2 | 278.8 | -77.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 275.6 | 246.6 | -32.0 | 308.6 | 266.5 | -91.5 | 169.3 | -59.8 | 452.0 | -16.6 | -71.3 | -44.2 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 45.5 | 33.1 | 79.1 | 154.7 | 32.1 | 15.6 | 9.8 | 5.1 | 7.5 | 14.1 | 9.5 | 4.1 |
| ផ្ទះល្វែង | 204.2 | 213.3 | 297.2 | 221.6 | 95.2 | 7.4 | 28.0 | 11.1 | 127.2 | 25.3 | 20.3 | 16.1 |
| ផ្សេងៗ | 109.1 | 76.8 | 259.6 | 740.9 | 53.7 | 68.4 | 29.0 | 35.2 | 67.4 | 38.9 | 76.2 | 23.6 |
| សរុប | 358.8 | 323.3 | 635.8 | 1117.0 | 181.1 | 91.4 | 66.8 | 51.4 | 202.1 | 78.4 | 106.0 | 43.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | -48.5 | 46.6 | -26.9 | -23.1 | 293.2 | -61.2 | 35.3 | -58.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 36.2 | -9.9 | 96.7 | 75.7 | 31.9 | -81.2 | -81.0 | -71.6 | 224.4 | -14.2 | 58.7 | -14.8 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | ចំនួនអ្នកដំណើរ ( ពាន់នាក់ ) | | | | | | | | | | | |
| តាមផ្លូវអាកាស | 856.5 | 1029.0 | 1296.5 | 1239.4 | 335.2 | 247.2 | 308.1 | 371.5 | 260.9 | 288.3 | 383.7 | 427.4 |
| តាមផ្លូវគោក និងទឹក | 565.1 | 672.9 | 718.6 | 881.9 | 287.1 | 240.2 | 279.5 | 312.2 | 276.6 | 293.8 | 321.4 | 351.0 |
| សរុប | 1421.6 | 1701.9 | 2015.1 | 2121.3 | 622.3 | 487.4 | 587.6 | 683.7 | 537.5 | 582.0 | 705.1 | 778.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 7.7 | 5.0 | 20.6 | 16.4 | -21.4 | 8.3 | 21.2 | 10.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 34.7 | 19.7 | 28.4 | 5.3 | -3.4 | 9.4 | 1.7 | 9.9 | 15.8 | 19.4 | 20.0 | 13.9 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 2352.8 | 2810.9 | 3050.3 | 3097.8 | 697.4 | 709.9 | 736.5 | 693.8 | 820.7 | 1045.3 | 1070.3 | 1017.7 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2253.3 | 2698.8 | 2938.9 | 2986.2 | 667.1 | 601.4 | 660.7 | 625.5 | 716.8 | 938.3 | 942.7 | 880.5 |
| - ទៅសហរដ្ឋអាមេរិក | 1546.1 | 1847.2 | 1956.5 | 1908.3 | 387.6 | 372.9 | 388.5 | 380.5 | 416.7 | 531.9 | 524.7 | 464.5 |
| - ទៅសហភាពអឺរ៉ុប | 503.1 | 601.0 | 654.2 | 689.0 | 183.1 | 128.0 | 165.5 | 137.2 | 184.8 | 239.4 | 248.0 | 232.0 |
| - ទៅអាស៊ាន | 2.3 | 2.6 | 3.2 | 10.8 | 1.0 | 1.3 | 2.9 | 2.2 | 1.9 | 2.9 | 3.0 | 3.8 |
| - ទៅជប៉ុន | 23.5 | 29.4 | 28.5 | 25.2 | 5.2 | 9.5 | 14.3 | 19.8 | 14.9 | 25.5 | 26.2 | 34.3 |
| - ទៅប្រទេសផ្សេងៗ | 178.3 | 218.7 | 296.4 | 352.9 | 90.2 | 89.6 | 89.6 | 85.7 | 98.6 | 138.6 | 140.7 | 145.9 |
| កសិកម្ម | 61.3 | 59.7 | 55.6 | 44.5 | 8.0 | 15.1 | 25.9 | 21.2 | 27.2 | 44.8 | 71.7 | 74.0 |
| - កៅស៊ូ | 36.8 | 41.5 | 41.0 | 35.8 | 5.1 | 11.8 | 16.5 | 11.9 | 13.8 | 25.3 | 38.1 | 49.9 |
| - ឈើ | 10.3 | 8.6 | 8.7 | 3.4 | 0.7 | 0.6 | 1.8 | 2.7 | 4.5 | 8.8 | 18.1 | 6.2 |
| - ត្រី | 10.1 | 5.9 | 3.2 | 2.3 | 0.7 | 0.8 | 1.2 | 0.8 | 0.7 | 0.5 | 0.8 | 0.6 |
| - ផ្សេងៗ | 4.2 | 3.7 | 2.7 | 3.1 | 1.5 | 1.9 | 6.3 | 5.7 | 8.2 | 10.2 | 14.7 | 17.3 |
| ផ្សេងៗ | 38.3 | 52.3 | 55.8 | 67.1 | 22.3 | 93.4 | 50.0 | 47.1 | 76.7 | 62.2 | 55.9 | 63.2 |
| ការនាំចូលសរុប | 2513.0 | 512.2 | 554.8 | 1010.9 | 585.3 | 484.4 | 532.8 | 505.6 | 563.2 | 731.3 | 677.1 | 728.7 |
| ក្នុងនេះ៖ សាំង | 40.2 | 38.8 | 58.7 | 70.1 | 16.8 | 19.3 | 19.4 | 28.8 | 22.4 | 27.6 | 30.5 | 62.0 |
| ម៉ាស៊ីត | 93.1 | 113.0 | 122.8 | 113.5 | 34.2 | 46.0 | 43.1 | 49.8 | 55.4 | 48.0 | 50.5 | 92.5 |
| សម្ភារៈសំណង់ | 134.7 | 56.5 | 69.0 | 77.8 | 13.8 | 15.7 | 13.3 | 13.7 | 13.2 | 16.7 | 13.8 | 11.8 |
| ផ្សេងៗ | 2245.0 | 303.9 | 304.3 | 749.5 | 520.5 | 403.4 | 457.0 | 413.3 | 472.2 | 638.9 | 582.3 | 562.4 |
| ជញ្ជីងពាណិជ្ជកម្ម | -160.2 | 2298.7 | 2495.5 | 2086.9 | 112.1 | 225.5 | 203.7 | 188.2 | 257.5 | 314.0 | 393.2 | 289.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | -9.9 | 23.0 | -8.1 | -5.3 | 14.6 | 30.9 | 0.5 | -6.6 |
| ការនាំចេញសរុប | - | - | - | - | 1.8 | 23.4 | -8.4 | -5.8 | 18.3 | 27.4 | 2.4 | -4.9 |
| ការនាំចូលសរុប | - | - | - | - | 2.8 | -20.3 | 10.0 | -5.1 | 11.4 | 29.8 | -7.4 | 7.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 11.2 | 19.8 | 8.9 | 1.6 | -19.7 | -16.5 | -1.0 | 4.0 | 22.6 | 30.5 | 42.7 | 40.8 |
| ការនាំចេញសរុប | 11.6 | 19.5 | 8.5 | 1.6 | -7.6 | -10.2 | 5.6 | -2.3 | 26.0 | 30.0 | 45.3 | 46.7 |
| ការនាំចូលសរុប | 189.6 | -79.6 | 8.3 | 82.2 | 0.2 | -8.4 | 13.7 | -14.5 | -7.4 | 51.0 | 27.1 | 44.1 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site).*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៥-១០ (ពាន់លានរៀល)

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 2625.0 | 3259.2 | 1146.1 | 5290.0 | 1101.7 | 1252.7 | 1184.7 | 1346.1 | 1536.8 | 1341.1 | 1436.0 | 1675.0 |
| ចំណូលចរន្ត | 2474.0 | 2881.8 | 1141.6 | 5210.7 | 1097.7 | 1245.7 | 1174.9 | 1337.7 | 1526.4 | 1330.9 | 1431.2 | 1570.5 |
| ចំណូលពន្ធ | 1911.0 | 2270.9 | 965.2 | 4409.9 | 947.4 | 1096.5 | 999.5 | 1224.1 | 1094.1 | 1143.8 | 1225.5 | 1229.6 |
| ពន្ធក្នុងស្រុក | - | - | 661.8 | 3248.4 | 712.0 | 838.7 | 731.8 | 808.5 | 820.3 | 890.9 | 916.9 | 905.5 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | 303.5 | 1161.5 | 235.4 | 257.8 | 268.0 | 303.4 | 273.7 | 253.0 | 308.6 | 324.1 |
| ចំណូលមិនមែនពន្ធ | 563.0 | 610.9 | 176.4 | 800.8 | 150.3 | 149.2 | 176.1 | 225.7 | 432.4 | 187.1 | 205.7 | 340.9 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | 13.6 | 78.0 | 13.1 | 9.7 | 27.5 | 14.3 | 237.0 | 20.2 | 19.5 | 14.5 |
| លក់ទំនិញ និងសេវា | - | - | 124.3 | 424.7 | 93.5 | 100.9 | 91.7 | 121.9 | 108.4 | 102.9 | 127.0 | 121.7 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | 38.5 | 298.2 | 43.7 | 38.6 | 56.5 | 89.5 | 84.0 | 61.0 | 59.2 | 204.8 |
| ចំណូលជាមូលធន | 152.0 | 377.4 | 4.5 | 79.3 | 4.0 | 7.0 | 9.8 | 8.4 | 10.4 | 10.2 | 4.8 | 104.5 |
| ចំណាយសរុប | 3295.0 | 4174.7 | 1689.7 | 6297.8 | 1650.6 | 1766.1 | 2089.5 | 1877.1 | 2129.4 | 2154.8 | 2390.3 | 1945.4 |
| ចំណាយជាមូលធន | 1328.0 | 1638.1 | 807.4 | 2574.4 | 693.6 | 607.1 | 759.2 | 634.9 | - | 913.0 | 887.0 | 675.6 |
| ចំណាយចរន្ត | 1967.0 | 2536.8 | 882.3 | 3809.0 | 752.4 | 1064.7 | 1290.4 | 1332.3 | 831.8 | 1168.1 | 1503.3 | 1269.8 |
| បៀវត្សរ៍ | 711.0 | 822.0 | 362.6 | 1397.0 | 327.4 | 515.5 | 526.6 | 642.5 | - | 545.6 | 562.4 | 567.4 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | 194.2 | 927.1 | 217.3 | 185.9 | 272.6 | 195.6 | 213.3 | 253.2 | 401.5 | 231.4 |
| ចំណាយចរន្តផ្សេងទៀត | - | - | 325.5 | 1384.9 | 207.7 | 363.2 | 491.2 | 494.3 | 449.6 | 369.3 | 539.4 | 471.0 |
| សមតុល្យជាទូទៅ | -706.0 | -915.6 | -543.6 | -1007.8 | -548.9 | -513.4 | -904.8 | 90.2 | -592.6 | -813.7 | -954.2 | -207.3 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1127.0 | 1360.7 | 741.5 | 2055.1 | 507.8 | 326.7 | 484.5 | -531.0 | 270.8 | 746.0 | 409.1 | 419.3 |
| ហិរញ្ញប្បទានក្នុងស្រុក | -396.0 | -445.1 | -185.8 | -127 | -310.3 | 236.5 | 316.4 | 406.4 | 422.8 | 194.1 | 343.3 | -21.6 |

*Source: MEF web site.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៥-១១

| | 2005 | 2006 | 2007 | 2008 | 2009 | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 4.7 | 5.8 | 19.7 | 4.3 | -3.0 | 1.7 | 7.0 | 4.1 | 1.8 | 3.3 | 3.6 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 8.6 | 6.4 | 9.9 | 33.1 | 6.1 | -2.7 | 1.8 | 7.8 | 3.6 | 1.9 | 4.1 | 3.9 |
| - ដឹកជញ្ជូន | 11.4 | 9.1 | 5.8 | 19.4 | -13.0 | -13.8 | 2.4 | 12.9 | 8.7 | 3.2 | 3.1 | 5.0 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.7 | 4119.0 | 4062.7 | 4058.2 | 4111.6 | 4164.4 | 4157.3 | 4180.1 | 4209.0 | 4236.7 | 4122.6 | 4041.9 |
| រៀលក្នុង ១ បាតថៃ | 102.6 | 108.7 | 122.8 | 123.5 | 116.6 | 122.9 | 126.0 | 127.0 | 129.9 | 138.3 | 137.3 | 132.7 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.8 | 25.1 | 25.0 | 24.8 | 23.6 | 23.5 | 23.0 | 22.3 | 22.1 | 21.4 | 21.1 | 19.9 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 54.0 | 70.6 | 83.2 | 105.9 | 105.6 | 123.2 | 133.8 | 133.9 | 142.9 | 147.8 | 165.7 | 168.3 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2633.0 | 3140.0 | 3262.3 | 4555.2 | 2873.7 | 3867.0 | 3381.9 | 3599.5 | 3835.1 | 3936.6 | 4066.1 | 4427.2 |
| ថ្លៃសាំង (រៀល/លីត្រ) | 3442.0 | 4004.0 | 4005.0 | 4750.8 | 3112.6 | 3371.1 | 3940.2 | 4163.0 | 4358.7 | 4415.5 | 4535.2 | 4750.1 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៥-១០ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 5475.0 | 7224.0 | 10,735.0 | 10,345.0 | 11,222.0 | 12,611.0 | 13,869.0 | 14,655.0 | 15,514.6 | 12,610.9 | 16,903.0 | 16,697.9 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -450.0 | -282.0 | 576.0 | 1513.3 | 1266.0 | 1249.0 | 1042.0 | 1573.0 | 1720.0 | 1785.3 | 1984.8 | 2778.9 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -421.0 | -953.0 | -1816.0 | -2987.0 | -3048.0 | -2889.0 | -2463.0 | -2252.0 | -2484.8 | -2362.7 | -2,120.4 | -2126.6 |
| ឥណទានដល់ផ្នែកឯកជន | 2394.0 | 3630.0 | 6386.0 | 9894.0 | 9814.0 | 10,129.0 | 10,127.0 | 10,532.0 | 11,146.7 | 11,859.1 | 12,479.8 | 13,331.2 |
| រូបិយវត្ថុទូទៅ M2 | 5025.0 | 6942.0 | 11,311.0 | 11,858.0 | 12,488.0 | 13,859.0 | 14,912.0 | 16,228.0 | 17,234.5 | 18,267.1 | 18,887.8 | 19,476.8 |
| រូបិយវត្ថុ M1 | 1323.0 | 1658.0 | 2052.0 | 2399.0 | 2545.0 | 2695.0 | 2773.0 | 3120.0 | 3148.5 | 3115.1 | 3061.7 | 3220.9 |
| រូបិយវត្ថុផ្សេងៗ | 3702.0 | 5285.0 | 9259.0 | 9459.0 | 9942.0 | 11,164.0 | 12,139.0 | 13,108.0 | 14,086.0 | 15,152.0 | 15,826.1 | 16255.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.1 | 38.1 | 62.9 | 4.8 | 3.7 | 9.1 | 18.7 | 36.9 | 38.0 | 31.8 | 26.7 | 20.0 |
| រូបិយវត្ថុ M1 | 14.7 | 25.3 | 23.8 | 16.9 | 6.5 | 9.2 | 18.7 | 30.1 | 23.7 | 15.6 | 10.4 | 3.2 |
| រូបិយវត្ថុផ្សេងៗ | 16.6 | 42.8 | 75.2 | 2.2 | 2.9 | 9.1 | 18.7 | 38.6 | 41.7 | 35.7 | 30.4 | 24.0 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2006 | 2007 | 2008 | 2009 | 2010 | | | 2011 | | 2010 | 2011 | |
| | | | | | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នកជាក់ស៊ីក្លូ | 7469 | 8075 | 12,628 | 8091 | 9570 | 8404 | 8759 | 10,633 | 8292 | 21.7 | 13.0 | -13.4 |
| អ្នកលីសែង | 6545 | 8588 | 9005 | 9549 | 9340 | 10,525 | 9965 | 11,184 | 9861 | 7.8 | 12.4 | 5.6 |
| អ្នកលក់បន្លែតូចតាច | 6390 | 8220 | 9926 | 8273 | 8062 | 8291 | 8821 | 9149 | 8599 | 19.4 | 16.9 | 6.7 |
| អ្នករើសអេតចាយ | 4416 | 5422 | 4652 | 5857 | 7407 | 6461 | 6628 | 6931 | 8661 | 46.1 | 11.1 | 16.9 |
| អ្នកបំរើតុភោជនីយដ្ឋាន* | 4412 | 4482 | 4327 | 4646 | 5380 | 6427 | 5448 | 6154 | 6066 | 1.3 | 19.9 | 12.7 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5306 | 5516 | 8697 | 6197 | 6260 | 6186 | 4912 | 4806 | 5984 | 1.6 | -10.3 | -4.4 |
| កម្មកររោងចក្រកាត់ដេរ | 7649 | 7568 | 6554 | 7085 | 7491 | 8470 | 7944 | 8312 | 7950 | 6.2 | 10.0 | 6.1 |
| អ្នករត់ម៉ូតូឌុប | 8201 | 10,634 | 15,691 | 10,685 | 10,274 | 10,558 | 10,278 | 11,444 | 10,630 | 9.7 | 1.3 | 3.5 |
| កម្មករសំណង់គ្មានជំនាញ | 5918 | 6155 | 8779 | 8343 | 9013 | 8744 | 9636 | 11,291 | 9415 | 22.6 | 46.7 | 4.5 |
| កម្មករសំណង់មានជំនាញ | 10,316 | 11,154 | 12,710 | 12,487 | 11,928 | 11,738 | 12,122 | 12,487 | 12,368 | -3.6 | 4.7 | 3.7 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

*តពីទំព័រ ២៤* **ព័ត៌មានថ្មីពី...**

សម្រាប់ឲ្យអ្នកប្រើប្រាស់ អាចទាញយកឯកសារបោះពុម្ពផ្សាយសំខាន់ៗមកប្រើបានដោយឥតគិតថ្លៃ។

## ផ្នែកស្រាវជ្រាវ

### កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈ (DGPRS)

នាបច្ចុប្បន្ន កម្មវិធីនេះកំពុងបង្ហើយការសិក្សាចំនួន ៥ គម្រោង គឺមាន ១) *"ការពិនិត្យពីសមត្ថភាពធម្មតារបស់រដ្ឋនៅកម្ពុជា នៅពេលសេដ្ឋកិច្ចកំពុងផ្លាស់ប្តូរ"* ដែលព្យាយាមវាយតម្លៃពីសមត្ថភាពរបស់រដ្ឋនាពេលបច្ចុប្បន្ន ២) គម្រោង *"អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ក្នុងប្រព័ន្ធនយោបាយបែបកូនកាត់៖ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) នៅក្នុងបរិបទប្រទេសកម្ពុជា"* ដែលព្យាយាមកំណត់ពីនិន្នាការ និងអនាគតនៃកំណែទម្រង់ D&D ក្នុងបរិបទប្រទេសកម្ពុជា ដែលមានប្រព័ន្ធទាំងពីរនៅលាយឡំគ្នា និងស្វែងរកចម្លើយថា តើ D&D ជួយពង្រឹងរបបប្រជាធិបតេយ្យនៅកម្ពុជាដែរឬទេ ៣) គម្រោង *"អង្កេតមូលដ្ឋានអំពីរដ្ឋបាលថ្នាក់ក្រោមជាតិ៖ ការស្វែងយល់ឲ្យបានកាន់តែប្រសើរពីកំណែទម្រង់ D&D នៅកម្ពុជា"* ដែលស្រាវជ្រាវពីចំណាប់អារម្មណ៍ និងការយល់ដឹងរបស់សមាជិកក្រុមប្រឹក្សាឃុំអំពីរដ្ឋបាលថ្នាក់ស្រុក និងខេត្ត (ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក និងខេត្ត) ៤) គម្រោង *"អភិបាលកិច្ចដែនរងទឹកភ្លៀង និងបញ្ហាចោទក្នុងកិច្ចសហប្រតិបត្តិការ៖ ករណីសិក្សានៅកម្ពុជា"* ដែលពិនិត្យពីកិច្ចសហប្រតិបត្តិការរវាងតួអង្គនានាក្នុងបរិបទនៃកំណែទម្រង់ D&D និង ៥) គម្រោង *"អភិបាលកិច្ចតាមបែបវិមជ្ឈការនៃទឹកស្រោចស្រពនៅកម្ពុជា៖ ការផ្គូផ្គងគោលការណ៍ទៅនឹងស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន"* ដែលពិនិត្យពីកម្រិតស៊ីគ្នារវាងរបៀបរៀបចំអភិបាលកិច្ច ហើយនិងតម្រូវការចាំបាច់នៃប្រព័ន្ធធារាសាស្ត្រទាំងនោះ។ អត្ថបទសង្ខេបគោលនយោបាយផ្អែកលើការសិក្សាទាំងពីរ គឺផ្នែកអភិបាលកិច្ចទឹក និងដែនរងទឹកភ្លៀង បានបោះពុម្ពផ្សាយរួចហើយ។

ក្រុមស្រាវជ្រាវ កំពុងកំណត់នូវគោលគំនិតធំៗសម្រាប់ការសិក្សាចំនួន ៤ គឺមាន ១) *"ផលប៉ះពាល់នៃ D&D ទៅលើការកាត់បន្ថយភាពក្រីក្រ"* ២) *"បដិការរវាងរដ្ឋ និងសង្គម"* ៣) *"ទំនាក់ទំនងរវាងឃុំ និងសង្កាត់"* និង ៤) *"វិមជ្ឈការតាមវិស័យ៖ ករណីសិក្សាក្នុងវិស័យអប់រំ"* ។ ក្រុមស្រាវជ្រាវ ក៏កំពុងរៀបចំផែនការធ្វើសិក្ខាសាលាផ្សព្វផ្សាយប្រចាំឆ្នាំមួយ នៅខែតុលា ២០១១។

### កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ (ETRC)

*"អង្កេតពលកររងាយរងគ្រោះ"* និង *"អង្កេតថ្លៃទំនិញនៅតាមខេត្ត"* បានដំណើរការទៅមុខយ៉ាងល្អ។ គម្រោង *"ចរន្តពលករខុសៗគ្នា តម្រូវការខុសៗគ្នា និងផលប៉ះពាល់ខុសៗគ្នា៖ ការគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្មអន្តរជាតិនៅអាស៊ាន"* និង គម្រោង *"ការវិភាគពីវិនិយោគអន្តរជាតិក្នុងវិស័យកសិកម្មនៅកម្ពុជា"* បានបញ្ចប់ដោយជោគជ័យ។ គម្រោង *"ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិន ទៅលើការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់មេគង្គ (GMS)៖ ករណីប្រទេសកម្ពុជា"* ត្រូវបានបោះពុម្ពជាឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI រួចហើយ។

សមាសភាគទីបីនៃ *"គម្រោងបណ្តាញភាពក្រីក្រ"* របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កំពុងដំណើរការយ៉ាងល្អ។ ឯកសារគោលគំនិតនៃគម្រោងនេះ បានប្រគល់ទៅឲ្យ ADB ជាស្រេច ហើយលទ្ធផលស្រាវជ្រាវបឋម នឹងមានបង្ហាញក្នុងសិក្ខាសាលាថ្នាក់តំបន់នៅប្រទេសឥណ្ឌូនេស៊ី ក្នុងខែកញ្ញា។ ឯកសារព្រាងដំបូងនៃគម្រោង *"ការវិភាគពីភាពក្រីក្រពុំរើនៅជនបទកម្ពុជា៖ ភស្តុតាងបានពីទិន្នន័យអង្កេតជាបន្តបន្ទាប់ (panel data)"* គ្រោងចប់រួចរាល់សម្រាប់ផ្ញើសុំយោបល់នៅខែកញ្ញា។ គម្រោង *"ការធ្វើរោគវិនិច្ឆ័យលើកំណើន ជំហានទីពីរ"* កំពុងបន្តទៅមុខ។ លទ្ធផលរកឃើញសំខាន់ៗនៃគម្រោង *"អាស៊ាន ឆ្នាំ២០៣០៖ ឯកសារសាវតារកម្ពុជា"* បានយកទៅបង្ហាញក្នុងសិក្ខាសាលាពិគ្រោះយោបល់ នៅប្រទេសឥណ្ឌូនេស៊ី កាលពីដើមខែកក្កដា។ ឯកសារព្រាងដំបូង ស្តីពី *"គោលនយោបាយគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម"* បានបញ្ជូនទៅឲ្យ វិទ្យាស្ថានអភិវឌ្ឍន៍កូរ៉េ (KDI) រួចរាល់ ហើយលទ្ធផលស្រាវជ្រាវនានា ត្រូវបានលើកយកទៅបង្ហាញនៅក្នុងសិក្ខាសាលាផ្នែកគោលនយោបាយ កាលពីដើមខែសីហា។

នៅខែកក្កដា សមាជិកបណ្តាញវិភាគអភិវឌ្ឍន៍នៃមហាអនុតំបន់មេគង្គ (GMS-DAN) បានរៀបចំសិក្ខាសាលាមួយនៅវិទ្យាស្ថាន CDRI ដើម្បីពិនិត្យឡើងវិញលើមេរៀនទទួលបានពីគម្រោងស្រាវជ្រាវ GMS-DAN8 ដែលផ្តោតលើដំណើរការជ្រើសរើស និងប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ និងដើម្បីពិភាក្សាពីការសម្របសម្រួលកម្មវិធី និងគម្រោង ក៏ដូចជាបញ្ហានានាសម្រាប់ការស្រាវជ្រាវទៅថ្ងៃមុខ។

អង្កេតមួយស្តីពីសហគ្រាសធុនមីក្រូ តូច និងមធ្យម ដែលបានអនុវត្តឡើងនៅខែសីហា ក្នុងក្របខ័ណ្ឌនៃគម្រោង *"វិបត្តិហិរញ្ញវត្ថុសាកល និងភាពងាយរងគ្រោះនៅកម្ពុជា៖ អង្កេតគ្រួសារជុំទីពីរ"* នឹងត្រូវបញ្ចប់នៅពាក់កណ្តាលខែកញ្ញា។

វេទិកាស្រាវជ្រាវអភិវឌ្ឍន៍ គ្រោងរៀបចំសន្និសីទប្រចាំឆ្នាំលើកទី៤ នៅទីក្រុងភ្នំពេញ នៅថ្ងៃទី ៨-៩ កញ្ញា ២០១១។ សំណើសម្រាប់ជំហានទី២ បានបញ្ជូនទៅឲ្យមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) ដើម្បីជូន និងសុំយោបល់។

### កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន (NRE)

កម្មវិធីនេះ កំពុងអនុវត្តគម្រោងធំៗចំនួន ៤ ។ ក្រុមដំណើរការគម្រោង *"កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក"* បានរៀបចំសិក្ខាសាលាថ្នាក់ជាតិលើកចុងក្រោយដើម្បីបញ្ចប់គម្រោង និងផ្សព្វផ្សាយពីសមិទ្ធផលនានានៃកម្មវិធីនេះ ដែលរួមមាន ឯកសារពិភាក្សា អត្ថបទសង្ខេបគោលនយោបាយ និងខ្សែវីដេអូខ្លីមួយ។ គម្រោង *"ព្រៃតំបន់ត្រូពិចសម្រាប់ការកាត់បន្ថយភាពក្រីក្រ-ការវិភាគទិន្នន័យ តាំងពីកម្រិតគ្រួសារដល់កម្រិតសាកល"* មានទិសដៅពង្រីកចំណេះដឹងស្តីពីតួនាទីព្រៃតំបន់ត្រូពិចក្នុងការកាត់បន្ថយភាពក្រីក្រ។ ឯកសារពិភាក្សានៃការសិក្សានេះ បានដាក់បញ្ចូលក្នុងវែបសាយ ហើយលទ្ធផលនានា បានយកទៅបង្ហាញក្នុងសន្និសីទថ្នាក់ជាតិ នៅខែមិថុនា ២០១១។ គម្រោង "ការពិនិត្យតាមដានផលប៉ះពាល់សង្គម និងអង្កេតមូលដ្ឋានវាយតម្លៃភាពងាយរងគ្រោះ" មានគោលដៅស្វែងយល់ពី កម្រិតពឹងផ្អែករបស់ប្រជាជនទៅលើធនធានទឹកនៅតាមដងទន្លេមេគង្គមួយកន្លែងប្រវែង ១៥គ.ម ដើម្បីជួយបញ្ជាក់ដល់ការវាយតម្លៃពីភាពងាយរងគ្រោះ និងផលប៉ះពាល់ខាងសង្គម នៅក្នុងគំនិតផ្តួចផ្តើមស្តីពីការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុរបស់គណៈកម្មការទន្លេមេគង្គ (MRC)។ របាយការណ៍ព្រាងនៃគម្រោងនេះ បានបញ្ជូនទៅក្រុមប្រចាំតំបន់

ឲ្យជួយពិនិត្យផ្តល់យោបល់ហើយ។ គម្រោង *"កសិកម្ម និងការប្រែប្រួលអាកាសធាតុ"* ផ្តល់មូលនិធិដោយ USAID តាមរយៈ វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI) និងអនុវត្តរួមគ្នាជាមួយ កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ មានគោលដៅធ្វើវិភាគអំពីកសិកម្ម និងសន្តិសុខស្បៀងក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុក្នុងន័យទូលាយ ដោយកំណត់ពីឧបសគ្គចំពោះកសិករនាពេលបច្ចុប្បន្ន ក្នុងការលើកកម្ពស់ទិន្នផល និងសម្របខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ។ ក្រុមស្រាវជ្រាវ បានបញ្ចប់ការសរសេររបាយការណ៍ព្រាងដំបូង និងបានទៅចូលរួមសិក្ខាសាលាបច្ចេកទេសនៅទីក្រុង Dhaka ប្រទេសបង់ក្លាដែស ហើយរបាយការណ៍សម្រេច បានយកមកបង្ហាញជូន ក្នុងសន្និសីទជាតិ នៅខែសីហា នៅខេត្តសៀមរាប។

កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ (PARD)

កម្មវិធីនេះកំពុងអនុវត្តគម្រោងចំនួន ៧ ។ក្រុមអនុវត្តគម្រោង *"ការវាយតម្លៃពីផលប្រយោជន៍នៃអង្គការកសិករ ចំពោះសន្តិសុខស្បៀងរបស់ជនក្រីក្រនៅជនបទ"* បានបញ្ចប់ការវិភាគទិន្នន័យទាំងបែបបរិមាណ និងបែបគុណភាព ហើយបច្ចុប្បន្នកំពុងសរសេររបាយការណ៍។ ក្រោយពីបានវិភាគសំណុំទិន្នន័យជាតិ ក្នុងគម្រោង *"ការកសាងវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់សម្រាប់សកម្មភាពដោះមីននៅកម្ពុជា"* ក្រុមស្រាវជ្រាវ កំពុងរង់ចាំចម្លើយរបស់ UNDP និងអាជ្ញាធរគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (CMAA) ស្តីពីការបន្តរយៈពេលគម្រោងចំនួន ៣ខែ ដើម្បីធ្វើតេស្តដល់កន្លែងនូវឧបករណ៍វាយតម្លៃផលប៉ះពាល់ដែលបានដាក់ស្នើឡើង។ ក្រុមស្រាវជ្រាវក្នុងកម្មវិធីនេះ បានទៅចូលរួមក្នុងសិក្ខាសាលាថ្នាក់តំបន់នៅប្រទេសឡាវ កាលពីថ្ងៃទី ២២-២៤ សីហា សម្រាប់គម្រោងរយៈពេល ៣ឆ្នាំ ស្តីពី *"គោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវនៅកម្ពុជា និងឡាវ"* ដែលផ្តល់មូលនិធិដោយមជ្ឈមណ្ឌលអូស្ត្រាលី សម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR)។ គម្រោង *"ការលើកកម្ពស់សមភាពយេនឌ័រនៅទីផ្សារពលកម្ម ដើម្បីឲ្យកំណើនមានលក្ខណៈរាប់បញ្ចូលកាន់តែខ្លាំង"* គឺជាគម្រោងរយៈពេល ១៥ខែ ទទួលមូលនិធិពី ADB និងចែកចេញជាអនុគម្រោងពីរ គឺសមភាពយេនឌ័រ និងសេដ្ឋកិច្ចពលកម្ម។ ក្រុមស្រាវជ្រាវក្នុងគម្រោងនេះ ជាមួយនឹងទីប្រឹក្សាអន្តរជាតិ បានទៅសាកសួរអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងមួយចំនួន ដើម្បីប្រមូលទិន្នន័យថ្នាក់ទីពីរ (secondary data) និងកសាងទំនាក់ទំនង។ របាយការណ៍បណ្តោះអាសន្នសម្រាប់គម្រោង *"ធនាគារគាំទ្រសហគ្រាសធុនតូច និងមធ្យម"* ត្រូវបានបញ្ជូនទៅឲ្យម្ចាស់ជំនួយ KDI ហើយរបាយការណ៍សម្រេចបានលើកមកបង្ហាញនៅក្នុងសិក្ខាសាលារៀបចំឡើងដោយ KDI នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៩ សីហា ២០១១។ សំណើសម្រាប់ *"ការសិក្សាដើម្បីកំណត់តម្លៃសេវានៃក្រុមប្រឹក្សាអាជ្ញាកណ្តាល"* កំពុងតែពិនិត្យកែសម្រួល។

កម្មវិធីអភិវឌ្ឍន៍សង្គម (SD)

កម្មវិធីនេះ កំពុងអនុវត្តគម្រោងចំនួន ៣។ ទីមួយ គឺសៀវភៅមានចំណងជើងថា *"ការលើកកម្ពស់លទ្ធផលក្នុងវិស័យសុខាភិបាល៖ ស្ថាប័ន សន្ទុះចិត្ត និងការលើកទឹកចិត្ត ៖ ចងក្រងចេញពីការពិគ្រោះយោបល់នៅកម្ពុជា"* ផ្តល់មូលនិធិដោយសាកលវិទ្យាល័យស្រាវជ្រាវ (URC) និងបោះពុម្ពផ្សាយដោយវិទ្យាស្ថានសិក្សាពីអាស៊ីអាគ្នេយ៍ (ISEAS) នៅប្រទេសសិង្ហបុរី ហើយរំពឹងថា នឹងបោះពុម្ពចប់រួចរាល់នៅចុងខែសីហា។ សៀវភៅនេះ ប្រមូលចងក្រងនូវដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត និងបទពិសោធន៍ល្អៗ នៅក្នុង និងនៅក្រៅប្រទេសកម្ពុជា ដើម្បីកែលំអលទ្ធផលក្នុងវិស័យសុខាភិបាល ដោយផ្តោតជាពិសេសទៅលើ ស្ថាប័ន សន្ទុះចិត្ត និងការលើកទឹកចិត្ត។

គម្រោងទី២ គឺគំនិតផ្តួចផ្តើម EQUITAP[១] ដែលសម្របសម្រួលដោយ វិទ្យាស្ថានសម្រាប់គោលនយោបាយសុខាភិបាលនៅប្រទេសស្រីលង្កា ក្រោមជំនួយហិរញ្ញវត្ថុពី AusAID/IDRC។ គម្រោងនេះមានគោលដៅចំបងធ្វើវិភាគលើទិន្នន័យអង្កេតគ្រួសារមានស្រាប់ ដើម្បីប៉ាន់ស្មានពីផលប៉ះពាល់ផ្សេងៗដែលធ្វើឲ្យចុះក្រ និងជួបមហន្តរាយ ការវិវត្តទៅមុខ ភាពខុសគ្នាក្នុងការប្រើប្រាស់សេវាថែទាំសុខភាព និងអត្ថប្រយោជន៍ទទួលបានពីចំណាយរដ្ឋាភិបាល។ លទ្ធផលនៃការវិភាគពីផលប៉ះពាល់ផ្សេងៗដែលធ្វើឲ្យចុះក្រ និងជួបមហន្តរាយ និងការវិវត្តទៅមុខ ត្រូវបានពិនិត្យមើល និងទទួលបានការយល់ស្របពីអ្នកសម្របសម្រួល។ ការងារនៅសេសសល់គឺ ត្រូវបង្ហើយការវិភាគពី ភាពខុសគ្នាក្នុងការប្រើប្រាស់សេវាថែទាំសុខភាព និងអត្ថប្រយោជន៍ទទួលបានពីចំណាយរដ្ឋាភិបាល។

គម្រោងស្រាវជ្រាវរយៈពេល ៦ឆ្នាំ ស្តីពី "ការកសាងប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញបន្ទាប់ពីបានបញ្ចប់ទំនាស់" ឬ ហៅកាត់ថា "REBUILD" កំពុងស្ថិតក្នុងដំណាក់កាលកសាងគោលគំនិត។ គម្រោងនេះផ្តល់ហិរញ្ញប្បទានដោយ DFID-UK និងដឹកនាំដោយ Liverpool School of Tropical Medicine និង Queen Margaret University នៅទីក្រុង Edinburgh ប្រទេសអង់គ្លេស និងមានគោលដៅស្វែងរកភស្តុតាងល្អៗ ដើម្បីជួយរួមចំណែកលើកកម្ពស់សុខភាពប្រជាជនក្រីក្រខ្លាំងក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ឯកសារពិធីការស្រាវជ្រាវ ៣ ត្រូវបានបង្កើតឡើង៖ ១) ផលប៉ះពាល់នៃការផ្លាស់ប្តូរគោល នយោបាយហិរញ្ញប្បទានសុខាភិបាល ទៅលើលំនាំចំណាយ សម្រាប់ការថែទាំសុខភាពរបស់គ្រួសារក្រីក្រនៅកម្ពុជា ២) គោលនយោបាយទាក់ទាញ និងរក្សាបុគ្គលិកផ្នែកសុខាភិបាលនៅតំបន់ជនបទ និង ៣) គំរូកិច្ចសន្យា និងការគ្រប់គ្រងលទ្ធផលការងារ នៅកម្ពុជា។ ក្រុមស្រាវជ្រាវកំពុងរៀបចំធ្វើបទបង្ហាញអំពីពិធីការស្រាវជ្រាវទាំងបីនេះ ជូនដល់ក្រុមការងារបច្ចេកទេសផ្នែកសុខភាព នៃក្រសួងសុខាភិបាល នៅថ្ងៃទី៨ កញ្ញា ដើម្បីទទួលបានយោបល់ ត្រឡប់លើសំណួរស្រាវជ្រាវសំខាន់ៗអំពីអ្នកពាក់ព័ន្ធ។

គម្រោងស្រាវជ្រាវថ្មីៗទាំង៣ គ្រោងចាប់ផ្តើមនៅខែកញ្ញា គឺមាន៖ ១) គម្រោង "ស្ថានភាពមូលធនសង្គមនៅកម្ពុជា" ផ្តល់មូលនិធិដោយ Senshu University នៃប្រទេសជប៉ុន ២) គម្រោង "មាគ៌ាឈានទៅផ្តល់សេវាឲ្យបានទូទៅនៅកម្ពុជា" ដោយសហការជាមួយ Nassal Institute for Global Health នៃសាកលវិទ្យាល័យមែលប៊ិន ប្រទេសអូស្ត្រាលី និង ៣) គម្រោង "រឿងល្អៗមិនដែលដើរស្របគ្នាទេ៖ ការវិភាគពីភាពប្រទាំងប្រទើសរវាងការកសាងសន្តិភាព និងប្រជាធិបតេយ្យភាវូបនីយកម្ម" ដែលត្រូវសិក្សារួមគ្នាជាមួយសាស្ត្រាចារ្យ Joakim Öjendal នៃសាកលវិទ្យាល័យ Gothenburg ប្រទេសស៊ុយអ៊ែត។

---

១ EQUITAP ឬ Equity in Asia-Pacific Health System (សមធម៌ក្នុងប្រព័ន្ធសុខាភិបាលនៅអាស៊ីប៉ាស៊ីហ្វិក) ជាកិច្ចប្រឹងប្រែងរួមគ្នារបស់អ្នកស្រាវជ្រាវជាង ១៥ក្រុម នៅអាស៊ី និងអឺរ៉ុប ដើម្បីពិនិត្យពីសមធម៌ក្នុងប្រព័ន្ធសុខាភិបាលជាតិនានានៅអាស៊ីប៉ាស៊ីហ្វិក។ កិច្ចសហការណ៍នេះ រួមមាន ការកសាងឧបករណ៍សម្រាប់ស្រាវជ្រាវ និងការវាយតម្លៃជាក់ស្តែងលើការអនុវត្តប្រព័ន្ធសុខាភិបាលជាតិនានា។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

នៅថ្ងៃទី១២ សីហា ២០១១ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) និង ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) បានចុះហត្ថលេខាព្រមព្រៀងលើកម្មវិធីថ្មី ដែលចែងពីការផ្តល់ជំនួយឧបត្ថម្ភរបស់ Sida ចំនួន ៤,២លានដុល្លារ ក្នុងរយៈពេល ៥ឆ្នាំ ចាប់ពីខែកក្កដា ២០១១ ដល់ មិថុនា ២០១៦។ ធនធាននេះ នឹងជួយទ្រទ្រង់ចំណាយប្រតិបត្តិការស្នូល ព្រមទាំងការអភិវឌ្ឍសមត្ថភាព និងការស្រាវជ្រាវសំខាន់ៗរបស់ កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ ក៏ដូចជាការស្រាវជ្រាវថ្មីៗរបស់ វបសអ ស្តីពីបញ្ហាទើបផុសឡើង ដូចជា កំណើនមានការរាប់បញ្ចូល បម្រែបម្រួលអាកាសធាតុ និងការអប់រំ ជាដើម។ ក្នុងដំណើរការនេះ និងស្របតាមតម្រូវការរបស់ការិយាល័យសវនកម្មប្រទេសស៊ុយអែត អង្គការ Sida បានជួលក្រុមហ៊ុន KPMG ឲ្យត្រួតពិនិត្យការងារស្ថាប័នរបស់ វបសអ។ ការត្រួតពិនិត្យនេះ បានបង្ហាញថា វបសអ មានការគ្រប់គ្រង និងអភិបាលកិច្ចស្ថាប័នប្រកបដោយស្តង់ដារខ្ពស់។ កិច្ចព្រមព្រៀងថ្មីនេះ បានប្រកាសចេញនៅថ្ងៃទី២៥ សីហា ២០១១ ក្នុងកិច្ចប្រជុំពាក់កណ្តាលឆ្នាំរបស់ក្រុមប្រឹក្សាភិបាលនៃ វបសអ ដែលពេលនោះ ឯ.ឧ បណ្ឌិត សុខ ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាលថ្មីនៃវិទ្យាស្ថាន វបសអ បានអញ្ជើញចូលរួមជាលើកដំបូង។

បន្ទាប់ពីសិក្ខាសាលានៅ វបសអ កាលពីខែកក្កដា ២០១១ វបសអ និងដៃគូនានាក្នុងបណ្តាញវិភាគអភិវឌ្ឍន៍នៃមហាអនុតំបន់មេគង្គ (GMS-DAN) បានបញ្ជូនសំណើមួយទៅមូលនិធិ Rockefeller ស្នើសុំឲ្យបន្តជំនួយទ្រទ្រង់ចំនួន ៣ឆ្នាំទៀតពីឆ្នាំ២០១១ ដល់ ២០១៤ លើគម្រោងស្រាវជ្រាវធំទូលាយ ស្តីពី "កំណើនមានការរាប់បញ្ចូល និងសមាហរណកម្មកម្រិតអនុតំបន់ក្នុង GMS"។ វបសអ ក៏បានពិភាក្សាជាមួយមជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិ (IDRC) ផងដែរ ស្តីពីការផ្តល់ជំនួយជាគោលការណ៍ សម្រាប់ការស្រាវជ្រាវបន្ថែមរបស់ GMS-DAN។ មជ្ឈមណ្ឌល IDRC មូលនិធិ Rockefeller និង GMS-DAN បានជួបប្រជុំគ្នានៅទីក្រុងបាងកក កាលពីថ្ងៃទី៣០ សីហា ដើម្បីពិភាក្សាពីវិធីដំណើការកិច្ចសហការ ៣ភាគី នេះ ។

វបសអ បានបញ្ចប់ការសរសេរឯកសារព័ត៌មានទូទៅពីប្រទេសកម្ពុជា ដែលវិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី (ADBI) បានចុះកិច្ចសន្យាឲ្យរៀបចំឡើង សម្រាប់ផ្តល់ព័ត៌មានដល់ការសិក្សាថ្មីធំមួយរបស់វិទ្យាស្ថាន ADBI នៃធនាគារ ADB ក្រោមចំណងជើងថា អាស៊ាន ២០៣០៖ ការរីកលូតលាស់ទាំងអស់គ្នាដើម្បីវិបុលភាពរួម។ លទ្ធផលនៃគម្រោងនេះ គ្រោងផ្សព្វផ្សាយចេញនៅខែឧសភា ២០១២ នៅកម្ពុជា នៅពេលប្រទេសកម្ពុជាធ្វើជាប្រធានកិច្ចប្រជុំអាស៊ាន។ ADBI ក៏គ្រោងបោះពុម្ពផ្សាយឯកសារព័ត៌មានទូទៅពីប្រទេសកម្ពុជានេះ ក្នុងឆ្នាំ២០១២ ដែរ។

នៅពាក់កណ្តាលឆ្នាំ២០១១ វបសអ បានចុះកិច្ចសន្យាជាមួយ IDRC លើការផ្តល់យោបល់ពិគ្រោះរយៈពេលខ្លី ស្តីពីភាពអាចធ្វើបាន និងដំណើរការបង្កើតវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយអភិវឌ្ឍន៍ឯករាជ្យ (MDRI) នៅប្រទេសមីយ៉ាន់ម៉ា ដោយផ្អែកតាមគំរូរបស់ វបសអ។ ការងារនេះ ជាចម្លើយតបទៅនឹងសំណើពីអ្នកពាក់ព័ន្ធសំខាន់ៗក្នុងគំនិតផ្តួចផ្តើមបង្កើត MDRI បន្ទាប់ពីបានធ្វើទស្សនកិច្ចនៅ វបសអ នៅចុងឆ្នាំ២០១០។ នៅខែសីហា ២០១១ នាយកប្រតិបត្តិរបស់ វបសអ និងអ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ បានធ្វើទស្សនកិច្ចនៅទីក្រុង Yangon ដើម្បីចូលរួមកម្មវិធីពិគ្រោះយោបល់រយៈពេល ៣ថ្ងៃនៅទីនោះ។

វបសអ បានអនុវត្តវិធីបញ្ជូនសារអេឡិចត្រូនិចជាទៀងទាត់ថ្មីមួយ ដើម្បីប្រកាសផ្សាយពី ព្រឹត្តិការណ៍ និងឯកសារបោះពុម្ពផ្សាយថ្មីៗផ្នែកស្រាវជ្រាវ ព្រមទាំងគេហទំព័ររបស់ វបសអ

(តទៅទំព័រ ២២)

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៥ លេខ៣ ខែកក្កដា~កញ្ញា ឆ្នាំ២០១១

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន ។ អ្នកនិពន្ធ ត្រូវទាក់ទង វបសអ មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@cdri.org.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ៖ វបសអ
គ្រប់គ្រងកែសំរួល៖ យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម៖ អ៊ុំ ចាន់ថា និង ម៉ែន ច័ន្ទធីតា
ជំនួយការកែសំរួល៖ ខេង សេង និង អ៊ឹង សុជាតិ។ រោងពុម្ព T&S ភ្នំពេញ។
រូបភាពទំព័រមុខ៖ http://www.traffickingproject.org/2009/07/

© រក្សាសិទ្ធិ ២០១១ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។